ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ឯកសារជំនួយ

# ការអប់រំកុមារពិការសតិបញ្ញា

សម្រាប់គ្រូសម្របសម្រួល
វគ្គបណ្តុះបណ្តាល រយៈពេល៧ថ្ងៃ

ឯកសារឧបសម្ព័ន្ធទី២ របស់ឯកសារ ការអប់រំកុមារពិការសតិបញ្ញា

ឆ្នាំ២០១៨

# អារម្ភកថា

ឯកសារជំនួយគ្រូបង្រៀន ស្តីពី «ការអប់រំកុមារពិការសតិបញ្ញា *សម្រាប់គ្រូសម្របសម្រួល*» ត្រូវបានរៀបចំឡើងដោយក្រសួងអប់រំ យុវជននិងកីឡា រួមមាននាយកដ្ឋានអប់រំពិសេស នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹតការ និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដោយសហការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធ និងអ្នកជំនួយការបច្ចេកទេស។

ខ្លឹមសារនៅក្នុងសៀវភៅអត្ថបទ «ការអប់រំកុមារពិការសតិបញ្ញា» មានទាំងអស់១២ប្រធានបទ ហើយការបណ្តុះបណ្តាលប្រធានបទទាំងអស់នេះដល់គ្រូបង្រៀន ត្រូវប្រើរយៈពេលច្រើនដល់រាប់សប្តាហ៍។ ដោយសារការបណ្តុះបណ្តាលប្រធានបទទាំងអស់ ត្រូវការពេលវេលា និងថវិកាច្រើន ពេលនេះក្រុមការងារផលិតឯកសារ បានរៀបចំសៀវភៅសម្រាប់គ្រូសម្របសម្រួលនេះ សម្រាប់តែប្រធានបទសំខាន់ៗបំផុត មួយចំនួនដែលគ្រូបង្រៀនត្រូវការចាំបាច់បំផុត ដូចមានក្នុងមាតិកានៅទំព័របន្ទាប់ សម្រាប់រយៈពេលបណ្តុះបណ្តាល យ៉ាងតិចចំនួន៧ថ្ងៃ។

អ្នករៀបចំវគ្គបណ្តុះបណ្តាល និងគ្រូសម្របសម្រួល អាចបណ្តុះបណ្តាលប្រធានបទទាំងនេះ បន្តបន្ទាប់គ្នាទាំង៧ថ្ងៃ ឬអាចដាច់ៗពីគ្នាក្នុងចន្លោះពេលពីមួយ ទៅពីរខែ ទៅតាមលទ្ធភាពពេលវេលា និងថវិកា ប៉ុន្តែមិនគួរអូសបន្លាយពេលយូរជាងនេះ ព្រោះសិក្ខាកាមអាចភ្លេចខ្លឹមសារមេរៀន ដែលមានទំនាក់ទំនងគ្នា ទៅនឹងការរៀបចំវិធីបង្រៀន និងជួយដល់សិស្សមានតម្រូវការពិសេស។

វិធី បច្ចេកទេស និងសម្ភារបង្រៀន ដែលមាននៅក្នុងឯកសារនេះ ត្រូវបានរៀបចំដោយ មន្ត្រីនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគ្រូអប់រំពិសេស របស់ដៃគូអភិវឌ្ឍ ព្រមទាំងបានសាកល្បង ជាមួយគ្រូបង្រៀនមួយចំនួន នៅកម្រិតបឋមសិក្សា។

សម្រាប់ប្រធានបទនីមួយៗ យើងខ្ញុំបានរៀបចំជាគម្រោងលំនាំបង្រៀន ឬបណ្តុះបណ្តាល និងកិច្ចតែងការបង្រៀនសម្រាប់តែជំហ៊ានទី៣ ដែលបែងចែកខ្លឹមសារ តាមពេលវេលា និងលទ្ធផលរំពឹងទុក។ ក្នុងពេលបង្រៀន គ្រូសម្របសម្រួល អាចជ្រើសរើសយក វិធី សកម្មភាព និងសម្ភារបង្រៀន ដែលមានស្រាប់ក្នុងសៀវភៅនេះ ឬអាចជ្រើសរើសយកវិធីផ្សេងដែលល្អជាងនេះ ឱ្យតែសិក្ខាកាមបានចូលរួមរៀន អាចសម្រេចគោលបំណង និងលទ្ធផលរំពឹងទុកសម្រាប់ប្រធានបទ នីមួយៗ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ដៃគូអភិវឌ្ឍពាក់ព័ន្ធ អ្នកជំនួយការបច្ចេកទេស មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានពាក់ព័ន្ធ និងគ្រូអប់រំពិសេសទាំងអស់ ដែលបានផលិត និងរៀបចំឯកសារដ៏មានសារៈសំខាន់នេះ។

ក្រុមការងារយើងខ្ញុំនឹងរង់ចាំទទួលមតិយោបល់ជួយកែលម្អប្រកបដោយន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូទាំងអស់ ដោយក្តីសោមនស្សរីករាយ ដើម្បីរួមចំណែកអភិវឌ្ឍវិស័យអប់រំ។

**ក្រុមការងារផលិតឯកសារ**

## ខ្លឹមសារមេរៀន សម្រាប់បណ្តុះបណ្តាល *(រយៈពេល៧ថ្ងៃ)*

**មេរៀនទី៣ ៖ ខ្សោយបញ្ញា** (Intellectual Disabilities)

**លំបាកក្នុងការសិក្សាមុខវិជ្ជា** (Learning Disabilities)

**អូទីសឹម** (Autism Spectrum Disorder: ASD)**និង**

**មេរៀនទី៤ ៖ ដោនស៊ីនដ្រូម** (Down Syndrome)

**ពិការចលករខួរក្បាល** (Cerebral Palsy)

*ខ្លឹមសាររួមសម្រាប់មេរៀនទាំងពីរ ផ្តោតលើ៖*

- និយមន័យ
- ចំណាត់ថ្នាក់
- លក្ខណៈសម្គាល់
- មូលហេតុ
- ការការពារ

សម្រាប់រយៈពេលបណ្តុះបណ្តាល **ចំនួន១ថ្ងៃ**

**មេរៀនទី៦ ៖ កម្មវិធីសិក្សា និង បញ្ជីវាយតម្លៃសម្បទារបស់កុមារ**

- ផ្តោតលើបឋមសិក្សាកម្រិតទាប ( ទី១ និងទី២ )
- សកម្មភាពផ្ទាល់ខ្លួនសម្រាប់ការរស់នៅប្រចាំថ្ងៃ
- សកម្មភាពសង្គម
- សកម្មភាពការសិក្សា
- សកម្មភាពការងារ

សម្រាប់រយៈពេលបណ្តុះបណ្តាល **ចំនួន១ថ្ងៃ**

**មេរៀនទី៧៖ វិធីសាស្ត្របង្រៀន**

*១.វិធីសាស្ត្របង្រៀនកុមារមានការលំបាកសិក្សាមុខវិជ្ជា៖*

- ពិបាកអាន
- ពិបាកសរសេរ
- ពិបាកគណនា

សម្រាប់រយៈពេលបណ្តុះបណ្តាល **ចំនួន១ថ្ងៃ**

*២.លំហូរ វិធី គន្លឹះ និងល្បិច ក្នុងការបង្រៀនបំណិនអំណានភាសាខ្មែរ កម្រិតបឋមសិក្សា (នៅក្នុងឯកសារឧបសម្ពន្ធ)៖*

- ស្គាល់សូរ តួអក្សរ និងសូរ ( សម្រាប់អំណានភាសាខ្មែរថ្នាក់ដំបូងៗ )

- ប្រកបព្យាង្គ ( សម្រាប់អំណានភាសាខ្មែរថ្នាក់ដំបូងៗ )

សម្រាប់រយៈពេលបណ្តុះបណ្តាល **ចំនួន១ថ្ងៃ**

*៣.វិធីសាស្ត្របង្រៀនកុមារមានបញ្ហាខ្សោយបញ្ញា*

- គោលការណ៍មូលដ្ឋានសម្រាប់បង្រៀន
- ប្រើប្រាស់ដំណាក់កាលនៃការសិក្សា
- ប្រើវិធីបង្រៀនបត់បែន

សម្រាប់រយៈពេលបណ្តុះបណ្តាល **ចំនួន១ថ្ងៃ**

*៤.វិធីសាស្ត្របង្រៀនកុមារអូទីសឹម*(ASD)

- វិធីសាស្ត្រសម្រាប់បង្រៀនកុមារអូទីសឹម
- សកម្មភាពជាក់លាក់ សម្រាប់ជួយកុមារអូទីសឹមតាមករណីផ្សេងៗគ្នា

សម្រាប់រយៈពេលបណ្តុះបណ្តាល **ចំនួន១ថ្ងៃ**

**មេរៀនទី១០ និង១១**

ការគ្រប់គ្រងថ្នាក់រៀន និងការគ្រប់គ្រងកុមារមានវិបត្តិអាកប្បកិរិយា៖

- ការគ្រប់គ្រងថ្នាក់រៀន
- ការគ្រប់គ្រងកុមារមានវិបត្តិអាកប្បកិរិយា

សម្រាប់រយៈពេលបណ្តុះបណ្តាល **ចំនួន១ថ្ងៃ**

# មេរៀនទី៣

## ខ្សោយបញ្ញា (Intellectual Disabilities)
## ដោនស៊ីនដ្រូម (Down Syndrome)
## លំបាកក្នុងការសិក្សាមុខវិជ្ជា (Learning Disabilities)
## អូទីសឹម (Autism Spectrum Disorder: ASD)និង
## ពិការចលករខួរក្បាល (Cerebral Palsy)

# គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

## មេរៀនទី៣៖ ខ្សោយបញ្ញា សម្រាប់រយៈពេល ៧០នាទី

| ខ្លឹមសារសំខាន់ៗ<br>Key Content of the Topic | វិធីសាស្ត្រ និងសកម្មភាពបង្រៀន<br>Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន<br>Training/Teaching Materials | រយៈពេលបង្រៀន<br>Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា<br>Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| **១.និយមន័យខ្សោយបញ្ញា** | • សំណួរ ៖ អ្នកធ្លាប់ឃើញកុមារខ្សោយបញ្ញា នៅក្នុងថ្នាក់រៀនរបស់អ្នកឬទេ? ចូរអ្នកគ្រូឱ្យនិយមន័យខ្សោយបញ្ញា។<br>• គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្តាខៀន<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយដោយឱ្យសិក្ខាកាមអានមេរៀនអំពីនិយមន័យរបស់ខ្សោយបញ្ញា( **ទំព័រទី២៧** ) | • Power point ដែលមានសំណួរ<br>• ហ្វឺតសរសេរ<br>• ផ្ទាំងក្រដាសធំ | ៥នាទី | សិក្ខាកាមយល់ដឹងអំពីខ្សោយបញ្ញាផ្សេងគ្នា និងសេចក្តីត្រូវការរបស់ពិការភាព |
| 2. ការចាត់ចំណាត់ថ្នាក់អ្នកឯកទេសបែងចែក | • **ជម្រើស១៖** បង្ហាញតាម Power point | Power point និង | ៥នាទី | សិក្ខាកាមយល់ដឹងអំពីកំរិតពិការខ្សោយបញ្ញាផ្សេងគ្នា និងសេចក្តីត្រូវ |

| | | | | |
|---|---|---|---|---|
| ខ្សោយបញ្ញាជា 4 កម្រិតៈ<br>- កម្រិតស្រាល IQ ៥០ ទៅ ៧០<br>- កម្រិតមធ្យម IQ 35 ទៅ ៤០<br>- កម្រិតធ្ងន់ធ្ងរ IQ ២០ ទៅ៣៤<br>- និងធ្ងន់ធ្ងរបំផុត IQ ទាបជាង២០ | • **ជម្រើស២ៈ** បង្ហាញតាមផ្ទាំងក្រដាសធំ សរសេរខ្លឹមសារសំខាន់ៗ<br>• ពន្យល់ និងបកស្រាយម្តងមួយ | LCD | | ការរបស់ពិការភាព |
| **៣.លក្ខណៈសម្គាល់កុមារមានបញ្ហាខ្សោយបញ្ញា** | • ពិភាក្សាក្រុម (គ្រូសម្របសម្រួលបែងចែកសិក្ខាកាមជា ៤ ឬ ៥ ក្រុម) អានមេរៀន ពិភាក្សា និងកត់ត្រាលើផ្ទាំងក្រដាសធំ<br>• ការបង្ហាញតាមក្រុម<br>• ការបង្ហាញរបស់គ្រូសម្របសម្រួល<br>• បង្ហាញវីដេអូខ្លីៗ អំពីកុមារខ្សោយបញ្ញា (បើមាន) | ក្រដាសផ្ទាំងធំ ហ្វឺត | ២០នាទី | សិក្ខាកាមអាចកំណត់ និងស្គាល់កុមារខ្សោយបញ្ញា តាមកម្រិតពិការភាព |
| **៤.មូលហេតុខ្សោយបញ្ញា** (មុនកំណើត កំឡុងពេលកំណើត និងក្រោយពេលកំណើត) | • ពិភាក្សាក្រុម (គ្រូសម្របសម្រួលបែងចែកសិក្ខាកាមជា ៤ ឬ ៥ ក្រុម) ពិភាក្សា និងកត់ត្រាលើផ្ទាំងក្រដាសធំ<br>• ការបង្ហាញតាមក្រុម | ក្រដាសផ្ទាំងធំ ហ្វឺត | ២០នាទី | សិក្ខាកាមអាចប្រាប់អំពីមូលហេតុមុនកំណើត កំឡុងពេលកំណើត និងក្រោយពេលកំណើត |

| | | | | |
|---|---|---|---|---|
| | • គ្រូសម្របសម្រួលបង្ហាញចម្លើយ | | | |
| **៥.ការការពារពិការភាព** (មុនកំណើត កំឡុងពេលកំណើត និងក្រោយពេលកំណើត) | • ពិភាក្សាក្រុម (គ្រូសម្របសម្រួលបែងចែកសិក្ខាកាមជា ៤ ឬ ៥ ក្រុម) ពិភាក្សា និងកត់ត្រាលើផ្ទាំងក្រដាសធំ<br>• ការបង្ហាញតាមក្រុម<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយ | ក្រដាសផ្ទាំងធំ ហ្វឺត | ២០នាទី | សិក្ខាកាមអាចប្រាប់អំពីវិធិការពារមុនកំណើត កំឡុងពេលកំណើត និងក្រោយពេលកំណើត ទៅឪពុកម្ដាយ និងចូលរួមកាត់បន្ថយពិការភាពក្នុងសង្គម |

## កិច្ចតែងការបង្រៀន/បណ្ដុះបណ្ដាល (សម្រាប់តែជំហានទី៣)

**បំណិនឧិងខ្លឹមសារមេរៀន** : **ខ្សោយបញ្ញា**

**វិធី និងសកម្មភាពបង្រៀន** : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្តែងតួ ករណីសិក្សា បង្ហាញវីដេអូ រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងពីការសិក្សា** : **ចំណេះសម្បទា**

សិក្ខាកាមប្រាប់បានពីនិយមន័យ ខ្សោយបញ្ញា

: **បំណិនសម្បទា**

- សិក្ខាកាមដែលជាគ្រូ ប្រាប់បានថា ក្នុងថ្នាក់របស់គាត់ មានកុមារប្រហែល..........នាក់ខ្សោយបញ្ញា
- សិក្ខាកាមប្រាប់ឧទាហរណ៍ អំពីលក្ខណៈសម្គាល់របស់កុមារខ្សោយបញ្ញា

: **ចរិយាសម្បទា**

- សិក្ខាកាមប្រើចំណេះដឹង បំណិន និងបទពិសោធន៍ ដែលទទួលបាន ទៅអប់រំណែនាំ ដល់ឪពុកម្តាយដែលមានកូនខ្សោយបញ្ញា នៅក្នុងសហគមន៍ ឱ្យចេះជួយកុមារប្រភេទនេះ
- ពេលត្រឡប់ទៅវិញ សិក្ខាកាមដែលជាគ្រូ ប្រើបច្ចេកទេស និងសម្ភារបង្រៀន ជួយដល់កុមារខ្សោយបញ្ញា នៅក្នុងថ្នាក់របស់គាត់

**សម្ភារឧបទេ្ទស** - រូបភាព និងវីដេអូ កុមារផ្សេងៗ ដែលមានបញ្ហាខ្សោយបញ្ញា
- ផ្ទាំងក្រដាសធំ សម្រាប់សរសេរ គូស និងផាត់ពណ៌ផ្សេងៗ
- ហ្វឺតសរសេរ ក្រដាសពណ៌ ស្កុត
- LCD projector, Laptop

| សកម្មភាពគ្រូសម្របសម្រួល | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស/សិក្ខាកាម |
|---|---|---|

| Trainer's Activities: | Key contents | Trainees' activities |
|---|---|---|
| • សំណួរ ៖<br>អ្នកធ្លាប់ឃើញកុមារខ្សោយបញ្ញា នៅក្នុងថ្នាក់រៀនរបស់អ្នកឬទេ? ចូរអ្នកគ្រូឱ្យនិយមន័យខ្សោយបញ្ញា។<br>• គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្តារខៀន<br>• គ្រូបង្ហាញចម្លើយដោយឱ្យសិក្ខាកាមអានមេរៀន និយមន័យខ្សោយបញ្ញា (**ទំព័រទី២៧**) | **១. និយមន័យ ខ្សោយបញ្ញា**<br>ខ្សោយបញ្ញាសំដៅដល់មនុស្សទាំងឡាយណាដែលមានមុខងារបញ្ញានិងអាកប្បកិរិយា មិនពេញលេញនាំឱ្យប៉ះពាល់ដល់<br>• បំណិនយល់ដឹង និងទំនាក់ទំនងសង្គម<br>• សកម្មភាពជីវភាពប្រចាំថ្ងៃ<br>• ពិន្ទុ IQ ក្រោម ៧៥<br>• អាយុ ក្រោម១៨ ឆ្នាំ | <u>ការងារក្រុម៤ឬ៥នាក់៖</u><br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់កុមារនៅក្នុងថ្នាក់ និងភូមិរបស់ខ្លួន<br>២. សំយោគនិយមន័យរបស់ ខ្សោយបញ្ញា<br>៣. តំណាងក្រុមរាយការណ៍លទ្ធផលពិភាក្សា<br>៤. អានមេរៀន**ទំព័រទី២៧** |
| ១. ចែកសិក្ខាកាមជាក្រុម៤ឬ៥នាក់<br>▪ គ្រូសម្របសម្រួល បែងចែកសិក្ខាកាមជា៣ក្រុមតូចៗ<br>▪ នាំសិក្ខាកាមធ្វើការងារក្រុម និងអានខ្លឹមសារមេរៀន<br>២. សំណួរ៖ ដាក់សំណួរអំពីខ្លឹមសារតូចៗជាក់លាក់ (២ទៅ៣ ក្នុងមួយកម្រិត) រួចឱ្យសិក្ខាកាមប្រាប់ថា វាស្ថិតក្នុងកម្រិតណា?<br>៣. បំភ្លឺសំណួររបស់សិក្ខាកាម<br>៤. បង្ហាញដល់សិក្ខាកាម | **២.ការចាត់ចំណាត់ថ្នាក់**<br><br>អ្នកឯកទេសបែងចែក ខ្សោយបញ្ញាជា 4កម្រិត:<br><br>• កម្រិត ស្រាល IQ ៥០ទៅ ៧០<br>• កម្រិតមធ្យម IQ 35ទៅ ៤០<br>• កម្រិតធ្ងន់ធ្ងរ IQ ២០ទៅ៣៤<br>• និងធ្ងន់ធ្ងរបំផុត IQ | <u>ការងារក្រុម៤ឬ៥នាក់៖</u><br>១.ស្តាប់សំណួរ<br>២. អានដើម្បីស្វែងរកខ្លឹមសារ និងប្រាប់ពីកម្រិតរបស់ខ្សោយបញ្ញា<br>៣. ពិភាក្សា រួចតំណាងក្រុមរាយការលទ្ធផលពិភាក្សា<br>៤. ក្រុមប្រកួតគ្នា រកក្រុមដែលឆ្លើយបានត្រឹមត្រូវ<br><br>សិក្ខាកាមអានមេរៀនបន្ថែម |

| | | |
|---|---|---|
| **បង្ហាញតាម** Power point | | និងសួរសំណួរទៅគ្រូឧទ្ទេស |
| • ជម្រើសទី១៖<br>– ចាក់វីដេអូ អំពីកុមារខ្សោយបញ្ញា<br>• ជម្រើសទី២៖<br>– សិក្សាលើករណីសិក្សា<br>• ឱ្យក្រុម ឆ្លើយសំណួរអំពីលក្ខណៈសម្គាល់ខ្សោយបញ្ញា<br>• បង្ហាញខ្លឹមសារមេរៀន (បញ្ចាំងស្លាយ ឬផ្ទាំងក្រដាសធំ) | **៣. លក្ខណៈសម្គាល់ ខ្សោយបញ្ញា**<br>• ការចងចាំខ្សោយ<br>• មានការយឺតយ៉ាវក្នុងការសំរេចចិត្ត<br>• មិនសូវមានបំណិនអនុវត្តសកម្មភាពប្រចាំថ្ងៃ<br>• ពិបាកធ្វើការសន្ទនា<br>• មានវិបត្តអាកប្បកិរិយា<br>• ពិបាកផ្តល់ជាគោលគំនិត ឬយោបល់<br>• ពិបាកកំណត់គោលដៅសម្រាប់ខ្លួន | <u>ការងារក្រុម៖</u><br>• មើលវីដេអូខ្លី /អានករណីសិក្សា<br>• កត់ត្រាសកម្មភាពកុមារនៅក្នុងវីដេអូ/ករណីសិក្សា<br>• ពិភាក្សា និង កត់ត្រាចំលើយ<br>• ជ្រើសអ្នកបង្ហាញ<br>• អានខ្លឹមសារមេរៀន |
| • បែងចែក ៤ ឬ ៥ក្រុម<br>• ដាក់សំណួរ<br>– តើខ្សោយបញ្ញា បណ្តាលមកពីមូលហេតុអ្វីខ្លះ?<br>• បង្ហាញចម្លើយ | **៤. មូលហេតុ ខ្សោយបញ្ញា**<br>• មុនកំណើត<br>• កំឡុងពេលកំណើត<br>• ក្រោយពេលកំណើត | <u>ការងារក្រុម៖</u><br>– អានអត្ថបទ<br>– សង្ខេបខ្លឹមសារ<br>– រាយការណ៍ចម្លើយ<br>– ប្រកួតចម្លើយជាមួយក្រុមដទៃ |
| • បែកក្រុម៤ឬ៥នាក់<br>• ពិភាក្សា ព្យុះគំនិត<br>– តើគេគួរធ្វើដូចម្តេចខ្លះ ដើម្បីបង្ការពីពិការ ខ្សោយបញ្ញា? | **៥. ការការពារពិការភាព**<br>សូមមើលអត្ថបទ ត្រង់ចំណុច៖<br>• មុនកំណើត<br>• កំឡុងពេលកំណើត | <u>ការងារក្រុម៖</u><br>– ផ្អែកលើចំណេះដឹងដែលមានស្រាប់ គិតអំពីវិធីដែលអាច បង្ការកុំឱ្យកុមារ មានពិការ ខ្សោយបញ្ញា (ចាប់ពីមុនកើត រហូត |

| | | |
|---|---|---|
| • សម្របសម្រួលលទ្ធផលតាមក្រុម<br>• បង្ហាញចម្លើយ | • ក្រោយពេលកំណើត | ដល់ពេញវ័យ)<br>– សរសេរចម្លើយលើក្រដាសតាមក្រុម រួចបញ្ជូនទៅក្រុមក្បែរគ្នា ដើម្បីប្រៀបធៀបរកចម្លើយដូចគ្នា<br>– រាយការណ៍ចម្លើយ<br>អានអត្ថបទអំពី ការការពារ បញ្ចៀសពីពិការខ្សោយបញ្ញា។ |

## គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

**មេរៀនទី៤៖ Down Syndrome (ដោនស៊ីនដ្រុម)** សម្រាប់រយៈពេល ៥៥នាទី

| ខ្លឹមសារសំខាន់ៗ | វិធីសាស្ត្រ និងសកម្មភាពបង្រៀន | សម្ភារបង្រៀន | រយៈពេលបង្រៀន | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា |
|---|---|---|---|---|

| Key Content of the Topic | Method & Activities to be Used in Teaching/Training | Training/Teaching Materials | Duration for training/teaching | Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| និយមន័យ<br>Down Syndrome | • សំណួរ ៖<br>– អ្នកធ្លាប់ឃើញកុមារពិការ Down Syndrome នៅក្នុងថ្នាក់រៀនរបស់អ្នកដែរឬទេ ?<br>– ចូរអ្នកគ្រូឱ្យនិយមន័ពិការ Down Syndrome<br>• កត់ចម្លើយនៅលើក្តារខៀន<br>• គ្រូបង្ហាញចម្លើយដោយឱ្យសិស្សអានមេរៀន | Power point ដែលមានសំណួរ ហ្វឺតសរសេរ ផ្ទាំងក្រដាសធំ | ៥នាទី | សិក្ខាកាមបានយល់ដឹងអំពីពិការ Down Syndrome និងសេចក្តីត្រូវការ របស់អ្នកមានពិការភាពនេះ |
| លក្ខណសំគាល់កុមារពិការ Down Syndrome | • ចាក់វីដេអូដើម្បីឱ្យសិស្សសង្កេបកុមារពិការ Down Syndrome<br>• គ្រូសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន/ផ្ទាំងក្រដាសធំ<br>• សម្របសម្រួលសិក្ខាកាមអានសៀវភៅមេរៀន | ក្រដាសផ្ទាំងធំ ហ្វឺត វិដេអូ | ១០នាទី | សិក្ខាកាមអាចកំណត់សំគាល់ពិការ Down Syndrome និងអាចរៀបរាប់ លក្ខណៈភិនភាគខាងក្រៅបាន ដល់អ្នកដទៃ |
| មូលហេតុពិការ | • ពិភាក្សាក្រុម (គ្រូសម្របសម្រួលបែងចែកសិក្ខាកាមជា ៤ ឬ ៥ក្រុម) ពិភាក្សា និងកត់ត្រាលើផ្ទាំងក្រដាសធំ | ក្រដាសផ្ទាំងធំ ហ្វឺត | ២០នាទី | សិស្សអាចប្រាប់អំពីមូលហេតុពិការមុនកំណើត កំឡុងពេលកំណើត និងក្រោយពេលកំណើត |

| | | | | |
|---|---|---|---|---|
| | • ការបង្ហាញតាមក្រុម<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយ | | | |
| ការការពារពិការភាព | • ពិភាក្សាក្រុម (គ្រូសម្របសម្រួលបែងចែកសិក្ខាកាមជា ៤ ឬ ៥ក្រុម) ពិភាក្សា និងកត់ត្រាលើផ្ទាំងក្រដាសធំ<br>• ការបង្ហាញតាមក្រុម<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយ | ក្រដាសផ្ទាំងធំ ហ្វឺត | ២០នាទី | សិក្ខាកាមអាចប្រាប់អំពីវិធីការពារពិការមុនកំណើត កំឡុងពេលកំណើត និងក្រោយពេលកំណើត ទៅឪពុកម្តាយ និងចូលរួមកាត់បន្ថយពិការភាពក្នុងសង្គម |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**ចំណងជើងនិងខ្លឹមសារមេរៀន** : **ពិការ Down Syndrome** (ដោនស៊ីនដ្រូម)

**វិធី និងសកម្មភាពបង្រៀន** : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្តែងតួ បង្ហាញវីដេអូ ករណីសិក្សា រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងពីការសិក្សា** : **ចំណេះដឹង**

សិក្ខាកាមប្រាប់បានពីនិយមន័យ Down Syndrome (ដោនស៊ីនដ្រូម)

: **បំណិនសម្បទា**

- សិក្ខាកាមដែលជាគ្រូ ប្រាប់បានថា ក្នុងថ្នាក់របស់គាត់ មានកុមារប្រហែល ..........នាក់ មានពិការ Down Syndrome (ដោនស៊ីនដ្រូម)
- សិក្ខាកាមប្រាប់ឧទាហរណ៍ អំពីលក្ខណៈសម្គាល់របស់កុមារពិការ Down Syndrome

: **ចរិយាសម្បទា**

- សិក្ខាកាមប្រើចំណេះដឹង បំណិន និងបទពិសោធន៍ ដែលទទួលបាន ទៅអប់រំណែនាំ ដល់ឪពុកម្តាយដែលមានកូនពិការ Down Syndrome (ដោនស៊ីនដ្រូម) នៅក្នុងសហគមន៍ ឱ្យចេះជួយកុមារប្រភេទនេះ
- ពេលត្រឡប់ទៅវិញ សិក្ខាកាមដែលជាគ្រូ ប្រើបច្ចេកទេស និងសម្ភារបង្រៀន ជួយដល់កុមារ មានបញ្ហា Down Syndrome (ដោនស៊ីនដ្រូម) នៅក្នុងថ្នាក់របស់គាត់

**សម្ភារឧបទ្ទេស**

- រូបភាព និងវីដេអូ កុមារផ្សេងៗ ដែលមាន Down Syndrome (ដោនស៊ីនដ្រូម)
- ផ្ទាំងក្រដាសធំ សម្រាប់សរសេរ គូស និងផាត់ពណ៌ផ្សេងៗ
- ហ្វឺតសរសេរ ក្រដាសពណ៌ ស្កុត
- LCD projector, Laptop

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| • សំណួរ ៖<br>– អ្នកធ្លាប់ឃើញកុមារពិការ | **និយមន័យ Down Syndrome** (ដោនស៊ីនដ្រូម)<br>• ក្រូម៉ូសូម ២១ មានភាពខុសប្លែកពីធម្មតា | ១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់កុមារនៅ |

| | | |
|---|---|---|
| Down Syndrome នៅក្នុងថ្នាក់រៀន/ភូមិរបស់អ្នកឬទេ?<br>– ចូរអ្នកគ្រូនិយាយរៀបរាប់ Down Syndrome ។<br>• គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្តារខៀន<br>• គ្រូបង្ហាញចម្លើយដោយឱ្យសិក្ខាកាមអានមេរៀន **ទំព័រ៥០** | • អ្នកដែលមានជំងឺ Down Syndrome មានក្រូម៉ូសូមចំនួន 47 ក្នុងកោសិកានានារបស់ពួកគេ ជំនួសឱ្យការមានក្រូម៉ូសូមចំនួន46។ពួកគេមានក្រូម៉ូសូម21លើសចំនួន1ដែលនេះជាមូលហេតុដែលពេលខ្លះគេស្គាល់ Down Syndrome ថាជា trisomy 21 (លក្ខណៈដែលអ្នកជំងឺមានក្រូម៉ូសូមចំនួន3ជំនួសឱ្យ1គូ)ដែរ។ | ក្នុងថ្នាក់ និងភូមិរបស់ខ្លួន<br>២. សំយោគនិយមន័យរបស់ពិការ **Down Syndrome** (ដោនស៊ីនដ្រូម)<br>៣. តំណាងក្រុមរាយការណ៍លទ្ធផលពិភាក្សា<br>៤. សិស្សអានមេរៀន **ទំព័រ៥០** |
| • ចាក់វីដេអូដើម្បីឱ្យសិក្ខាកាមសង្កេតកុមារ Down Syndrome<br>*<u>សំណួរមុនទស្សនាវីដេអូ</u>*<br>ចូរកំណត់ឱ្យបានយ៉ាងតិច៣ចំណុចរបស់កុមារក្នុងវីដេអូ អំពី:<br>– សរីរាង្គខាងក្រៅ ដូចជា មុខ ក្បាល ក អណ្តាត ភ្នែក<br>– សកម្មភាព និងអាកប្បកិរិយា<br>– សមត្ថភាពខួរក្បាល<br>• ចែកសិក្ខាកាមជាក្រុម៤ឬ៥នាក់<br>▪ នាំសិក្ខាកាមមើល ស្តាប់ និងកត់ត្រា ដើម្បីឆ្លើយសំណួរ<br>▪ ពិភាក្សា និងឯកភាពក្នុងក្រុម<br>▪ រាយការណ៍លទ្ធផល<br>• នាំសិក្ខាកាមអានអត្ថបទ ដើម្បីផ្ទៀង | **លក្ខណសម្គាល់**<br>• មុខរាបស្មើ<br>• ក្បាលតូច<br>• កខ្លី<br>• អណ្តាតលៀន<br>• ត្របកភ្នែកខើចឡើងលើ (ជំរៅប្រេះត្របកភ្នែក) [Upward slanting eye lids (palpebral fissures)]<br>• ត្រចៀកមានរូបរាងខុស ធម្មតា ឬតូច<br>• សាច់ដុំខ្សោយ<br>• ដៃខ្លី ធំដោយមានគន្លាក់តែមួយគត់នៅលើប្រអប់ដៃ<br>• ម្រាមដៃខ្លីហើយមានដៃនិងជើងតូចៗ<br>• មានភាពបត់បែនច្រើនហួសប្រមាណ (Excessive flexibility) | <u>ការងារបុគ្គល៖</u><br>▪ មើល ស្តាប់ និងកត់ត្រា អំពីសរីរាង្គក្រៅ សកម្មភាព និងសមត្ថភាពខួរក្បាល របស់កុមារ មានជម្ងឺ Down Syndrome<br>▪ រាយការណ៍កំណត់ត្រារបស់ខ្លួន ដល់ក្រុមធំ<br><u>ការងារក្រុម៖</u><br>១. អានមេរៀន ត្រង់ចំណុច ពិការ Down Syndrome<br><br>២. រាយការណ៍លទ្ធផលកិច្ចការតាមក្រុម<br>៣. សួរសំណួរ ទៅគ្រូសម្របសម្រួល |

| | | |
|---|---|---|
| ផ្ទាត់ចម្លើយ | • កន្ទួលពណ៌សតូចៗនៅក្នុងភ្នែក (ប្រស្រីភ្នែក) ដែលគេហៅថាកន្ទួល Brushfield [Tiny white spots on the colored part (iris) of the eye called Brushfield's spots]<br>• កម្ពស់ទាប<br>ទារកដែលមានជំងឺ Down Syndrome អាចមានទំហំខ្លួនធំមធ្យមប៉ុន្តែជាទូទៅពួកគេធំលូតលាស់យឺតហើយនៅ តែមានកម្ពស់ទាបជាងកុមារដទៃទៀតដែលមានអាយុដំណាលគ្នា។ | |
| ពិភាក្សា និងបង្ហាញ<br>▪ អ្នកមានដឹងថា ជំងឺ Down Syndrome កើតឡើងដោយសារមូលហេតុអ្វី?<br>▪ គ្រូសម្របសម្រួលបង្ហាញតាម power point | **មូលហេតុពិការ**<br>• ឪពុកម្ដាយរៀបការ មានអាយុចាស់ពេក<br>• សៃនសេនិច (ក្រូម៉ូសូមទី២១ខុសពីធម្មតា) | ការងារក្រុមតូច<br>• ពិភាក្សាអំពីមូលហេតុដែលនាំឱ្យមានជំងឺ Down Syndrome<br>• ឆ្លើយសំណួរតាមក្រុម តាមផ្ទាំងបទបង្ហាញ<br>• សួរត្រឡប់ទៅអ្នកសម្របសម្រួល |
| • ចែកក្រុម៤ឬ៥នាក់<br>• ពិភាក្សា ព្យុះគំនិត<br>– តើគេគួរធ្វើដូចម្តេចខ្លះ ដើម្បីបង្ការពីពិការ Down Syndrome?<br>• សម្របសម្រួលលទ្ធផលតាមក្រុម<br>• បង្ហាញចម្លើយ | **ការការពារពិការភាព**<br>• កុំយកកូននៅពេលលើសពី៣៥ ពិសេសស្ត្រី<br>• បើមានគភ៌ត្រូវតេសស្វែង Down Syndrome នៅពេល គភ៌បាន៣ខែ | <u>ការងារក្រុម៖</u><br>– ផ្អែកលើចំណេះដឹងដែលមានស្រាប់ គិតអំពីវិធីដែលអាច បង្ការកុំឱ្យមានពិការ Down Syndrome<br>– សរសេរចម្លើយលើក្រដាសតាមក្រុម រួចបញ្ជូនទៅក្រុមជាប់គ្នា ដើម្បីប្រៀបធៀប រកចម្លើយដូចគ្នា<br>– រាយការណ៍ចម្លើយ |

| | | |
|---|---|---|
| | | អានអត្ថបទអំពី ការការពារ បញ្ចៀសពីពិការ Down Syndrome ។ |

# គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

## មេរៀនទី៣៖ **ការលំបាកក្នុងការសិក្សាមុខវិជ្ជា** សម្រាប់រយៈពេល ៥៥នាទី

| ខ្លឹមសារសំខាន់ៗ Key Content of the Topic | វិធីសាស្រ្ត និងសកម្មភាពបង្រៀន Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន Training/Teaching Materials | រយៈពេលបង្រៀន Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា Expected Learning outcomes from the training/teaching |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| និយមន័យ<br>លំបាកក្នុងការសិក្សាមុខវិជ្ជា | • សំណួរ ៖<br>– នៅក្នុងថ្នាក់របស់អ្នកគ្រូ មានសិស្សប៉ុន្មាននាក់ ដែលពិបាកសិក្សាមុខវិជ្ជា ?<br>– ចូរអ្នកគ្រូឱ្យនិយមន័យ ពិបាកសិក្សាមុខវិជ្ជា។<br>• កត់ចម្លើយនៅលើក្តារខៀន<br>• គ្រូបង្ហាញចម្លើយដោយឱ្យសិស្សអានអត្ថបទ | Power point ដែលមានសំណួរ ហ្វ៊ីតសរសេរ ក្រដាសផ្ទាំងធំ | ៥នាទី | សិក្ខាកាមយល់ដឹងអំពីលំបាកក្នុងការសិក្សាមុខវិជ្ជា និងសេចក្តីត្រូវការរបស់ពិការភាព |
| លក្ខណៈសម្គាល់ និងប្រភេទលំបាកក្នុងការសិក្សាមុខវិជ្ជា | • បែងចែកសិក្ខាកាមជាក្រុម<br>• សិក្សាសំណួរ<br>• សង្កេតវីដេអូ ឬ ករណីសិក្សា<br>• ពិភាក្សាក្រុម និងកត់ត្រា<br>• ការបង្ហាញតាមក្រុម<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយ | ក្រដាសផ្ទាំងធំ ហ្វ៊ីត | ៤០នាទី | សិក្ខាកាមអាចប្រាប់បានថា នៅក្នុងថ្នាក់របស់គាត់ អាចមាន/មិនមានកុមារលំបាកក្នុងការសិក្សាមុខវិជ្ជា |
| ៣. មូលហេតុនៃការលំបាកក្នុងការសិក្សាមុខវិជ្ជា | • ពិភាក្សាក្រុម (គ្រូសម្របសម្រួលបែងចែកសិក្ខាកាមជា ៤ ឬ ៥ក្រុម) ពិភាក្សា និងកត់ត្រាលើផ្ទាំងក្រដាសធំ<br>• ការបង្ហាញតាមក្រុម<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយ | Power point LCD | ១០នាទី | សិក្ខាកាមអាចប្រាប់អំពីមូលហេតុនៃការពិបាកក្នុងការសិក្សាមុខវិជ្ជា |

# **កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល** (សម្រាប់តែជំហានទី៣)

**ចំណងជើងខ្លឹមសារមេរៀន** : **ការលំបាកក្នុងការសិក្សាមុខជំនាញ**

**វិធី និងសកម្មភាពបង្រៀន** : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្ដែងតួ ករណីសិក្សា បង្ហាញវីដេអូ រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងពីការសិក្សា** : **ចំណេះដឹង**

សិក្ខាកាមប្រាប់បានពីនិយមន័យ លំបាកក្នុងការសិក្សាមុខវិជ្ជា

| | |
|---|---|
| | **: បំណិនសម្បទា**<br>- សិក្ខាកាមដែលជាគ្រូ ប្រាប់បានថា ក្នុងថ្នាក់របស់គាត់ មានកុមារប្រហែល..........នាក់លំបាកក្នុងការសិក្សាមុខវិជ្ជា<br>- សិក្ខាកាមប្រាប់ឧទាហរណ៍ អំពីលក្ខណ:សម្គាល់របស់កុមារលំបាកក្នុងការសិក្សាមុខវិជ្ជា |
| | **: ចរិយាសម្បទា**<br>- ពេលត្រឡប់ទៅវិញ សិក្ខាកាមដែលជាគ្រូ ប្រើបច្ចេកទេស និងសម្ភារបង្រៀន ជួយដល់កុមារលំបាកក្នុងការសិក្សា នៅក្នុងថ្នាក់របស់គាត់ បានជោគជ័យគ្រប់គ្នា |
| **សម្ភារឧបទេ្ទស** | - រូបភាព និងវីដេអូ កុមារផ្សេងៗ ដែលមានការលំបាកក្នុងការសិក្សាមុខវិជ្ជា<br>- ក្រដាសផ្ទាំងធំ សម្រាប់សរសេរ គូស និងផាត់ពណ៌ផ្សេងៗ<br>- ហ្វឺតសរសេរ ក្រដាសពណ៌ ស្កុត<br>- LCD projector, Laptop |

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer´s Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees´ activities |
|---|---|---|
| • សំណួ ៖<br>– អ្នកធ្លាប់ឃើញកុមារលំបាកក្នុងការសិក្សាមុខវិជ្ជានៅក្នុងថ្នាក់រៀនរបស់អ្នកឬទេ ? បើ | **និយមន័យ៖**<br>**ការលំបាកក្នុងការសិក្សាមុខវិជ្ជា**<br>គឺជាបញ្ហាមួយផ្នែកនៃប្រព័ន្ធប្រសាទរបស់មនុស្ស។ បញ្ហានេះកើតឡើង ដោយសារតែ ប្រព័ន្ធខួរក្បាលរបស់មនុស្សម្នាក់«បានចងភ្ជាប់ | <u>ការងារក្រុម៖</u><br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់កុមារនៅក្នុងថ្នាក់ និងភូមិរបស់ខ្លួន<br>២. សំយោគនិយមន័យរបស់ |

| | | |
|---|---|---|
| សិនជាមាន ប៉ុន្មាននាក់?<br>– ចូរអ្នកគ្រូឱ្យនិយមន័យការលំបាកក្នុងការសិក្សាមុខវិជ្ជា<br>• គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្ដារខៀន<br>• គ្រូបង្ហាញចម្លើយដោយឱ្យសិក្ខាកាមអានមេរៀន | គ្នា» ដែលខុសប្លែក ពីមនុស្សម្នាក់ទៀត។<br>កុមារ អាចឆ្លាតដូចមិត្តភក្តិរបស់គេ ឬអាចឆ្លាតជាងមិត្តភក្តិរបស់គេទៀតផង។ ពួកគេអាចមានការលំបាកក្នុងការអាន សរសេរ ប្រកបពន្យល់ហេតុផល រំឭកឡើងវិញ ឬរៀបចំព័ត៌មានសម្រាប់បង្ហាញប្រសិនបើឱ្យពួកគេធ្វើកិច្ចការដោយខ្លួនឯង ឬប្រសិនបើគ្រូបង្រៀនពួកគេតាមរបៀបបុរាណ។ | លំបាកក្នុងការសិក្សាមុខវិជ្ជា<br>៣. តំណាងក្រុមរាយការណ៍លទ្ធផលពិភាក្សា<br>៤. សិក្ខាកាមអានមេរៀន |
| • ចាក់វីដេអូខ្លី ឬចែកករណីសិក្សាដើម្បីឱ្យសិស្សសង្កេតមើលកុមារលំបាកក្នុងការសិក្សាមុខវិជ្ជា<br>– រៀបចំសិក្ខាកាមជាក្រុម និងផ្ដល់សំណួរ មុនការទស្សនាវីដេអូ៖<br>– តើកុមារលំបាកក្នុងការសិក្សាមានប៉ុន្មានប្រភេទ? អ្វីខ្លះ?<br>– ចូរអ្នករៀបរាប់កុមារលំបាកក្នុងការអាន និងកុមារលំបាកក្នុងការសរសេរ<br>• ឱ្យក្រុម ឆ្លើយសំណួរអំពីប្រភេទនិងលក្ខណៈសម្គាល់<br>• បង្ហាញខ្លឹមសារមេរៀន (បញ្ចាំងស្លាយ ឬផ្ទាំង | **លក្ខណសម្គាល់/ការលំបាកក្នុងការសិក្សាមុខវិជ្ជា**<br>***ប្រភេទ និងលក្ខណៈសម្គាល់៖***<br>**លំបាកអាន**(Dyslexia)៖ គឺជាការលំបាកផ្នែកភាសា ដែលមនុស្សម្នាក់ពិបាកយល់ពាក្យដែលគេសរសេរ។ គេក៏អាចហៅវាថា ជាការលំបាកក្នុងការអាន ឬវិបត្តិក្នុងការអាន។<br>**លំបាកគណនា**(Dyscalculia)៖ គឺជាការលំបាកផ្នែកគណិតវិទ្យា ដែលមនុស្សម្នាក់ ជួបប្រទះក្នុងការដោះស្រាយបញ្ហាលេខគណិត និងយល់ពីគោលគំនិតផ្នែកគណិតវិទ្យា។<br>**លំបាកសរសេរ**(Dysgraphia)៖ គឺជាការលំបាកមួយ ដែលមនុស្សម្នាក់មាន ក្នុងការសរសេរឱ្យទៅជាទម្រង់អក្សរ ឬសរសេរអក្សរ នៅកន្លែងដែលគេបានកំណត់។<br>**វិបត្តិក្នុងការស្ដាប់និងមើល**៖ គឺជាវិបត្តិផ្នែកវិញ្ញាណទទួល ដែលមនុស្សម្នាក់មានការលំបាកក្នុងការយល់ ភាសា ទោះបីជាគាត់ស្ដាប់ | <u>ការងារក្រុម៖</u><br>• មើលវីដេអូខ្លី /អានករណីសិក្សា<br>• កត់ត្រាសកម្មភាពកុមារនៅក្នុងវីដេអូ/ករណីសិក្សា<br>• ពិភាក្សា និង កត់ត្រាចំលើយ<br>• ជ្រើសរើសអ្នកបង្ហាញ<br>• អានខ្លឹមសារមេរៀន |

| | | |
|---|---|---|
| ក្រដាសធំ ) | ឮ និងមើលឃើញធម្មតាក៏ដោយ។<br>**ការមិនយល់ភាសាកាយវិការ**( Nonverbal learning disabilities ) ៖ គឺជាវិបត្តិផ្នែកប្រព័ន្ធប្រសាទ ដែលកើតមាននៅខួរក្បាលផ្នែកខាងស្ដាំ និងបណ្ដាលឱ្យមានបញ្ហាផ្សេងៗទាក់ទងនឹងទំហំចក្ខុវិញ្ញាណ ការយល់ដោយអារម្មណ៍ ការរៀបចំ ការថ្លឹងថ្លែង និងដំណើរការតាមមុខងាររបស់សរីរាង្គ។<br>លក្ខណៈសម្គាល់ការ**លំបាកក្នុងការអាន:** Dyslexia<br>▪ តួអក្សរ និងសូរៈ ពិបាកសម្គាល់ និងពិបាកអាន និងឧស្សាហ៍ច្រឡំ ( ច្រឡំតួអក្សរ )<br>▪ **ការស្គាល់សូរ** ( Phonemic awareness )៖ ពិបាកសម្គាល់សូរ ចងចាំសូរ បំបែកសូរ និងផ្សំសូរ<br>▪ **ដំណើរការបង្កើតសូរ នៅក្នុងភាសា** ( Phonological processing )៖<br>▪ **ការយល់ភ្លាមៗ** ( Automaticity )៖ ពិបាកយល់ភ្លាមៗ ក្នុងពេលអាន<br>▪ **ការបំលែងសញ្ញាឱ្យទៅជាអត្ថន័យ** ( Decoding ): ពិបាកយល់ន័យរបស់តួអក្សរ សញ្ញា និងភាសា<br>▪ **វាក្យស័ព្ទ:** ពិបាករៀនវាក្យស័ព្ទថ្មី ដោយសារកត្តាខាងលើ<br>▪ **ប្រកប និងសរសេរ៖** ពិបាក និងប្រើពេលយូរ<br>▪ **ការស្មាន៖** ជាទូទៅប្រើការស្មាន ជំនួសឱ្យការអាន | |

| | | |
|---|---|---|
| | **ការលំបាកក្នុងការសរសេរ**: Dysgraphia<br><br>▪ ប្រើសញ្ញាវណ្ណយុត្តិដោយពុំច្បាស់លាស់ (ឬមិនប្រើតែម្តង)<br>▪ កំហុសអក្ខរាវិរុទ្ធ (ពេលខ្លះពាក្យដូចគ្នា ប្រកបខុសគ្នា) សរសេរបញ្ច្រាសគ្នា ស្រដៀងគ្នា សូរស្រដៀងគ្នា (phonic approximation) បាត់ព្យាង្គ មានកំហុសក្នុងការប្រើបច្ច័យទូទៅនៃពាក្យ។<br>▪ ជាទូទៅអក្សរសរសេរមើលមិនដាច់<br>▪ មិនស៊ីសង្វាក់គ្នា៖ ប្របូកប្របល់គ្នាចំពោះអក្សរពុម្ព និងអក្សរដែលគេសរសេរជាប់គ្នា  អក្សរធំ និងតូច ឬមិនទៀងទាត់ចំពោះទំហំ  រាង និងទីតាំងទ្រេតរបស់អក្សរ។<br>▪ សរសេរពាក្យ ឬអក្សរមិនបានចប់ចុងចប់ដើម  បាត់ពាក្យ។<br>▪ ពុំស៊ីសង្វាក់គ្នាចំពោះទីតាំងនៅលើទំព័រតាមបន្ទាត់ និងរឹមទំព័រ ព្រមទាំងពុំស៊ីសង្វាក់គ្នាចំពោះចន្លោះរវាងពាក្យ និងអក្សរនានា។ | |
| • បែងចែក ៤ ឬ ៥ក្រុម<br>• ដាក់សំណួរ<br>– តើការលំបាកក្នុងការសិក្សាមុខវិជ្ជា បណ្តាលមកពីមូលហេតុអ្វីខ្លះ?<br>• បង្ហាញចម្លើយ | **មូលហេតុ**<br>• ភាគច្រើនមិនដឹងច្បាស់មូលហេតុ<br>• ក្រុមអ្នកសាវជ្រាវខ្លះ ថាមកពីជាប់ទាក់ទង នឹងផ្នែកផ្សេងៗនៃខួរក្បាល ផ្នែកភាសា<br>• ការប៉ះទង្គិចខួរក្បាលដែលបណ្តាលឱ្យបាត់បង់ការចងចាំ<br>• កត្តាខាងក្រៅដូចជា ឱសថ គ្រឿងស្រវឹង បរិស្ថានរស់នៅ អាហារូបត្ថម្ភ ...។ | <u>ការងារក្រុម៖</u><br>• អានអត្ថបទ<br>• សង្ខេបខ្លឹមសារ<br>• រាយការណ៍ចម្លើយ<br>• ប្រកួតចម្លើយជាមួយក្រុមដទៃ |

# គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

## មេរៀនទី៣៖ និយមន័យរបស់អូទីស៊ឹម   សម្រាប់រយៈពេល ១ម៉ោង

| ខ្លឹមសារសំខាន់ៗ<br>Key Content of the Topic | វិធីសាស្ត្រ និងសកម្មភាពបង្រៀន<br>Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន<br>Training/Teaching Materials | រយៈពេលបង្រៀន<br>Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា<br>Expected Learning outcomes from the training/teaching |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១. និយមន័យពិការអូទីសឹម | សំណួរៈ អ្នកធ្លាប់ឃើញកុមារពិការសតិបញ្ញានៅក្នុងថ្នាក់រៀនរបស់អ្នកឬទេ? ចូរអ្នកគ្រូឱ្យនិយមន័យពិការសតិបញ្ញា និងអូទីសឹម។ គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្តារខៀន គ្រូសម្របសម្រួលបង្ហាញចម្លើយដោយឱ្យសិក្ខាកាមអានមេរៀន។ | Power point ដែលមានសំណួរ ហ្វឺតសរសេរ ក្រដាសផ្ទាំងធំ | ១០នាទី | សិក្ខាកាមយល់ដឹង អំពីពិការអូទីសឹម ដែលមាននៅក្នុងប្រទេស និងនៅតំបន់របស់គាត់ |
| ២. លក្ខណៈសម្គាល់កុមារពិការអូទីសឹម | ▪ បែងចែកសិក្ខាកាមជាក្រុម<br>▪ សិក្សាសំណួរ<br>▪ សង្កេតវីដេអូ ឬ ករណីសិក្សា<br>▪ ពិភាក្សាក្រុម និងកត់ត្រា<br>▪ ការបង្ហាញតាមក្រុម<br>▪ គ្រូសម្របសម្រួលបង្ហាញចម្លើយ | ក្រដាសផ្ទាំងធំ ហ្វឺត | ២៥នាទី | គ្រូអាចប្រាប់បានថា នៅក្នុងថ្នាក់របស់គាត់ អាចមាន/មិនមានកុមារអូទីសឹម |
| ៣. មូលហេតុពិការអូទីសឹម | គ្រូសម្របសម្រួលបង្ហាញតាម Power point | Power point<br>LCD | ២៥នាទី | សិក្ខាកាមអាចប្រាប់អំពីមូលហេតុពិការអូទីសឹម |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**ចំណងជើងខ្លឹមសារមេរៀន** : **និយមន័យរបស់អូទីសឹម**

**វិធី និងសកម្មភាពបង្រៀន** : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្តែងតួ បង្ហាញវីដេអូ ករណីសិក្សា រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងពីការសិក្សា** : **ចំណេះដឹង**

សិក្ខាកាមប្រាប់បានពីនិយមន័យ របស់អូទីសឹម

: **បំណិនសម្បទា**

- សិក្ខាកាមដែលជាគ្រូ ប្រាប់បានថា ក្នុងថ្នាក់របស់គាត់ មានកុមារអូទីសឹម ប្រហែល ......នាក់
- សិក្ខាកាមប្រាប់ឧទាហរណ៍ អំពីលក្ខណ:សម្គាល់របស់កុមារអូទីសឹម

: **ចរិយាសម្បទា**

- សិក្ខាកាមប្រើចំណេះដឹង បំណិន និងបទពិសោធន៍ ដែលទទួលបាន ទៅអប់រំណែនាំ ដល់ឪពុកម្តាយដែលមានកូនអូទីសឹម នៅក្នុងសហគមន៍ ឱ្យចេះជួយកុមារដែលមានអូទីសឹម

**សម្ភារឧបទេ្ទស** :

- រូបភាព និងវីដេអូ កុមារផ្សេងៗ ដែលមានបញ្ហាអូទីសឹម
- ក្រដាសផ្ទាំងធំ សម្រាប់សរសេរ គូស និងផាត់ពណ៌ផ្សេងៗ
- ហ្វឺតសរសេរ
- ក្រដាសពណ៌ ស្កុត
- LCD projector
- Laptop

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| សំណួរ ៖<br>• អ្នកធ្លាប់ឃើញកុមារអូទីសឹមនៅក្នុងថ្នាក់រៀនរបស់អ្នកឬទេ? | **១. និយមន័យ ពិការអូទីសឹម**<br>• មានពិបាកក្នុងជំនាញយល់ដឹងភាសា<br>• មានពិបាកក្នុងជំនាញសង្គម និងការផ្លាស់ប្តូរ | ការងារក្រុម៤ឬ៥នាក់៖<br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់កុមារនៅក្នុងថ្នាក់ និងភូមិរបស់ខ្លួន |

| | | |
|---|---|---|
| • ចូរអ្នកគ្រូឱ្យនិយមន័យពិការអូទីសឹម<br>• គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្តារខៀន<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយដោយឱ្យសិស្សអានមេរៀន | អាកប្បកិរិយាច្រើន<br>• មានភាពសកម្មពេក ឬ អសកម្មពេក | ២. សំយោគនិយមន័យរបស់ពិការអូទីសឹម<br>៣. តំណាងក្រុមរាយការណ៍លទ្ធផលពិភាក្សា<br>៤. អានមេរៀនទំព័រទី៤៤និង៤៥ |
| ១. ចាក់បង្ហាញវីដេអូ កុមារអូទីសឹម<br>*សំណួរមុនទស្សនាវីដេអូ*<br>ចូរកំណត់ឱ្យបានយ៉ាងតិច៣ចំណុច របស់កុមារក្នុងវីដេអូ អំពី:<br>▪ ការប្រើប្រាស់ភាសានិងការទំនាក់ទំនង<br>▪ ការយល់ដឹង និង អាកប្បកិរិយាក្នុងការរស់នៅ<br>▪ ភាពសកម្ម<br><br>២. ចែកសិក្ខាកាមជាក្រុម៤ឬ៥នាក់<br>▪ គ្រូសម្របសម្រួល បែងចែក សិក្ខាកាមជា៣ក្រុមតូចៗ<br>▪ នាំសិក្ខាកាមធ្វើការងារក្រុម<br>▪ នាំសិក្ខាកាមរាយការណ៍ លក្ខណៈសម្គាល់ពិការអូទីសឹម<br>▪ បំភ្លឺសំណួររបស់សិក្ខាកាម<br>▪ បង្ហាញដល់សិក្ខាកាម | **២. លក្ខណៈសម្គាល់របស់ ពិការអូទីសឹម៖**<br>• ពុំមានការស្រែក ឬ និយាយដូចក្មេងធម្មតានៅត្រឹមអាយុ12ខែ<br>• ពុំអាចនិយាយ/បានមួយម៉ាត់នៅអាយុ16ខែ ឬឃ្លាដែលមាន2ពាក្យនៅអាយុនៅ24ខែ<br>• មិនឆ្លើយតបទៅនឹងការហៅឈ្មោះនៅអាយុ1ឆ្នាំ<br>• ការបាត់បង់យ៉ាងឆាប់រហ័សនូវភាសាដែលទទួលបាន ឬបំណិនផ្នែកសង្គម<br>• មានទំនាក់ទំនងដោយប្រើក្រសែភ្នែកខ្សោយ<br>• តម្រៀបជាជួរ ឬរៀបចំរបស់ក្មេងលេង ឬវត្ថុផ្សេងទៀតច្រើនហួសហេតុ។<br>• មិនញញឹមតបវិញទេនៅពេលដែលគេញញឹមដាក់<br>• សមត្ថភាពថយចុះក្នុងការរាប់អាន និងរក្សាមិត្តភាព<br>• ពិបាកក្នុងការសន្ទនាធម្មតាជាមួយអ្នកផ្សេង | <u>ការងារបុគ្គល៖</u><br>▪ មើល ស្តាប់ និងកត់ត្រា ទៅលើ ការប្រើប្រាស់ភាសា អាកប្បកិរិយា និងការងាររបស់កុមារនៅក្នុងវីដេអូ<br>▪ រាយការណ៍កំណត់ត្រារបស់ខ្លួន ដល់ក្រុមរបស់ខ្លួន<br><br><u>ការងារក្រុម៖</u><br>១. អានមេរៀនទី៣ ត្រង់ចំណុច ពិការអូទីសឹមទៅតាមក្រុម ដែល៖<br>▪ ពីរក្រុមស្វែងរកលក្ខណៈសម្គាល់ទៅលើភាសា និងទនាក់ទំនងសង្គម<br>▪ ពីរក្រុមស្វែងរកលក្ខណៈសម្គាល់ទៅលើ អាកប្បកិរិយា<br>▪ ពីរក្រុមស្វែងរកលក្ខណៈសម្គាល់ទៅលើ ការងាររបស់កុមារ |

| | | |
|---|---|---|
| | ទៀត<br>• ពុំចេះលេងតាមរបៀបធ្វើពុត(ធ្វើត្រាប់) និងការលេងរបៀបស្រមើស្រមៃទាក់ទងនឹងសង្គម (ឧទាហរណ៍ ការលេងធ្វើជាផ្ទះ ធ្វើជាវេជ្ជបណ្ឌិត)<br>• ប្រើប្រាស់ភាសាដដែលៗ ឬខុសពីធម្មតា<br>• មានការចាប់អារម្មណ៍តិចចំពោះអ្វីមួយដែលធំទូលាយ ហួសហេតុ (Narrow patterns of interest that are excessive)<br>• ផ្តោតអារម្មណ៍តែរឿងអ្វីមួយឬវត្ថុជាក់លាក់ច្រើនហួសហេតុ<br>• រឹងរូសហួសហេតុពេកក្នុងការផ្លាស់ប្តូរនូវកិច្ចការប្រចាំថ្ងៃ | ២. រាយការណ៍លទ្ធផលកិច្ចការតាមក្រុម<br>៣. សួរសំណួរ ទៅគ្រូសម្របសម្រួល |
| ពិភាក្សា និងបង្ហាញ<br>▪ អ្នកមានដឹងថា អូទីសឹមកើតឡើងដោយសារ មូលហេតុអ្វី?<br>▪ គ្រូសម្របសម្រួលបង្ហាញតាម power point | **៣. មូលហេតុរបស់អូទីសឹម**<br>• មិនមានមូលហេតច្បាស់លាស់<br>• ដោយមានកំរិតសារធាតុគីមីដែលបញ្ជូនរំញោចសរសៃប្រសាទពីកោសិកាមិនគ្រប់គ្រាន់ក្នុងខួរក្បាល | ការងារក្រុមតូច<br>• ពិភាក្សាអំពីមូលហេតុដែលនាំឱ្យមានអូទីសឹម<br>• ឆ្លើយសំណួរតាមក្រុម<br>• តាមមជ្ឈដ្ឋានបទបង្ហាញ<br>• សួរត្រឡប់ទៅអ្នកសម្របសម្រួល |

# គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

## មេរៀនទី៤៖ ពិការចលករខួរក្បាល សម្រាប់រយៈពេល ៥៥នាទី

| ខ្លឹមសារសំខាន់ៗ<br>Key Content of the Topic | វិធីសាស្ត្រ និងសកម្មភាពបង្រៀន<br>Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន<br>Training/Teaching Materials | រយៈពេលបង្រៀន<br>Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា<br>Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| និយមន័យ | • សំណួរ ៖ | | | |

| | | | | |
|---|---|---|---|---|
| ពិការចលករខួរក្បាល | – អ្នកធ្លាប់ឃើញកុមារពិការចលករខួរក្បាលនៅក្នុងថ្នាក់រៀន/ភូមិរបស់អ្នកឬទេ?<br>– ចូរអ្នកគ្រូឱ្យនិយមន័ពិការចលករខួរក្បាល។<br>• កត់ចម្លើយនៅលើក្តារខៀន<br>• គ្រូបង្ហាញចម្លើយដោយឱ្យសិក្ខាកាមអានមេរៀន**ទំព័រទី៥៩** | Power point ដែលមានសំណួរ ហ្វឺតសរសេរ ក្រដាសផ្ទាំងធំ | ៥នាទី | សិក្ខាកាមយល់ដឹងអំពីពិការចលករខួរក្បាល |
| លក្ខណៈសម្គាល់ ពិការចលករខួរក្បាល | • ចាក់វីដេអូដើម្បីឱ្យសិក្ខាកាមសង្កេតកុមារពិការចលករខួរក្បាល<br>• គ្រូសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តាខៀន/ ក្រដាសផ្ទាំងធំ<br>• សិក្ខាកាមអានអត្ថបទ **ទំព័រទី៥៩** | វីដេអូខ្លី ក្រដាសផ្ទាំងធំ ហ្វឺត | ១០នាទី | សិក្ខាកាមអាចកំណត់សម្គាល់ពិការចលករខួរក្បាល តាមប្រភេទផ្សេងៗគ្នា នៃកុមារពិការចលករខួរក្បាលតាមកម្រិតពិការភាព។ |
| មូលហេតុពិការចលករខួរក្បាល | • ពិភាក្សាក្រុម (គ្រូសម្របសម្រួល បែងចែកសិក្ខាកាមជា ៤ ឬ ៥ក្រុម) ពិភាក្សា និងកត់ត្រាលើក្រដាសផ្ទាំងធំ<br>• ការបង្ហាញតាមក្រុម<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយ | ក្រដាសផ្ទាំងធំ ហ្វឺត | ២០នាទី | សិក្ខាកាមអាចប្រាប់អំពីមូលហេតុពិការចលករខួរក្បាល យ៉ាងតិច៣ចំណុចសំខាន់ៗ |
| ការការពារពិការភាព | • ពិភាក្សាក្រុម (គ្រូសម្របសម្រួល បែងចែក | ក្រដាសផ្ទាំងធំ | ២០នាទី | សិក្ខាកាមអាចប្រាប់អំពីវិធិ |

| | | | | |
|---|---|---|---|---|
| | សិក្ខាកាមជា ៤ ឬ ៥ក្រុម) ពិភាក្សា និងកត់ត្រាលើក្រដាសផ្ទាំងធំ<br>• ការបង្ហាញតាមក្រុម<br>• គ្រូសម្របសម្រួលបង្ហាញចម្លើយ<br>• ឱ្យសិក្ខាកាមអានអត្ថបទ | ហ្វឹត | | ការពារពិការភាពមុនកំណើត កំឡុងពេលកំណើត និងក្រោយពេលកំណើត ទៅឳពុកម្តាយ និងចូលរួមកាត់បន្ថយពិការភាពក្នុងសង្គម |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**ចំណងជើងខ្លឹមសារមេរៀន** : **ពិការចលករខួរក្បាល**

**វិធី និងសកម្មភាពបង្រៀន** : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្តែងតួ បង្ហាញវីដេអូ ករណីសិក្សា រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងពីការសិក្សា** : **ចំណេះដឹង**:

សិក្ខាកាមប្រាប់បានពីនិយមន័យ ពិការចលករខួរក្បាល

: **បំណិនសម្បទា**:

- សិក្ខាកាមដែលជាគ្រូ ប្រាប់បានថា ក្នុងថ្នាក់របស់គាត់ មានកុមារប្រហែល ..........នាក់ មានពិការចលករខួរក្បាល
- សិក្ខាកាមប្រាប់ឧទាហរណ៍ អំពីលក្ខណ:សម្គាល់របស់កុមារពិការចលករខួរក្បាល

: **ចរិយាសម្បទា**:

- សិក្ខាកាមប្រើចំណេះដឹង បំណិន និងបទពិសោធន៍ ដែលទទួលបាន ទៅអប់រំណែនាំ ដល់ឪពុកម្តាយដែលមានកូនពិការចលករខួរក្បាល នៅក្នុងសហគមន៍ ឱ្យចេះជួយកុមារប្រភេទនេះ
- ពេលត្រឡប់ទៅវិញ សិក្ខាកាមដែលជាគ្រូ ប្រើបច្ចេកទេស និងសម្ភារបង្រៀន ជួយដល់កុមារ មានបញ្ហាចលករខួរក្បាល នៅក្នុងថ្នាក់របស់គាត់

**សម្ភារឧបទេ្ទស**

- រូបភាព និងវីដេអូ កុមារផ្សេងៗ ដែលមានបញ្ហាចលករខួរក្បាល
- ក្រដាសផ្ទាំងធំ សម្រាប់សរសេរ គូស និងផាត់ពណ៌ផ្សេងៗ
- ហ្វឺតសរសេរ ក្រដាសពណ៌ ស្កុត
- LCD projector, Laptop

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| • សំណួរ ៖<br>– អ្នកធ្លាប់ឃើញកុមារពិការចលករខួរក្បាលនៅក្នុងថ្នាក់រៀនរបស់អ្នកឬទេ ?<br>– ចូរអ្នកគ្រូឱ្យនិយមន័យពិការចលករខួរក្បាល។ | **និយមន័យ**<br>• បញ្ហានៃប្រព័ន្ធប្រសាទដែលកើតឡើងលើទារកឬកុមារតូចៗហើយប៉ះពាល់ជាអចិន្ត្រៃទៅលើចលនារបស់រាងកាយ<br>• ការបាត់បង់ឬការលំបាកផ្នែកសម្បទាចលនា( motor function )។ជំងឺពិការចលករខួរក្បាលប៉ះពាល់ដល់ | <u>ការងារក្រុម៖</u><br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់កុមារនៅក្នុងថ្នាក់ និងភូមិរបស់ខ្លួន<br>២. សំយោគនិយមន័យរបស់ ពិការចលករខួរក្បាល<br>៣. តំណាងក្រុមរាយការណ៍លទ្ធផលពិភាក្សា |

| | | |
|---|---|---|
| • គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្ដារខៀន<br>• គ្រូបង្ហាញចម្លើយដោយឱ្យសិស្សអានមេរៀន | ផ្នែកចលនា(motor area)នៃស្រទាប់ខាងក្រៅរបស់ខួរក្បាល<br>• អាចកើតឡើងមុនពេលអាយុ៦ឆ្នាំ | ៤. សិក្ខាកាមអានមេរៀន**ទំព័រទី៥៩** |
| • ចាក់វីដេអូខ្លី ឬចែកករណីសិក្សា ដើម្បីឱ្យសិស្សសង្កេតកុមារពិការចលករខួរក្បាល<br>– រៀបចំសិក្ខាកាមជាក្រុម និងផ្ដល់សំណួរ មុនការទស្សនាវីដេអូ៖<br>– តើកុមារពិការចលករខួរក្បាលមានខុសប្លែកពីប្រភេទពិការផ្សេងៗដែលអ្នកបានសិក្សារួច នៅលើផ្នែកអ្វីខ្លះ?<br>– ចូរអ្នកកត់សម្គាល់ទៅលើការបញ្ហាសាច់ដុំ ការនិយាយ ការដើរ ឈរ អង្គុយ និងការបរិភោគអាហារ<br>• ឱ្យក្រុម ឆ្លើយសំណួរអំពី លក្ខណៈសម្គាល់ពិការចលករខួរក្បាល<br>• បង្ហាញខ្លឹមសារមេរៀន (បញ្ចាំងស្លាយ ឬ ក្រដាសផ្ទាំងធំ) | **លក្ខណសម្គាល់ ពិការចលករខួរក្បាល**<br>• ខ្វះការសម្របសម្រួលផ្នែកចលនាសាច់ដុំនៅពេលធ្វើចលនាដោយសេរី (រោគឃើតសរសៃ[ataxia])<br>• សាច់ដុំរឹង ឬតឹង និងកន្ត្រាក់/ញាក់ដោយមិនដឹងខ្លួន (សាច់ដុំរឹង[spasticity]);<br>• ភាពទន់ខ្សោយនៅដៃ ឬជើងមួយចំហៀង ឬទាំងពីរ។<br>• ដើរនៅលើម្រាមជើង ដើរឱនៗ(ទ្រីមទ្រោមៗ)ឬដើររបៀប scissored(«scissored» gait)<br>• ការប្រែប្រួលនៅក្នុង សាច់ដុំ ទាំងរឹងពេកឬ ទន់ពេក<br>• ហៀរទឹកមាត់ច្រើន ពិបាកលេប ឬនិយាយ<br>• ចលនាញ័ររញ្ជួយញ័រកញ្ជាប់ ឬម្តងម្កាល<br>• យឺតយ៉ាវ ក្នុងការបញ្ជាចលនា<br>• លំបាកក្នុងការធ្វើ ចលនា ជាក់លាក់ដូចជាការសរសេរ ឬ បិទឡេវអាវ។ | <u>ការងារក្រុម៖</u><br>• មើលវីដេអូខ្លី /អានករណីសិក្សា<br>• កត់ត្រាសកម្មភាពកុមារនៅក្នុងវីដេអូ/ករណីសិក្សា<br>• ពិភាក្សា និង កត់ត្រាចម្លើយ<br>• ជ្រើសរើសអ្នកបង្ហាញ<br>• អានខ្លឹមសារមេរៀន |
| • បែងចែក ៤ ឬ ៥ក្រុម<br>• ដាក់សំណួរ<br>– តើពិការចលករខួរក្បាលបណ្ដាល | **មូលហេតុពិការចលករខួរក្បាល**<br>• មុនកំណើត<br>• កំឡុងពេលកំណើត | <u>ការងារក្រុម៖</u><br>• អានអត្ថបទ<br>• សង្ខេបខ្លឹមសារ |

| | | |
|---|---|---|
| មកពីមូលហេតុអ្វីខ្លះ ?<br>• បង្ហាញចម្លើយ | • ក្រោយពេលកំណើត | • រាយការណ៍ចម្លើយ<br>• ប្រកួតចម្លើយជាមួយក្រុមដទៃ |
| • ចែកក្រុម៤ឬ៥នាក់<br>• ពិភាក្សា ព្យុះគំនិត<br>– តើគេគួរធ្វើដូចម្តេចខ្លះ ដើម្បីបង្ការពីពិការចលករខួរក្បាល ?<br>• សម្របសម្រួលលទ្ធផលតាមក្រុម<br>• បង្ហាញចម្លើយ | **ការការពារពិការភាព**<br>• មុនកំណើត<br>• កំឡុងពេលកំណើត<br>• ក្រោយពេលកំណើត | <u>ការងារក្រុម៖</u><br>– ផ្តែកលើចំណេះដឹងដែលមានស្រាប់ គិតអំពីវិធីដែលអាច បង្ការកុំឱ្យកុមារមានពិការចលករខួរក្បាល( ចាប់ពីមុនកើត រហូតដល់ពេញវ័យ )<br>– សរសេរចម្លើយលើក្រដាសតាមក្រុម រួចបញ្ជូនទៅក្រុមជាប់គ្នា ដើម្បីប្រៀបធៀប រកចម្លើយដូចគ្នា<br>– រាយការណ៍ចម្លើយ<br>អានអត្ថបទអំពី ការការពារ បញ្ចៀសពីពិការចលករខួរក្បាល។ |

# មេរៀនទី៦

# ផែនការបង្រៀន ឧបករណ៍វាយតម្លៃសម្បទារបស់កុមារ (បឋមសិក្សា: កម្រិត១)

## គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

មេរៀនទី៦៖ **ផែនការបង្រៀន ឧបករណ៍វាយតម្លៃសម្បទារបស់កុមារ** (បឋមសិក្សា: កម្រិត១) សម្រាប់រយៈពេល ៨ម៉ោង

| ខ្លឹមសារសំខាន់ៗ Key Content of the Topic | វិធីសាស្រ្ត និងសកម្មភាពបង្រៀន Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន Training/Teaching Materials | រយៈពេលបង្រៀន Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា Expected Learning outcomes from the training/teaching |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| សកម្មភាពផ្ទាល់ខ្លួនសម្រាប់ការរស់នៅប្រចាំថ្ងៃ | ឧទ្ទេសបង្ហាញ និងបំផុសសំណួរលើអត្ថន័យនីមួយៗ ។<br><br>ធ្វើគំរូបង្ហាញ និងសំដែងតួ ។ | • ក្រដាសផ្ទាំងធំ<br>• LCD Projector<br>• កុំព្យូទ័រ<br>• ស្កុត<br>• ក្រដាសពណ៌<br>• ឯកសារមេរៀន<br>• កន្ត្រៃ ហ្វឺត | ២ម៉ោង | សិក្ខាកាមយល់ អនុវត្តនិងកំណត់បាននូវតម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពផ្ទាល់ខ្លួនសម្រាប់ការរស់នៅប្រចាំថ្ងៃ ។ |
| សកម្មភាពសង្គម | ឧទ្ទេសបង្ហាញ និងបំផុសសំណួរលើអត្ថន័យនីមួយៗ ។<br><br>ធ្វើបង្ហាញ និងសំដែងតួ ។ | • ដាស់ផ្ទាំងធំ<br>• LCD Projector<br>• កុំព្យូទ័រ<br>• ស្កុត ក្រដាសពណ៌<br>• ឯកសារមេរៀន<br>• កន្ត្រៃ ហ្វឺត | ២ម៉ោង | សិក្ខាកាមយល់ អនុវត្តនិងកំណត់បាននូវតម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពសង្គម ។ |
| សកម្មភាពការសិក្សា | ឧទ្ទេសបង្ហាញ និងបំផុសសំណួរលើអត្ថន័យនីមួយៗ ។<br><br>ធ្វើបង្ហាញ និងសំដែងតួ ។ | • ក្រដាសផ្ទាំងធំ<br>• LCD Projector កុំព្យូទ័រ<br>• ស្កុត ក្រដាសពណ៌<br>• ឯកសារមេរៀន<br>• កន្ត្រៃ ហ្វឺត | ២ម៉ោង | សិក្ខាកាមយល់ អនុវត្តនិងកំណត់បាននូវតម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពសិក្សា ។ |

| | | | | |
|---|---|---|---|---|
| សកម្មភាពការងារ | ឧទ្ទេសបង្ហាញ និងបំផុសសំណួរលើអត្ថន័យនីមួយៗ ។<br><br>ធ្វើបង្ហាញ និងសំដែងតួ ។<br><br>ពិភាក្សាក្រុមតូច និងដៃគូ ។ | • ក្រដាសផ្ទាំងធំ<br>• LCD Projector កុំព្យូទ័រ<br>• ស្កុត ក្រដាសពណ៌<br>• ឯកសារមេរៀន<br>• កន្ត្រៃ ហ្វឺត<br>• បណ្ណពាក្យ បណ្ណលេខ<br>• ប្រតិទិន<br>• នាឡិកា<br>• វត្ថុខុសគ្នាចំនួន១០<br>• ក្រដាសប្រាក់រៀល<br>• ក្រដាសប្រាក់ដុល្លា<br>• តារាងឈ្មោះនៃថ្ងៃ<br>• ផ្ទាំងរូបភាពបន្លែ និងផ្លែឈើ | ២ម៉ោង | សិក្ខាកាមយល់ អនុវត្តនិងកំណត់បាននូវតម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពការងារ ។ |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិននិងខ្លឹមសារមេរៀន** ៖ **ឧបករណ៍វាយតម្លៃសកម្មភាពផ្ទាល់ខ្លួនសម្រាប់សកម្មភាពរស់នៅប្រចាំថ្ងៃ**

**វិធី និងសកម្មភាព** ៖ ឧទ្ទេសបង្ហាញ បំផុសសំណួរក្រុមធំ ធ្វើគំរូបង្ហាញ និងសំដែងតួ

**លទ្ធផលរំពឹងពីការសិក្សា** ៖

- **ចំណេះដឹង៖** សិក្ខាកាមយល់ច្បាស់អំពីឧបករណ៍វាយតម្លៃទាក់ទងនឹងសកម្មភាពផ្ទាល់ខ្លួនសម្រាប់ការរស់នៅប្រចាំថ្ងៃ ។
- **បំណិនសម្បទា៖** សិក្ខាកាមអាចរៀបចំឧបករណ៍ និងរៀបចំផែនការ កំណត់តម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពផ្ទាល់ខ្លួនសម្រាប់ការរស់នៅប្រចាំថ្ងៃ ។
- **ចិរយាសម្បទា៖** សិក្ខាកាមផ្លាស់ប្តូរវិធីសាស្ត្របង្រៀនដោយផ្អែកទៅតាមប្រភេទសិស្ស តាមរយៈឧបករណ៍វាយតម្លៃលើសកម្មភាពរស់នៅប្រចាំថ្ងៃ ។

**សម្ភារឧបទេ្ទស** ៖

- ក្រដាសផ្ទាំងធំ
- LCD Projector កុំព្យូទ័រ
- ស្កុត ក្រដាសពណ៌
- ឯកសារមេរៀន
- ហ្វឹត កន្ត្រៃ

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| សួរសំណួរទៅក្រុមធំ៖ តើលោកគ្រូអ្នកគ្រូធ្វើអ្វីខ្លះ ក្នុងសកម្មភាពផ្ទាល់ខ្លួនក្នុងការរស់នៅប្រចាំថ្ងៃ? | ផ្តើមសេចក្តី ដើម្បីចូលមេរៀនថ្មី<br>ឧទាហរណ៍៖<br>-ដាំបាយ និងធ្វើម្ហូប<br>-ធ្វើកិច្ចតែងការបង្រៀន<br>-កែកិច្ចការសិស្ស<br>-ងូតទឹក<br>-ថែទាំកូន... ។ | <u>ការងារក្រុម៤ឬ៥នាក់៖</u><br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់សកម្មភាពរបស់ខ្លួន ប្រចាំថ្ងៃ<br>២.កត់ត្រា<br>៣. រាយការណ៍ |
| ចំណែកឯសិស្សរបស់លោកគ្រូ អ្នកគ្រូវិញតើពួកគេធ្វើអ្វីខ្លះដែរ ទាក់ទងទៅនឹងសកម្មភាពប្រចាំថ្ងៃ? | ឧទាហរណ៍៖<br>-លប់មុខ ដុសធ្មេញ ងូតទឹក និងស្លៀកពាក់<br>-ជួយដាំបាយ និងធ្វើម្ហូប<br>-ឃ្វាលគោ<br>-រែកទឹក<br>-ដាក់បាយជ្រូក<br>-ជួយកិច្ចការផ្ទះមួយចំនួន... | <u>ការងារក្រុម៤ឬ៥នាក់៖</u><br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់សកម្មភាព ប្រចាំថ្ងៃ របស់កុមារនៅក្នុងផ្ទះ និងអ្នកជិតខាង<br>២.កត់ត្រា<br>៣. រាយការណ៍ |
| ធ្វើបទបង្ហាញតាមរយៈ LCD Projector ព្រមទាំងពន្យល់តាមចំណុចម្តងមួយៗដើម្បីឱ្យសិក្ខាកាមយល់អំពីអត្ថន័យ ។ | **បញ្ជីសកម្មភាពផ្ទាល់ខ្លួនសម្រាប់សកម្មភាពរស់នៅប្រចាំថ្ងៃ របស់កុមារ៖** *(សម្រាប់វាយតម្លៃសមត្ថភាពរបស់កុមារ)*<br>1. ដើរដោយខ្លួនឯងចម្ងាយប្រមាណ៣ម៉ែត្រដើម្បីទៅយកវត្ថុអ្វីមួយ។<br>2. ឡើង និងចុះជណ្តើរដោយដាក់ជើងទាំង២នៅលើកាំជណ្តើរនីមួយៗ ដោយពុំមានអ្នកជួយ។<br>3. ចាក់សោបើកទ្វារ/ដកគន្លឹះទ្វារដើម្បីបើកទ្វារនៅពេលគេចង់ចូល/ចេញ | សង្កេត<br>ស្តាប់<br>កត់ត្រា |

| | | |
|---|---|---|
| | ទៅក្រៅបន្ទប់។<br>4. លាងសម្អាតខ្លួនបន្ទាប់ពីបន្ទោរបង់រួច។<br>5. កាច់/ចុចទឹក ឬចាក់ទឹកបង្គន់បន្ទាប់ពីបន្ទោរបង់រួច។<br>6. ស្លៀកសម្លៀកបំពាក់ ដោយរួមទាំងខោ / អាវក្នុង (ប្រហែលជាមិនភ្ជាប់ឡេវ/ទំពក់/ខ្សែរូតទេ)<br>7. ស្លៀកសម្លៀកបំពាក់៖ ក) រូត ខ) កិបឡេវ គ) ដាក់ឡេវ ឃ) ថ្កក់ឡេវ<br>8. ដោះសម្លៀកបំពាក់៖ ក) រូត ខ) ដោះឡេវ<br>9. ញុាំអាហារអស់ដោយខ្លួនឯងដោយពុំមានកំពប់<br>10. សុំ/ចង្អុលម្ហូបអាហារ (ឧ. បាយ និងសម្លរការី នំបញ្ចុក)នៅពេលគេចង់ញុាំថែមទៀត។<br>11. រៀបចំអាហារថ្ងៃត្រង់ និងពេលល្ងាចទាំងនៅលើតុ និងលើកម្រាល។<br>12. ចាក់ទឹកចេញពីកំសៀវ / ត្រងទឹកពីក្បាលរ៉ូបីណេដើម្បីផឹកនៅពេលដែលគេស្រេកទឹក<br>13. យកទឹកឱ្យអ្នកផ្សេងទៀត<br>14. លាងសម្អាតដៃមុនពេលញុាំអាហារសម្រន់ ឬចំណីអាហារផ្សេងៗ ឬបន្ទាប់ពីចេញពីបង្គន់ ឬនៅពេលដែលដៃ កខ្វក់។<br>15. លុបលាងមុខដោយសាប៊ូសម្រាប់លាងសម្អាតមុខ/ សាប៊ូលាងមុខ និងទឹក<br>16. ជូតសម្អាតដៃ និងមុខដោយកន្សែងពោះគោបន្ទាប់ពីលាងសម្អាតហើយ។<br>17. សម្អាតច្រមុះជាមួយនឹងកន្សែងដៃ/ក្រដាសអនាម័យនៅពេលដែលចាំបាច់។ | |

| | | |
|---|---|---|
| | 18. ប្រើប្រាស់សាប៊ូដុះ/សាប៊ូដុសខ្លួនដើម្បីសម្អាតខ្លួននៅពេលងូតទឹក។<br>19. លាបម្សៅ/ លាបឡេនៅលើមុខ។<br>20. សិតសក់ និងចងសក់ដោយប្រើកៅស៊ូកងបន្ទាប់ពីត្រដោះសក់ ដែលជំពាក់រួចហើយ(ក្នុងករណីក្មេងស្រី)។ | |
| ទុកឱកាសឱ្យសិក្ខាកាមសួរបញ្ជាក់ចំពោះចំណុចដែលមិនទាន់ច្បាស់ ។ អ្នកសម្របសម្រួលពន្យល់បន្ថែមនូវរាល់សំណួររបស់សិក្ខាកាម។ | សំណួរបំភ្លឺបន្ថែម | សួរគ្រូសម្របសម្រួលតាមបុគ្គល |
| អ្នកសម្របសម្រួលសំដែងតួក្នុងការអនុវត្តឧបករណ៍វាយតម្លៃទៅលើសកម្មភាពផ្ទាល់ខ្លួនរបស់កុមារនៅក្នុងការរស់នៅប្រចាំថ្ងៃ (សកម្មភាពទី១ ទី២ និង ទី៣)។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>-អ្នកសម្របសម្រួលម្នាក់<br>-កុមារម្នាក់ ដែលសង្ស័យថា មានតម្រូវការពិសេស<br>-អនុវត្តសំណួរខាងលើ ជាមួយសិស្ស | សិក្ខាកាមសង្កេត និងកត់ត្រា |
| បែងចែកសិក្ខាកាមជា៥ក្រុម ហ្វឹកហាត់ រួចសម្តែងតួ តាមក្រុមរៀងៗខ្លួន ។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>ឬ សម្តែងតួតាមក្រុមតូច ក្នុងករណីរកសិស្សមិនបាន<br>-អនុវត្តសំណួរខាងលើ | សិក្ខាកាមសង្កេត និងកត់ត្រា |
| ជ្រើសរើស១ក្រុម ដើម្បីសម្តែងតួ ដល់ក្រុមធំ ដើម្បីឆ្លុះបញ្ចាំង និងកែលម្អ ។ | សម្តែងក្រុមធំ<br>-អនុវត្តសំណួរខាងលើ | សំណួរនិងចម្លើយ |

| | | |
|---|---|---|
| អ្នកសម្របសម្រួលសង្ខេបអំពីឧបករណ៍វាយតម្លៃសកម្មភាពផ្ទាល់ខ្លួនរស់នៅប្រចាំថ្ងៃ ។ | ពង្រឹងពុទ្ធិ | ឆ្លើយតាមក្រុមតូច |

## កច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

### ចំណងជើងនិងខ្លឹមសារមេរៀន ៖ ឧបករណ៍វាយតម្លៃសកម្មភាពសង្គមរបស់កុមារ

**វិធីនិងសកម្មភាពបង្រៀន** ៖

- ឧទ្ទេសបង្ហាញ
- បំផុសសំណួរក្រុមធំ
- ធ្វើគំរូបង្ហាញ
- សំដែងតួ

**លទ្ធផលរំពឹងពីការសិក្សា** ៖

- **ចំណេះដឹង៖** សិក្ខាកាមយល់ច្បាស់អំពីឧបករណ៍វាយតម្លៃទាក់ទងសកម្មភាពសង្គមរបស់កុមារ ។
- **បំណិនសម្បទា៖** សិក្ខាកាមចេះអនុវត្ត និងកំណត់បាននូវតម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពសង្គម ។
- **ចិរយាសម្បទា៖** សិក្ខាកាមផ្លាស់ប្តូរវិធីសាស្ត្របង្រៀនដោយផ្អែកទៅតាមប្រភេទសិស្ស តាមរយៈឧបករណ៍វាយតម្លៃលើសកម្មភាពសង្គម ។

**សម្ភារឧទ្ទេស** ៖

- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត
- កុំព្យូទ័រយួរដៃ (Laptop)
- ម៉ាស៊ីនសម្រាប់បញ្ចាំងមេរៀន (LCD Projector)

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|

| | | |
|---|---|---|
| សួរសំណួរទៅក្រុមធំ៖<br>តើសកម្មភាពប្រចាំថ្ងៃអ្វីខ្លះ ដែលកុមារ មានតម្រូវការពិសេស មិនអាចធ្វើបាន? | រំលឹកអំពី សមត្ថភាពប្រចាំថ្ងៃ ដែលកុមារមានតម្រូវការពិសេសពិបាកធ្វើ<br>(សូមមើលខ្លឹមសារ មេរៀន សម្រាប់ម៉ោងមុន) | ការងារក្រុមធំ៖<br>រៀបរាប់អំពីសកម្មភាពប្រចាំថ្ងៃ របស់កុមារ មានសុខភាពធម្មតា និងកុមារមានតម្រូវការពិសេស |
| បែងចែកសិក្ខាកាមជាក្រុមតូចៗ<br>*សំណួរ:*<br>តើសកម្មភាពសង្គមមានមានន័យដូចម្តេច? | សំណួរដើម្បីផ្សាភ្ជាប់ទៅនឹងប្រធានបទថ្មី<br>សកម្មភាពសង្គមគឺជាសកម្មភាពទាំងឡាយណាដែលមានការទំនាក់ទំនងគ្នារវាងមនុស្សឬវត្ថុចាប់ពីពីរឡើងទៅ។ | ការងារក្រុមតូច៖<br>–ពិភាក្សាក្រុម អំពី សកម្មភាពទាំងឡាយណាដែលមានការទំនាក់ទំនងគ្នា រវាងមនុស្សចាប់ពីពីរឡើងទៅ។<br>–កត់ត្រា និងរាយការណ៍ក្រុមតូច |
| *សំណួរ:*<br><br>តើលោកគ្រូអ្នកគ្រូដឹងថាសិស្ស អាចធ្វើសកម្មភាពសង្គមអ្វីខ្លះ? | សកម្មភាពសង្គមរបស់កុមារ អាចមានដូចជា៖<br>-ទំនាក់ទំនងជាមួយម្តាយ ឪពុក ចាស់ទុំ មិត្តភ័ក្តិ គ្រូបង្រៀន<br>-ទំនាក់ទំនងជាមួយចាស់ទុំ<br>-ទំនាក់ទំនងជាមួយសិស្សដទៃទៀត<br>-ទំនាក់ទំនងជាមួយអ្នកជិតខាង<br>-លេងល្បែងជាក្រុម<br>-ចូលរួមព្រឹត្តិការណ៍សង្គម<br>-ជួយគ្នាក្នុងសង្គម<br>-សម្តែងតរិយាបទសមរម្យ... | <br>ការងារក្រុម៤ឬ៥នាក់៖<br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់សកម្មភាពសង្គម របស់កុមារ<br>២. សំយោគនិងកត់ត្រាតាមក្រុម<br>៣. តំណាងក្រុមរាយការណ៍លទ្ធផលពិភាក្សា<br>៤. អានមេរៀន |
| ធ្វើបទបង្ហាញអំពីឧបករណ៍វាយតម្លៃពីសកម្មភាពរបស់កុមារ ដែលមានទំនាក់ទំនងសង្គម ដោយពន្យល់តាមចំណុចម្តងមួយៗយ៉ាង | **បញ្ជីសកម្មភាពសង្គមរបស់កុមារ៖**<br>(*សម្រាប់វាយតម្លៃសមត្ថភាពរបស់កុមារ*)<br>1. ផ្តល់ឱ្យមានជម្រើសមួយ រវាងសកម្មភាព២ ឬវត្ថុ២។ | សង្កេត និងស្តាប់ |

| | | |
|---|---|---|
| លម្អិតដើម្បីឱ្យសិក្ខាកាមយល់។ | 2. ធ្វើសកម្មភាពទៅតាមការស្នើសុំរបស់គ្រូបង្រៀន និងឪពុកម្តាយ។<br>3. សុំការអនុញ្ញាតដើម្បីលេងតុក្កតា ឬសម្ភារផ្សេងៗដែលមិនមែនជារបស់ខ្លួន។<br>4. ចូលរួមនៅក្នុងការលេងល្បែងជាក្រុមដែលមានកុមារលេងចំនួន៤-៥នាក់។<br>5. រង់ចាំវេនរបស់ខ្លួននៅក្នុងពេលកំពុងលេងល្បែង។<br>6. ចែកសម្ភារគ្នាលេងនៅពេលលេងល្បែងជាក្រុម។<br>7. រក្សានូវឥរិយាបថសមរម្យនៅពេលចូលរួមក្នុងកម្មវិធីសង្គមផ្សេងៗ។<br>8. ថែរក្សាសម្ភារផ្ទាល់ខ្លួនរបស់គាត់នៅសាលារៀន( ឧ.កាបូបដាក់សៀវភៅ ប្រអប់ដាក់អាហារថ្ងៃត្រង់ ប្រអប់ដាក់ ខ្មៅដៃ )។<br>9. ការពារ / ស្វែងរកជំនួយនៅពេលមានរបួសស្នាម ឬមានការរំខានពីអ្នកដទៃទៀត។<br>10. ដឹងថាអ្នកនិយាយកំពុងខឹង ធុញទ្រាន់ ក្រៀមក្រំ រីករាយ ។ល។<br>11. ប្រាប់ឈ្មោះផ្នែកផ្សេងៗរបស់រាងកាយនៅពេលគេចង្អុល។<br>12. ប្រើប្រាស់ពាក្យផ្សំ ឬកាយវិការដើម្បីបញ្ជាក់ពីតម្រូវការ ឬបំណងប្រាថ្នារបស់ខ្លួន។<br>13. ឆ្លើយ( ដោយការនិយាយ / កាយវិការ )នឹងសំណួរផ្សេងៗដូចជា «នេះជារបស់នរណា ?» ដោយកុមារចង្អុលមក ខ្លួនរបស់គាត់ ឬនរណាម្នាក់បានយ៉ាងត្រឹមត្រូវ។<br>14. អនុវត្តតាមការណែនាំ / បញ្ជាចំនួន២ដងបន្តបន្ទាប់គ្នា។<br>15. រៀបរាប់ឈ្មោះសមាជិកគ្រួសារដូចជា បង / ប្អូនប្រុស  បង / ប្អូន | |

| | | |
|---|---|---|
| | ស្រី ម្តាយមីង / ម្តាយធំ ឪពុកធំ / ឪពុកមា។<br>16. ប្រើប្រាស់ឃ្លាដែលមាន២-៣ព្យាង្គដើម្បីប្រាប់ព័ត៌មាន (ប្រសិនបើកាយវិការធ្វើឱ្យខ្លួនយល់ - if non-verbal make self understood by guestures)។<br>17. សុំឱ្យគេជួយ(ជាពាក្យសំដី ឬកាយវិការ)សម្រាប់តម្រូវការផ្ទាល់ខ្លួន។<br>18. ធ្វើតាមសារផ្សេងៗដោយមានអាយតនិបាត(ឈ្នាប់)ផ្សេងៗ ដូចជា នៅខាងក្រោម នៅខាងក្រោយ នៅខាងមុខ (ឧទាហរណ៍ ដាក់កាបូបនៅខាងមុខក្មេងប្រុសនោះ)។<br>19. ប្រើប្រាស់ពាក្យទាក់ទងនឹងយេនឌ័រនៅបានត្រឹមត្រូវនៅពេលគេសួរ។ តើប្អូន (ឬចង្អុលទៅកុមារម្នាក់)ជា កុមារា ឬកុមារី?<br>20. អាចរៀបរាប់ឈ្មោះទម្រង់ពហុវចនៈ។ ឧទាហរណ៍ កៅអីច្រើន ខ្មៅដៃច្រើន សៀវភៅច្រើន។<br>21. អាចអនុវត្តតាមការណែនាំផ្សេងៗដើម្បីធ្វើកិច្ចការមួយដោយពុំមានផ្តល់គន្លឹះ ឬសញ្ញា។ | |
| ទុកឱកាសឱ្យសិក្ខាកាមសួរបញ្ជាក់ចំពោះចំណុចដែលមិនទាន់ច្បាស់ ។អ្នកសម្របសម្រួលពន្យល់បន្ថែមនូវរាល់សំណួររបស់សិក្ខាកាម ។ | សំណួរបំភ្លឺបន្ថែម | សំណួររំពឹង... |

| | | |
|---|---|---|
| អ្នកសម្របសម្រួល សំដែងតួក្នុងការអនុវត្ត ឧបករណ៍វាយតម្លៃទៅ លើសកម្មភាពសង្គម របស់កុមារ( សកម្មភាពទី១ ទី២ និង ទី៣ )។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>-អ្នកសម្របសម្រួលម្នាក់<br>-កុមារម្នាក់ ដែលសង្ស័យថា មានតម្រូវការពិសេស<br>-អនុវត្តសំណួរខាងលើ ជាមួយសិស្ស | សិក្ខាកាមសង្កេត និងកត់ត្រា |
| បែងចែកសិក្ខាកាមជា៥ក្រុម ហ្វឹកហាត់ រួចសម្តែងតួ តាមក្រុម រៀងៗខ្លួន ។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>ឬ សម្តែងតួតាមក្រុមតូច ក្នុងករណីរកសិស្សមិនបាន<br>-អនុវត្តសំណួរខាងលើ | សិក្ខាកាមសង្កេត និងកត់ត្រា |
| ជ្រើសរើស១ក្រុម ដើម្បី សម្តែងតួ ដល់ក្រុមធំ ដើម្បីឆ្លុះបញ្ចាំង និងកែលម្អ ។ | សម្តែងក្រុមធំ<br>-អនុវត្តសំណួរខាងលើ | សំណួរនិងចម្លើយ |
| អ្នកសម្របសម្រួលសង្ខេបអំពី ឧបករណ៍វាយតម្លៃសកម្មភាពសង្គម របស់កុមារ ។ | ពង្រឹងពុទ្ធិ | សិក្ខាកាមស្តាប់ |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិននិងខ្លឹមសារមេរៀន ៖ ឧបករណ៍វាយតម្លៃសកម្មភាពនៃការសិក្សារបស់កុមារ**

**វិធី និងសកម្មភាពបង្រៀន ៖**

- ឧទ្ទេសបង្ហាញ
- បំផុសសំណួរក្រុមធំ

- ធ្វើគំរូបង្ហាញ
- សំដែងតួ

**លទ្ធផលរំពឹងពីការសិក្សា** ៖

- **ចំណេះដឹង៖** សិក្ខាកាមយល់ច្បាស់អំពីឧបករណ៍វាយតម្លៃទាក់ទងសកម្មភាពសិក្សារបស់កុមារ ។
- **បំណិនសម្បទា៖** សិក្ខាកាមអាចអនុវត្ត និងកំណត់បានតម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពសិក្សា ។
- **ចរិយាសម្បទា៖** សិក្ខាកាមផ្លាស់ប្តូរវិធីសាស្រ្តបង្រៀនដោយផ្អែកទៅតាមប្រភេទសិស្ស តាមរយៈឧបករណ៍វាយតម្លៃលើសកម្មភាពសិក្សា ។

**សម្ភារឧបទេស** ៖

- ក្រដាសផ្ទាំងធំ
- LCD Projector
- កុំព្យូទ័រ
- ស្កុត
- ក្រដាសពណ៌
- ឯកសារមេរៀន
- ហ្វឺត
- កន្រ្តៃ

| សកម្មភាពគ្រូសម្របសម្រួល Trainer's Activities: | ខ្លឹមសារមេរៀន Key contents | សកម្មភាពសិស្ស/សិក្ខាកាម Trainees' activities |
|---|---|---|

| | | |
|---|---|---|
| *សួរសំណួរទៅក្រុមធំ៖*<br>តើកុមារមានតម្រូវការពិសេស មានការលំបាកអ្វីខ្លះ ក្នុងសកម្មភាពសង្គមរបស់ខ្លួន ? | រំលឹកអំពី សមត្ថភាពសង្គម ដែលកុមារមានតម្រូវការពិសេស ពិបាកធ្វើ<br>( សូមមើលខ្លឹមសារ មេរៀន សម្រាប់ម៉ោងមុន ) | ការងារក្រុមធំ៖<br>រៀបរាប់អំពីសកម្មភាពសង្គម របស់កុមារ មានសុខភាពធម្មតា និងកុមារមានតម្រូវការពិសេស |
| បែងចែកសិក្ខាកាមជាក្រុមតូចៗ<br>*សំណួរ:*<br>តើសកម្មភាពការសិក្សារបស់កុមារមានន័យដូចម្តេច ?<br><br>ចូរលោកគ្រូ អ្នកគ្រូរៀបរាប់អំពីសកម្មភាព ការសិក្សារបស់សិស្ស | ផ្សាភ្ជាប់មេរៀនថ្មី អំពីសកម្មភាពការសិក្សារបស់សិស្ស ដូចជា៖<br><br>-អានសៀវភៅ<br>-សរសេរ<br>-គណនាលេខ<br>-ពិភាក្សាក្រុម<br>-លេងល្បែងសិក្សា<br>-អានប្រណាំងគ្នា... | ការងារក្រុមតូច៖<br>–ពិភាក្សាក្រុម អំពី សកម្មភាពទាំងឡាយណាដែល បង្ហាញពីការសិក្សារបស់សិស្ស។<br>–កត់ត្រា និងរាយការណ៍ក្រុមតូច |
| បែងចែកសិក្ខាកាមជាក្រុមតូចៗ<br>*សំណួរ:*<br><br>តើសិស្សរបស់លោកគ្រូ អ្នកគ្រូ ជួបការលំបាកអ្វីខ្លះ ពាក់ព័ន្ធនឹងសកម្មភាពសិក្សា ? | សកម្មភាពធំៗ ដែលពាក់ព័ន្ធនឹងការលំបាក នៅក្នុងសកម្មភាពសិក្សារបស់សិស្ស អាចមាន៖<br>-ពិបាកអាន<br>-ពិបាកសរសេរ<br>-ពិបាកគណនាលេខ<br>-ពិបាកប្រកប<br>-មិនចាំព្យញ្ជនៈ ស្រៈ<br>-ផ្ទះឆ្ងាយ<br>-ក្រីក្រ... | ការងារក្រុមតូច<br>–ពិភាក្សាក្រុម<br>–កត់ត្រាតាមក្រុម<br>–រាយការណ៍លទ្ធផល ប្រៀបធៀបជាមួយក្រុមដទៃ |
| បទបង្ហាញអំពីឧបករណ៍វាយតម្លៃ ពី | **បញ្ជីសកម្មភាពនៃការសិក្សារបស់កុមារ៖** | សង្កេត |

| | | |
|---|---|---|
| សកម្មភាពសិក្សារបស់កុមារ ដោយពន្យល់តាមចំណុចម្តង មួយៗយ៉ាងលម្អិតដើម្បីឱ្យ សិក្ខាកាមយល់។ | *(សម្រាប់វាយតម្លៃសមត្ថភាពរបស់កុមារ)*<br>1. អានស្រះទាំងអស់(ជាភាសាអង់គ្លេស ឬភាសាខ្មែរ)នៅពេលដែល គេបង្ហាញនៅលើតារាង/សៀវភៅ។(ពាក្យដែលសរសេរនៅលើ ប្រអប់សម្រាប់បង្រៀន)។<br>2. អានពាក្យ(បន្លែ ផ្លែឈើ គ្រឿងសង្ហារឹម សត្វផ្សេងៗ) (ប្រហែល ១០ពាក្យ)។<br>3. អានពាក្យដែលមាន២-៣ព្យាង្គដោយពុំមានបង្ហាញរូបភាពជា ជំនួយ(ប្រហែល១០ពាក្យ)។<br>4. អានឈ្មោះរបស់ខ្លួន<br>5. អានឈ្មោះរបស់មិត្តភក្តិរបស់ខ្លួននៅក្នុងថ្នាក់។<br>6. ប្រាប់ស្លាកសញ្ញាចំនួន៤ទាក់ទងនឹងការធ្វើដំណើរដោយខ្លួនឯង(ឯករាជ្យ)។<br>7. សរសេរឈ្មោះរបស់ខ្លួន។<br>8. សរសេរពាក្យដែលជាឈ្មោះ (បន្លែ ផ្លែឈើ គ្រឿងសង្ហារឹម សត្វ សម្លៀកបំពាក់)។<br>9. ប្រាប់ពីតួនាទីនៃសរីរាង្គដែលទាក់ទងនឹងវិញ្ញាណ។<br>10. រាប់ និងផ្តល់វត្ថុផ្សេងៗរហូតដល់១០មុខ នៅពេលដែលគេពុំបានសួរតាមលំដាប់លំដោយ។<br>11. បង្ហាញនូវចំនួនរហូតដល់១០ នៅពេលដែលគេពុំបានសួរតាមលំដាប់លំដោយ។<br>12. រាប់ចំនួនរហូតដល់លេខ១០ នៅពេលគេពុំបានសួរតាមលំដាប់លំដោយ។<br>13. សរសេរលេខរហូតដល់លេខ១០ នៅពេលគេហៅឱ្យសរសេរ | ស្តាប់<br>កត់ត្រា |

| | | |
|---|---|---|
| | តាមអានចោះៗ។<br>14. សរសេរលេខរហូតដល់លេខ ១០ ទៅតាមលំដាប់លំដោយយ៉ាងត្រឹមត្រូវ។<br>15. សរសេរលេខដែលបាត់ដែលនៅពីខាងមុខ និងខាងក្រោយរហូតដល់លេខ១០។<br>16. ធ្វើលេខបូកងាយៗពីវត្ថុផ្សេងៗត្រឹមចំនួន១០(ដោយពុំចាំបាច់សរសេរលើក្រដាស)។<br>17. ធ្វើលេខបូកងាយៗពីវត្ថុផ្សេងត្រឹមចំនួន១០នៅលើក្រដាសដោយមានប្រើសញ្ញាធូត (/)។<br>18. ផ្តល់ឱ្យចំនួនពិតប្រាកដរបស់វត្ថុនានារហូតដល់២០ នៅពេលដែលគេសួរ។<br>19. បន្ថែមចំនួនពីចំនួន១១ រហូតដល់២០( ឧ. ១១= ១០ & ១)។<br>20. ចង្អុលលេខរហូតដល់លេខ២០ នៅពេលគេសួរតាមលំដាប់លំដោយ។<br>21. រៀបរាប់ចំនួនលេខរហូតលេខ ២០ នៅពេលគេពុំបានសួរលំដាប់លំដោយ។<br>22. សរសេរលេខរហូតដល់លេខ២០ នៅពេលដែលគេហៅឱ្យសរសេរតាមអាន។<br>23. សរសេរលេខរហូតដល់លេខ២០តាមលំដាប់លំដោយ។<br>24. សរសេរលេខដែលបាត់នៅពីមុខ និងពីក្រោយលេខ១៩។<br>25. រាប់លេខម្តង១០រហូតដល់លេខ១០០ (១០ ២០ ៣០ ៤០.......១០០)។ | |

| | | |
|---|---|---|
| | 26. ដាក់លេខ១០ៗដើម្បីឱ្យបានលេខ ១០ ២០ ៣០ ៤០ .......១០០)។<br>27. បញ្ចូល(ភ្ជាប់)ពេលវេលាជាមួយនឹងសកម្មភាពប្រចាំថ្ងៃ។<br>28. ប្រាប់/បង្ហាញនៅលើប្រតិទិន/តារាងឈ្មោះនៃថ្ងៃនៅពេលដែលគេសួរថា តើថ្ងៃនេះជាថ្ងៃអ្វី តើថ្ងៃស្អែកជា ថ្ងៃអ្វី ហើយតើថ្ងៃម្សិលមិញជាថ្ងៃអ្វី។<br>29. ប្រាប់/ធ្វើកាយវិការពីអ្វីដែលគេបានធ្វើពីព្រលឹមរហូតដល់ពេលចូលគេងតាមលំដាប់លំដោយ។<br>30. ប្រាប់អាយុរបស់ខ្លួន នៅពេលដែលគេសួរ។<br>31. ប្រាប់ / ធ្វើកាយវិការពីចំនួនថ្ងៃក្នុងមួយសប្តាហ៍។<br>32. ប្រាប់ពីចំនួនខែក្នុងមួយឆ្នាំ។<br>33. បង្ហាញពីកាលបរិច្ឆេទនៅលើប្រតិទិន។<br>34. ផ្លាស់ប្តូរកាលបរិច្ឆេទ និងខែនៅលើប្រតិទិន។<br>35. ប្រាប់ពីតួនាទីរបស់ទ្រនិចនាឡិកាវែង និងខ្លីនៅលើនាឡិកានៅពេលដែលគេសួរ។<br>36. បង្ហាញម៉ោងនៅលើនាឡិកាជាចំនួនម៉ោងគត់នៅពេលដែលគេសួរ។<br>37. ប្រាប់ម៉ោងពីចំនួនម៉ោងគត់ដោយមើលនាឡិការព្យួរជញ្ជាំង / នាឡិកាដៃ។<br>38. បង្ហាញម៉ោងជាចំនួនកន្លះម៉ោង(៣០នាទី)នៅលើនាឡិកា (ម៉ោង ៦៖៣០ ម៉ោង ៧៖៣០)។<br>39. ប្រាប់ម៉ោងជាចំនួនកន្លះម៉ោង[៣០នាទី] (ម៉ោង ៣៖៣០ ម៉ោង ៤៖៣០)ដោយមើលនាឡិកាព្យួរជញ្ជាំង / នាឡិកា | |

| | | |
|---|---|---|
| | ដៃ។<br>40. រៀបចំខ្លួនរួចរាល់ដើម្បីមកសាលារៀនឱ្យទាន់ពេលវេលា។<br>41. ស្គាល់ក្រដាសប្រាក់រៀល ១០០ ៥០០ ១០០០រៀល ឬ ប្រាក់ដុល្លា ពី១ដុល្លា ៥ដុល្លា ១០ដុល្លា។<br>42. រាប់ក្រដាសប្រាក់រៀល១០០រៀល ឱ្យបាន ៨០០រៀល ១០០០រៀល ២០០០រៀល ។ល។ ឬប្រាក់១ដុល្លាដើម្បីឱ្យបានចំនួន៨ដុល្លា ១០ដុល្លា ២០ដុល្លា ។ល។<br>43. ដាក់ក្រដាសប្រាក់១០០០រៀល ឱ្យបាន ២០០០ ៣០០០ ៤០០០ ៥០០០រៀល ឬ ប្រាក់ដុល្លា១០ដុល្លាមួយដុំៗដើម្បីឱ្យបានចំនួន២០ដុល្លា ៣០ដុល្លា ៤០ដុល្លា ៥០ដុល្លា ... ១០០ ដុល្លា។<br>44. អាប់លុយសម្រាប់ក្រដាស១០០០រៀល ដោយប្រើ ក្រដាស ៥០០រៀល (៥០០+ ៥០០) ឬ ១០ដុល្លាដោយប្រើប្រាស់ក្រដាស៥ដុល្លា (៥+៥)។<br>45. អាប់លុយដែលមានក្រដាស៥០០ ១០០០ ២០០០រៀល ដោយប្រើក្រដាស ៥០០ និង ១០០០រៀល ឬ អាប់លុយរហូតដល់១០ដុល្លា ២០ដុល្លា ៥០ដុល្លាដោយប្រើប្រាស់ក្រដាសប្រាក់៥ ដុល្លា និង១០ដុល្លាបញ្ចូលគ្នា។<br>46. ប្រាប់ពីឈ្មោះក្រដាសប្រាក់រៀល ឬ ដុល្លា។<br>47. ប្រាប់អំពីចំនួនទឹកប៉ុន្មានពែង / កែវទឹក ចំនួនអង្ករដែលគេត្រូវការដើម្បីដាក់ទៅក្នុងសម្ភារផ្ទះបាយដែលគេផ្តល់ឱ្យ។<br>48. វាស់បរិមាណទឹកជាពែងដែលគេត្រូវការសម្រាប់ឆុងតែ/កាហ្វេ។ | |

| | | |
|---|---|---|
| | 49. ប្រាប់ឪពុកម្តាយ / សមាជិកគ្រួសាររបស់គេនៅពេលគេមានអារម្មណ៍មិនស្រួលខ្លួន។<br>50. ប្រាប់ពីមធ្យោបាយធ្វើដំណើរផ្សេងៗ (កង់ ស៊ីក្លូ ម៉ូតូឌុប រ៉ឺម៉កកង់៣ រថយន្ត រថយន្តក្រុង រថភ្លើង យន្តហោះ)។<br>51. រៀបរាប់ឈ្មោះមធ្យោបាយធ្វើដំណើរផ្សេងៗ។<br>52. ឡើងជិះ ឬចុះពីមធ្យោបាយធ្វើដំណើរណាមួយនៅពេលដែលវាឈប់។ | |
| ទុកឱកាសឱ្យសិក្ខាកាមសួរបញ្ជាក់ចំពោះចំណុចដែលមិនទាន់ច្បាស់ ។ អ្នកសម្របសម្រួលពន្យល់បន្ថែមនូវរាល់សំណួររបស់សិក្ខាកាម ។ | សំណួរបំភ្លឺបន្ថែម | សំណួររំពឹង... |
| អ្នកសម្របសម្រួល សំដែងតួក្នុងការអនុវត្តឧបករណ៍វាយតម្លៃទៅលើសកម្មភាពសិក្សារបស់កុមារ( សកម្មភាពទី១ ទី២ និង ទី៣)។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>-អ្នកសម្របសម្រួលម្នាក់<br>-កុមារម្នាក់ ដែលសង្ស័យថា មានតម្រូវការពិសេស<br>-អនុវត្តសំណួរខាងលើ ជាមួយសិស្ស | សិក្ខាកាមសង្កេត និងកត់ត្រា |
| បែងចែកសិក្ខាកាមជា៥ក្រុម ហ្វឹកហាត់ រួចសម្តែងតួ តាមក្រុមរៀងៗខ្លួន ។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>ឬ សម្តែងតួតាមក្រុមតូច ក្នុងករណីរកសិស្សមិនបាន<br>-អនុវត្តសំណួរខាងលើ | សិក្ខាកាមសង្កេត និងកត់ត្រា |
| ជ្រើសរើស១ក្រុម ដើម្បីសម្តែងតួ ដល់ក្រុមធំ ដើម្បីឆ្លុះបញ្ចាំង និងកែលម្អ ។ | សម្តែងក្រុមធំ<br>-អនុវត្តសំណួរខាងលើ | សំណួរនិងចម្លើយ |

| | | |
|---|---|---|
| អ្នកសម្របសម្រួលសង្ខេបអំពីឧបករណ៍វាយតម្លៃសកម្មភាពការសិក្សារបស់សិស្ស។ | ពង្រឹងពុទ្ធិ | សិក្ខាកាមស្តាប់ |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**ចំណងជើងនិងខ្លឹមសារមេរៀន ៖ ឧបករណ៍វាយតម្លៃសកម្មភាពបែបការងាររបស់កុមារ**

**វិធីនិងសកម្មភាពបង្រៀន ៖**

- ឧទ្ទេសបង្ហាញ

- បំផុសសំណួរក្រុមធំ
- ធ្វើបង្ហាញ
- សំដែងតួ
- ពិភាក្សាក្រុមតូច
- ការងារដៃគូ ។

**លទ្ធផលរំពឹងពីការសិក្សា** ៖

- **ចំណេះដឹង៖** សិក្ខាកាមយល់ច្បាស់អំពីឧបករណ៍វាយតម្លៃទាក់ទងសកម្មភាពការងាររបស់កុមារ ។
- **បំណិនសម្បទា៖** សិក្ខាកាមអាចអនុវត្ត និងកំណត់បាននូវតម្រូវការរបស់កុមារទាក់ទងទៅនឹងសកម្មភាពការងារ ។
- **ចិរយាសម្បទា៖** សិក្ខាកាមផ្លាស់ប្តូរវិធីសាស្ត្របង្រៀនដោយផ្អែកទៅតាមប្រភេទសិស្ស តាមរយៈឧបករណ៍វាយតម្លៃលើសកម្មភាពការងារ ។

**សម្ភារឧទ្ទេស** ៖

- ក្រដាសផ្ទាំងធំ
- LCD Projector កុំព្យូទ័រ
- ស្កុត ក្រដាសពណ៌
- ឯកសារមេរៀន
- ហ្វឺត កន្ត្រៃ
- បណ្ណពាក្យ និងបណ្ណអក្សរ
- ប្រតិទិន
- នាឡិកាដៃ និងនាឡិកាយួដៃ
- វត្ថុខុសគ្នាចំនួន១០
- ក្រដាសប្រាក់រៀល
- ក្រដាសប្រាក់ដុល្លា
- តារាងឈ្មោះនៃថ្ងៃ

- ផ្ទាំងរូបភាពបន្លែ និងផ្លែឈើ

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| *សួរសំណួរទៅក្រុមធំ៖*<br>តើកុមារមានតម្រូវការពិសេស មានការលំបាកអ្វីខ្លះ ក្នុងសកម្មភាពសិក្សារបស់ខ្លួន ? | រំលឹកអំពី សមត្ថភាពផ្នែកការសិក្សា ដែលកុមារមានតម្រូវការពិសេស ពិបាកធ្វើ<br>( សូមមើលខ្លឹមសារ មេរៀន សម្រាប់ម៉ោងមុន ) | ការងារក្រុមធំ៖<br>រៀបរាប់អំពីសកម្មភាពសិក្សា របស់កុមារ មានសុខភាពធម្មតា និងកុមារមានតម្រូវការពិសេស |
| បែងចែកសិក្ខាកាមជាក្រុមតូចៗ<br>*សំណួរ:*<br>តើសកម្មភាពបែបការងាររបស់កុមារមានន័យដូចម្តេច ?<br><br>ចូរលោកគ្រូ អ្នកគ្រូរៀបរាប់អំពីសកម្មភាពបែប ការងាររបស់សិស្ស | សកម្មភាពធំៗ ដែលពាក់ព័ន្ធនឹងការលំបាក នៅក្នុងសកម្មភាពបែបការងារ របស់សិស្ស អាចមាន៖<br>-ជួយធ្វើការងារផ្ទះ<br>-លាងចាន<br>-សំអាតបន្ទប់ទឹក<br>-ចិតបន្លែ ធ្វើម្ហូប<br>-រៀបចំអាហារ<br>-ទុកដាក់សម្ភារ | ការងារក្រុមតូច<br>–ពិភាក្សាក្រុម<br>–កត់ត្រាតាមក្រុម<br>–រាយការណ៍លទ្ធផល ប្រៀបធៀបជាមួយក្រុមដទៃ |
| តើសិស្សរបស់លោកគ្រូ អ្នកគ្រូ ជួបការលំបាកអ្វីខ្លះ ពាក់ព័ន្ធនឹងសកម្មភាពបែបការងារ ? | ឧទាហរណ៍ ទាក់ទងនឹងសកម្មភាពបែបការងារ ដែលកុមារជួបការលំបាកមាន:<br>-មិនអាចជួយការងារផ្ទះ<br>-មិនអាចដាំបន្លែ<br>-មិនអាចដាំស្ល ឬដាំបាយ... | ការងារក្រុមតូច<br>–ពិភាក្សាក្រុម<br>–កត់ត្រាតាមក្រុម<br>–រាយការណ៍លទ្ធផល ប្រៀបធៀបជាមួយក្រុមដទៃ |
| បទបង្ហាញអំពីឧបករណ៍វាយតម្លៃ ពី | **បញ្ជីសកម្មភាពបែបការងាររបស់កុមារ៖** | សង្កេត និងស្តាប់ |

| | | |
|---|---|---|
| សកម្មភាពការងាររបស់កុមារ ដោយពន្យល់តាមចំណុចម្តងមួយៗយ៉ាងលម្អិត ដើម្បីឱ្យសិក្ខាកាមយល់។ | *(សម្រាប់វាយតម្លៃសមត្ថភាពរបស់កុមារ)*<br>1. បោសធូលីលើគ្រឿងសង្ហារឹម និងវត្ថុផ្សេងៗទៀតនៅក្នុងផ្ទះ ដោយប្រើប្រាស់អំបោសដែលធ្វើពីក្រណាត់។<br>2. ដាក់បន្លែទៅតាមប្រភេទរបស់វា និងដាក់វានៅតាមធ្នើរ/ប្រអប់នីមួយៗនៅក្នុងទូទឹកកក។<br>3. រៀបចំចាន និងកែវទឹកបានត្រឹមត្រូវនៅលើតុអាហារ/កម្រាលសម្រាប់អាហារពេលព្រឹក/ពេលថ្ងៃត្រង់/ពេល ល្ងាច នៅពេលដែលគេបានប្រាប់។<br>4. លាងចាន និងកែវទឹកបន្ទាប់ពីទទួលទានអាហារ/ អាហារសម្រន់រួច។<br>5. បកសំបកបន្លែដូចជា សណ្តែក ខ្ទឹមបារាំង ដំឡូងស្ងោរ ។ល។ នៅពេលដែលពុំមានកាំបិត/ប្រដាប់ចិត។<br>6. ត្រងទឹកពីក្បាលរ៉ូប៊ីណេដោយប្រើធុងយួរតូចៗនៅពេលដែលចាំបាច់ ឬនៅពេលសមាជិកគ្រួសារប្រើ។<br>7. ដាក់សម្ភារផ្ទះបាយគរគ្នាបន្ទាប់ពីលាងសម្អាតរួច។<br>8. រៀបចំអាហារសម្រន់/ម្ហូបអាហារផ្សេងៗដាក់ក្នុងចានសម្រាប់សមាជិកគ្រួសារ។<br>9. បេះស្លឹកបន្លែពីបន្លែដែលគេទទួលទានស្លឹក។<br>10. ជួយធ្វើការម្តាយ/ឪពុក/បងប្អូននៅក្នុងផ្ទះបាយដោយជួយយករបស់របរសម្រាប់ដាំស្ល ដូចជាបន្លែ/ គ្រឿង ផ្សំ វាល់ទឹកសម្រាប់ឆុងតែ/កាហ្វេ នៅពេលគេប្រាប់។ | |
| ទុកឱកាសឱ្យសិក្ខាមសួរបញ្ជាក់ចំពោះចំណុចដែលមិនទាន់ច្បាស់ ។ អ្នកសម្រប | សំណួរបំភ្លឺបន្ថែម | សំណួររំពឹង... |

| | | |
|---|---|---|
| សម្រួលពន្យល់បន្ថែមនូវរាល់សំណួររបស់សិក្ខាកាម ។ | | |
| អ្នកសម្របសម្រួលសំដែងតួក្នុងការអនុវត្តឧបករណ៍វាយតម្លៃទៅលើសកម្មភាពបែបការងាររបស់កុមារ( សកម្មភាពទី១ ទី២ និង ទី៣ )។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>-អ្នកសម្របសម្រួលម្នាក់<br>-កុមារម្នាក់ ដែលសង្ស័យថា មានតម្រូវការពិសេស<br>-អនុវត្តសំណួរខាងលើ ជាមួយសិស្ស | សិក្ខាកាមសង្កេត និងកត់ត្រា |
| បែងចែកសិក្ខាកាមជា៥ក្រុម ហ្វឹកហាត់ រួចសម្តែងតួ តាមក្រុមរៀងៗខ្លួន ។ | អនុវត្តផ្ទាល់ជាមួយសិស្ស<br>ឬ សម្តែងតួតាមក្រុមតូច ក្នុងករណីរកសិស្សមិនបាន<br>-អនុវត្តសំណួរខាងលើ | សិក្ខាកាមសង្កេត និងកត់ត្រា |
| ជ្រើសរើស១ក្រុម ដើម្បីសម្តែងតួ ដល់ក្រុមធំ ដើម្បីឆ្លុះបញ្ចាំង និងកែលម្អ ។ | សម្តែងក្រុមធំ<br>-អនុវត្តសំណួរខាងលើ | សំណួរនិងចម្លើយ |
| អ្នកសម្របសម្រួលសង្ខេបអំពីឧបករណ៍វាយតម្លៃសកម្មភាពការងាររបស់កុមារ។ | ពង្រឹងពុទ្ធិ | សិក្ខាកាមស្តាប់ |

# មេរៀនទី៧៖

# វិធីសាស្រ្តបង្រៀនកុមារ៖

## ១. មានការលំបាកសិក្សាមុខវិជ្ជា៖

- ពិបាកក្នុងការអាន (២ម៉ោង)
- ពិបាកក្នុងការសរសេរ (២ម៉ោង)
- ពិបាកក្នុងការគណនា (៤ម៉ោង)

## ២. លំហាត់ វិធី គន្លឹះ និងល្បិច ក្នុងការបង្រៀនបំណិនអំណានភាសាខ្មែរ កម្រិតបឋមសិក្សា (នៅក្នុងឯកសារឧបសម្ពន្ធ)៖

- ស្គាល់ស្វ័រ តួអក្សរ និងស្រៈ (សម្រាប់អំណានភាសាខ្មែរថ្នាក់ដំបូងៗ)៖ រយៈពេល៥ម៉ោង
- ប្រកបព្យាង្គ (សម្រាប់អំណានភាសាខ្មែរថ្នាក់ដំបូងៗ)៖ រយៈពេល៣ម៉ោង

## ៣. ខ្សែភាពយន្ត

## ៤. អូឌីសឹម

## គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

មេរៀន៧៖ **លំបាកក្នុងការសិក្សាមុខវិជ្ជា: ពិបាកក្នុងការអាន** សម្រាប់រយៈពេល ២ម៉ោង

| ខ្លឹមសារសំខាន់ៗ Key Content of the Topic | វិធីសាស្ត្រ និងសកម្មភាពបង្រៀន Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន Training/Teaching Materials | រយៈពេលបង្រៀន | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា |
|---|---|---|---|---|

| | | | Duration for training/teaching | Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| **១.រំលឹកនិយមន័យ**<br><br>" ការពិបាកក្នុងការអាន" | - ឱ្យសិក្ខាកាមអានឯកសារ = ១០ នាទី<br>❖ គ្រូសម្របសម្រួលចែកសិក្ខាកាមជាក្រុមតូចៗ<br>- ពិភាក្សាក្រុម =១០នាទី<br>- តំណាងក្រុមឡើងបង្ហាញលទ្ធផលក្រុម=៥នាទី | - ក្ដារខៀន<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត | ២៥នាទី | សិក្ខាកាមប្រាប់បានអំពីនិយមន័យ របស់ការពិបាកក្នុងការអាន |
| **២.រំលឹក**លក្ខណៈសម្គាល់នៃការលំបាកក្នុងការអាន | គ្រូសម្របសម្រួលសួរសិក្ខាកាម និងឱ្យសិក្ខាកាមសរសេរចម្លើយ បិទនៅលើក្រដាសផ្ទាំងធំ។<br>**១.ការងារជាបុគ្គល**<br><br>- តើនៅក្នុងថ្នាក់របស់លោកគ្រូ អ្នកគ្រូមានកុមារមិនចេះអានប៉ុន្មាននាក់? (៥នាទី)<br>**២.ការងារក្រុម (៣ក្រុម)**<br>- តើលោកគ្រូអ្នកគ្រូសម្គាល់ឃើញយ៉ាងដូចម្តេចចំពោះកុមារដែលពិបាកក្នុងការអាន? (៥នាទី)<br>- តំណាងក្រុមបង្ហាញលទ្ធផល (៥នាទី/ក្រុម)<br>1. គ្រូសម្របសម្រួលផ្តល់នូវចម្លើយដែលត្រឹមត្រូវ។(១០នាទី)<br>៣. បង្ហាញវីដេអូពីកុមារដែលពិបាកក្នុង | - ក្រដាសរ៉ាម<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ខ្មៅដៃ<br>- ឧបករណ៍បញ្ចាំងស្លាយ (LCD)<br>- វីដេអូ | ៤០នាទី | សិក្ខាកាមប្រាប់ថា នៅក្នុងថ្នាក់របស់គាត់មានកុមាលំបាកក្នុងការអាន ចំនួន ...........នាក់ |

| | | | | |
|---|---|---|---|---|
| | ការអាន។(៧នាទី)   | | | |
| ៣. វិធីសាស្ត្រជួយកុមារពិបាកក្នុងការអាន | គ្រូសម្របសម្រួលចែកជាក្រុមដែលមានគ្នា៥ទៅ៦អ្នកឱ្យសិក្ខាកាមរកវិធីសាស្ត្រក្នុងការជួយកុមារពិបាកក្នុងការអាន។<br>១.ពិភាក្សាតាមក្រុម ៥នាទី និងបង្ហាញលទ្ធផល៥នាទី<br>២. គ្រូសម្របសម្រួលបង្ហាញនូវវិធីសាស្ត្រមួយចំនួនដល់សិក្ខាកាមដូចខាងក្រោម៖ ២០នាទី<br><br>- ប្រើរូបិយ និងរូបភាពជំនួយ<br>- ប្រើពហុវិញ្ញាណ<br>- ប្រើពណ៌ចម្រុះ<br>- ប្រើល្បែងចងចាំ<br>- ប្រើវិធីផ្គូរផ្គង<br>- ប្រើវិធីប្រៀបធៀប<br>- ប្រើវិធីចាត់ចំណាត់ថ្នាក់ ចែកក្រុម<br>- ប្រើល្បែង ដូចជា Puzzle, Bingo, ជាដើម<br><br>៣. គ្រូសម្របសម្រួល នាំសិក្ខាកាមលេងល្បែងផ្សេងៗដូចរៀបរាប់ខាងលើ។ | - ក្រដាសប៉ាម<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ខ្មៅដៃ<br>- ឧបករណ៍បញ្ចាំងស្លាយ (LCD)<br>- វីដេអូ | ៦០ នាទី | សិក្ខាកាមមានចំណេះដឹងពីវិធីសាស្ត្រជួយកុមារពិបាកក្នុងការអាន។ |

| | | | | |
|---|---|---|---|---|
| | (៣០ នាទី) | | | |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**ចំណងជើងខ្លឹមសារមេរៀន** : **លំបាកក្នុងការសិក្សាមុខវិជ្ជា: ពិបាកក្នុងការអាន**

**វិធី និងសកម្មភាពបង្រៀន** : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្តែងតួ ករណីសិក្សា បង្ហាញវីដេអូ រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖ **ចំណេះដឹង**

សិក្ខាកាមយល់អំពីវិធីសាស្ត្រជួយកុមារការពិបាកក្នុងការអាន តាមរយៈសំណួរបំផុស ឧទាហរណ៍ រូបភាព បណ្ណពាក្យ បានត្រឹមត្រូវ។

៖ **បំណិនសម្បទា**

សិក្ខាកាមមានបំណិនក្នុងការជួយដល់កុមារពិបាកក្នុងការអានតាមរយៈការអនុវត្តវិធីសាស្ត្រងាយៗ បានល្អ។

៖ **ចរិយាសម្បទា**

សិក្ខាកាមដែលជាគ្រូ បានកាត់បន្ថយកុមារពិបាកក្នុងការអាន បានចំនួន................នាក់ នៅក្នុងថ្នាក់របស់គាត់ ។

**សម្ភារបង្រៀន** ៖

- បណ្ណពាក្យ
- បណ្ណរូបភាព
- អក្សរចល័ត
- រូបភាពពិត

| សកម្មភាពគ្រូសម្របសម្រួល | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស/សិក្ខាកាម |
|---|---|---|

| Trainer's Activities: | Key contents | Trainees' activities |
|---|---|---|
| រំលឹកនិយមន័យ និងលក្ខណៈសម្គាល់ របស់កុមារពិបាកសិក្សាមុខវិជ្ជាៈ ពិបាកអាន<br>( សូមមើលរបៀបបង្រៀន អំពីនិយមន័យ និងលក្ខណៈសម្គាល់ របស់កុមារពិបាកសិក្សាមុខវិជ្ជាៈ ពិបាកអាន នៅក្នុងមេរៀនទី៣ ) | | |
| • សំណួរ ៖<br>១. ចូររក បច្ចេកទេស សកម្មភាពមួយចំនួន ដែលអាចជួយឱ្យកុមារពិបាកអាន អាចរៀនបាន នៅក្នុងថ្នាក់<br>• អនុវត្តបង្ហាញ៖<br>២.គ្រូសម្របសម្រួលបង្ហាញវិធីសាស្ត្រ ម្តងមួយៗ ក្នុងការជួយកុមារដែលពិបាកក្នុងការអាន | **វិធីដែលគ្រូ ត្រូវប្រើសម្រាប់ ជួយកុមារពិបាកអាន**<br>- ប្រើរូបិយ និងរូបភាពជំនួយ<br>- ប្រើពហុវិញ្ញាណ<br>- ប្រើពណ៌ចម្រុះ<br>- ប្រើល្បែងចងចាំ<br>- ប្រើវិធីផ្គូរផ្គង<br>- ប្រើវិធីប្រៀបធៀប<br>- ប្រើវិធីចាត់ចំណាត់ថ្នាក់ ចែកក្រុម<br>- ប្រើល្បែង ដូចជា Puzzle, Bingo, ជាដើម | <u>ការងារក្រុម៤ឬ៥នាក់៖</u><br>១.ពិភាក្សាគ្នា និងសញ្ជឹងគិតដល់ វិធីដែលខ្លួនធ្លាប់ឃើញ និងបានអនុវត្ត<br>២. សំយោគ<br>៣. តំណាងក្រុមរាយការណ៍លទ្ធផលពិភាក្សា<br><br><u>សិក្ខាកាមសង្កេត និងសួរសំណួរ</u><br>១. អានមេរៀនទំព័រ១០៨, ១០៩ និងទំព័រ ពី១២៤ ដល់ ១៤១ |
| គ្រូសម្របសម្រួលលើកឧទាហរណ៍អំពីការបង្រៀនសិស្សពិបាកការបែងចែកឱ្យដាច់ពីគ្នា នូវតួអក្សរមួយចំនួន | **១. ករណីច្រឡំតួអក្សរ** ពិបាកសម្គាល់ ពិបាកអាន និងឧស្សាហ៍ច្រឡំ (ច្រឡំតួអក្សរ)<br>ដូចជា «ល» និង «ហ» ឬ លេខ «៦» និង «៨»<br>▪ «គ» ថាជា «ក» ឬជា «ត» ឬជា «ភ»<br><br>*ការច្រឡំតួមាន៖ «រូបរាង ទីតាំង និងទិស របស់តួអក្សរ»*<br> | <u>សិក្ខាកាមសង្កេត និងសួរសំណួរ</u><br>១. អានមេរៀនទំព័រ១២៧, ១៣៣ |

| | | |
|---|---|---|
| |  | |
| គ្រូសម្របសម្រួល ពន្យល់ និងអនុវត្តបង្ហាញ៖<br><br>***ករណីបង្រៀន ផ្សំសូរ សូរដូច និងវាក្យស័ព្ទ*** *តាមរបៀបបរិយាបន្ន៖*<br>1. នាំសិស្សរៀនផ្សំសូរ/កាច់សូរពីរចូលគ្នា ដូចជា ម្ទ ម្ទ .ក្ស . ស្រ.ក្រ...។ល។ ដោយប្រើព្យញ្ជនៈនិងស្រៈចល័ត សម្លេង និងកាយវិការ (ប្រើព្យញ្ជនៈម្តងមួយៗ ផ្សំជាមួយស្រៈម្តងមួយៗ រហូតដល់អស់បើអាច)<br>2. ប្រើរូបភាព បណ្ណពាក្យ កាយវិកាសម្តែង សម្រាប់ពាក្យដែលមានសូរដូចគ្នា<br>3. ការបង្រៀនព្យញ្ជនៈ និងស្រៈ អាចបង្រៀនជាលក្ខណៈគូៗ ដូចជា៖ «ក.គ» «ខ.ឃ» «ច.ជ» «ថ.ធ» «ផ.ភ « »ដ.ឌ...«ជាដើម ដើម្បីឱ្យសិស្សចេះសម្គាល់សូរ «អនិង អ៊» និងកុំឱ្យសិស្សច្រឡំសូរទាំងពីរ តាមរយៈល្បែង<br>4. ប្រើការផ្សំតួអក្សរឱ្យទៅជាសម្លេងនិងពាក្យ (Manipulating) ដោយប្រើ ព្យញ្ជនៈនិងស្រៈចល័ត តាមរយៈល្បែង<br>5. វិធីប្រើល្បែងដូចជា៖<br>➢ ផ្គូរផ្គង ឬចាប់គូ (រូប និងខ្លឹមសារ)<br>➢ ប្រៀបធៀប<br>➢ ចែកក្រុម | **២. ករណីពិបាកស្គាល់សូរ** (Phonemic awareness)៖ ពិបាកសម្គាល់សូរ ចងចាំសូរ បំបែកសូរ និងផ្សំសូរ<br><br>*ការច្រឡំសូរមាន៖ «សូរ អ និង សូរ អ៊ ពេលផ្សំចូលគ្នា រវាងព្យញ្ជនៈ និងស្រៈ »*<br><br>a. សូរដូច(Rhymes): ពិបាកសម្គាល់ សូរចួនរបស់ពាក្យ (...គរ/គូ.សរ/ស.កាយ .ឱ)<br>b. ការផ្សំសូរ (Blending): ពិបាកផ្សំសូរ របស់ព្យញ្ជនៈ និងស្រៈ ដើម្បីបង្កើតជាសូរថ្មី (...ក្រ.ស្រ .ក្ស .ម្ទ ម្ទ.ឱ)<br>c. ការបំបែកព្យាង្គ និងសូរ (Segmenting): ពិបាកបំបែកពាក្យមួយ ឱ្យទៅជាព្យាង្គ និងជាសូរផ្សេងៗគ្នា<br>d. ការផ្សំតួអក្សរឱ្យទៅជាសម្លេងនិងពាក្យ (Manipulating): ពិបាកប្រកបពាក្យ និងបង្កើតសម្លេង<br>e. ពាក្យចុងចួន )Alliteration): ពិបាករកពាក្យចុងចួន | <u>សិក្ខាកាមសង្កេត និងសួរសំណួរ</u><br>១. អានមេរៀន<br>២. អនុវត្តជាដៃគូ និងក្រុម |

| | | |
|---|---|---|
| *ការញែកសូរ និងបំបែកព្យាង្គ*<br>▪ នាំសិស្សឱ្យស្គាល់ចំនួនព្យាង្គរបស់ពាក្យនីមួយៗ តាមរយៈលំហាត់ផ្ទាល់មាត់ និងសំណេរ<br>▪ នាំសិស្សឱ្យចេះញែកសូររបស់ព្យាង្គ និងពាក្យ ដូចជា « សូរដើម សូរបន្ទាប់/ចុង» តាមរយៈលំហាត់ផ្ទាល់មាត់ សំណេរ និងល្បែង | | |
| សូមអនុវត្តតាម លំហូរ វិធី គន្លឹះ និងល្បិចបង្រៀន នៅក្នុងឧបសម្ពន្ធភ្ជាប់ | **៣ .ករណីពិបាកក្នុងដំណើរការបង្កើតសូរ និងចងចាំ នៅក្នុងភាសា:** (Phonological processing)៖<br>▪ ពិបាកស្គាល់សូរ<br>▪ ពិបាកចាំសូរ<br>▪ ពិបាករំលឹកឈ្មោះបានភ្លាមៗ | <u>សិក្ខាកាមសង្កេត និងសួរសំណួរ</u><br>១. អានមេរៀន<br>២. អនុវត្តជាដៃគូ និងក្រុម |
| សូមអនុវត្តតាម លំហូរ វិធី គន្លឹះ និងល្បិចបង្រៀន នៅក្នុងឧបសម្ពន្ធភ្ជាប់ | ៤. **ករណីពិបាកប្រកប និងអាន ព្យាង្គ និងពាក្យសព្ទថ្មី**<br>សូមមើលលំហូរ វិធី គន្លឹះ និងល្បិចបង្រៀន នៅក្នុងឧបសម្ពន្ធភ្ជាប់ | <u>សិក្ខាកាមសង្កេត និងសួរសំណួរ</u><br>១. អានមេរៀន<br>២. អនុវត្តជាដៃគូ និងក្រុម |

# មេរៀន៧៖ **លំបាកក្នុងការសិក្សាមុខវិជ្ជា: ពិបាកក្នុងការសរសេរ** សម្រាប់រយៈពេល ២ម៉ោង

| ខ្លឹមសារសំខាន់ៗ<br>Key Content of the Topic | វិធីសាស្ត្រ និងសកម្មភាពបង្រៀន Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន<br>Training/Teaching Materials | រយៈពេលបង្រៀន<br>Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា<br>Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| **១.រំលឹកនិយមន័យ**<br><br>" ការពិបាកក្នុងការសរសេរ" | - ឱ្យសិក្ខាកាមអានឯកសារ = ១០ នាទី<br>❖ គ្រូសម្របសម្រួលចែកសិក្ខាកាមជាក្រុមតូចៗ<br>- ពិភាក្សាក្រុម =១០នាទី<br>- តំណាងក្រុមឡើងបង្ហាញលទ្ធផលក្រុម=៥នាទី | - ក្តារខៀន<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត | ២៥នាទី | សិក្ខាកាមប្រាប់បានអំពីនិយមន័យ របស់ការពិបាកក្នុងការសរសេរ |
| **២.រំលឹក**លក្ខណៈសម្គាល់នៃការលំបាកក្នុងការសរសេរ | គ្រូសម្របសម្រួលសួរសិក្ខាកាម និងឱ្យសិក្ខាកាមសរសេរចម្លើយបិទនៅលើក្រដាសផ្ទាំងធំ។<br>**១.ការងារជាបុគ្គល**<br><br>- តើនៅក្នុងថ្នាក់របស់លោកគ្រូអ្នកគ្រូមានកុមារពិបាកសរសេរប៉ុន្មាននាក់? (៥នាទី)<br>**២.ការងារក្រុម (៣ក្រុម)** | - ក្រដាសរ៉ាម<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ខ្មៅដៃ<br>- ឧបករណ៍បញ្ចាំងស្លាយ (LCD)<br>- វីដេអូ | ៤០នាទី | សិក្ខាកាមប្រាប់ថា នៅក្នុងថ្នាក់របស់គាត់មានកុមារលំបាកក្នុងការសរសេរចំនួន ...........នាក់ |

| | | | | |
|---|---|---|---|---|
| | - តើលោកគ្រូអ្នកគ្រូសម្គាល់ឃើញយ៉ាងដូចម្តេចចំពោះកុមារដែលពិបាកក្នុងការសរសេរ?(៥នាទី)<br>- តំណាងក្រុមបង្ហាញលទ្ធផល (៥នាទី/ក្រុម)<br>2. គ្រូសម្របសម្រួលផ្តល់នូវចម្លើយដែលត្រឹមត្រូវ។(១០នាទី)<br>៣. បង្ហាញវីដេអូអំពីកុមារដែលពិបាកក្នុងការសរសេរ។(៧នាទី) | | | |

| | | | | |
|---|---|---|---|---|
| ៣. វិធីសាស្រ្តជួយកុមារពិបាកក្នុងការសរសេរ | គ្រូសម្របសម្រួលចែកជាក្រុមដែលមានគ្នា៥ទៅ៦អ្នកឱ្យសិក្ខាកាមរកវិធីសាស្រ្តក្នុងការជួយកុមារពិបាកក្នុងការសរសេរ។<br>១.ពិភាក្សាតាមក្រុម ៥នាទី និងបង្ហាញលទ្ធផល៥នាទី<br>២. គ្រូសម្របសម្រួលបង្ហាញនូវវិធីសាស្រ្តមួយចំនួនដល់សិក្ខាកាមដូចខាងក្រោម៖ ២០នាទី<br>ក. ប្រើវិធីទាំង៤០ចំណុច ដូចបង្ហាញក្នុងមេរៀន<br>ខ. ប្រើសកម្មភាពជាក់លាក់ដូចជា៖<br>▪ សកម្មភាពជួយបង្កើននិងសម្របសម្រួលចលនាតូច ដូចជា ល្បែងសាងសង់ ល្បែងជាមួយមេដែក ចាក់ទឹកចូលក្នុងធុងតូច ល្បែងចាប់ចង្កឹះជ្រើសរើសវត្ថុតូចៗ ដែលមានពណ៌ផ្សេងគ្នា<br>▪ ការផាត់ពណ៌និងគូសរូប<br>▪ ប្រើឧបករណ៍សម្រាប់កាន់ខ្មៅដៃ, ...<br>៣. គ្រូសម្របសម្រួល នាំសិក្ខា | - ក្រដាសប៉ោម<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ខ្មៅដៃ<br>- ឧបករណ៍បញ្ចាំងស្លាយ (LCD)<br>- វីដេអូ | ៦០ នាទី | សិក្ខាកាមមានចំណេះដឹងពីវិធីសាស្រ្តជួយកុមារពិបាកក្នុងការសរសេរ។ |

| | | | | |
|---|---|---|---|---|
| | កាមលេងល្បែង ផ្សេងៗដូច រៀបរាប់ខាងលើ។ (៣០ នាទី) | | | |

## គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

មេរៀន៧៖ **លំបាកក្នុងការសិក្សាមុខជំនាញ: ពិបាកក្នុងការគណនា** សម្រាប់រយៈពេល ៤ម៉ោង

| ខ្លឹមសារសំខាន់ៗ Key Content of the Topic | វិធីសាស្រ្ត និងសកម្មភាពបង្រៀន Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន Training/Teaching Materials | រយៈពេលបង្រៀន Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| ១.រំលឹកលក្ខណៈសម្គាល់នៃការលំបាកក្នុងការគណនា | គ្រូសម្របសម្រួលសួរសិក្ខាកាម និងឱ្យសិក្ខាកាមសរសេរចម្លើយ បិទនៅលើក្រដាសផ្ទាំងធំ។<br>**១.ការងារជាបុគ្គល**<br>- តើនៅក្នុងថ្នាក់របស់លោកគ្រូ អ្នកគ្រូមានកុមារជួបការលំបាកក្នុងការគណនាប៉ុន្មាននាក់? (៥នាទី)<br>**២.ការងារក្រុម (៣ក្រុម)**<br>- តើលោកគ្រូអ្នកគ្រូសម្គាល់ឃើញយ៉ាងដូចម្តេចខ្លះចំពោះកុមារដែលពិបាកក្នុងការគណនា?(៥នាទី)<br>- តំណាងក្រុមបង្ហាញលទ្ធផល (៥នាទី/ក្រុម)<br>3. គ្រូសម្របសម្រួលផ្តល់នូវចម្លើយដែលត្រឹមត្រូវ។(១០នាទី)<br>៣. បង្ហាញវីដេអូអំពីកុមារដែលពិបាកក្នុងការគណនា។(៧នាទី) | - ក្រដាសប៉ាម<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ខ្មៅដៃ<br>- ឧបករណ៍បញ្ចាំងស្លាយ (LCD)<br>- វីដេអូ | ៤០នាទី | សិក្ខាកាមប្រាប់ថា នៅក្នុងថ្នាក់របស់គាត់មានកុមារលំបាកក្នុងការគណនា ចំនួន ...........នាក់ |

| | | | | |
|---|---|---|---|---|
| ២. វិធីសាស្ត្រជួយកុមារពិបាកក្នុងការគណនា | គ្រូសម្របសម្រួលចែកជាក្រុមដែលមានគ្នា៥ទៅ៦អ្នកឱ្យសិក្ខាកាមរកវិធីសាស្ត្រក្នុងការជួយកុមារពិបាកក្នុងការគណនា៖<br>១.ពិភាក្សាតាមក្រុម ៥នាទី និងបង្ហាញលទ្ធផល៥នាទី<br>២. គ្រូសម្របសម្រួលបង្ហាញនូវវិធីសាស្ត្រមួយចំនួនដល់សិក្ខាកាមដូចខាងក្រោម៖ ២០នាទី<br>ក. គន្លឹះសំខាន់ៗ ដូចជា៖<br>▪ ប្រើល្បែងគណិតវិទ្យា<br>▪ វិធីរាប់ចំនួនខ្ទង់រាយ ដោយការបន្ថែមចំនួន ដោយវត្ថុពិត<br>▪ ការរាប់លេខថយក្រោយ | - ក្រដាសប៉ាម<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ខ្មៅដៃ<br>- ឧបករណ៍បញ្ចាំងស្លាយ (LCD)<br>- វីដេអូ | ៦០ នាទី | សិក្ខាកាមមានចំណេះដឹងពីវិធីសាស្ត្រជួយកុមារពិបាកក្នុងការគណនា។ |

| | | | | |
|---|---|---|---|---|
| **៣. ករណីលំបាកដាក់លាក់មួយចំនួន ដូចជា៖**<br>▪ មិនស្គាល់តម្លៃលេខ<br>▪ មិនចេះបូកលេខ ឬដកលេខ<br>▪ មិនចេះបូកឬដកលេខតាមខ្ទង់ រាយដប់ រយ...<br>▪ មិនចាំតារាងមេគុណ<br>▪ មិនចេះប្រមាណវិធីគុណ<br>▪ មិនចេះប្រមាណវិធីចែក<br>▪ មិនចេះដោះស្រាយចំណោទ | គ្រូសម្របសម្រួលចែកជាក្រុមដែលមានគ្នា៥ទៅ៦អ្នកឱ្យសិក្ខាកាមរកវិធីសាស្ត្រក្នុងការជួយកុមារពិបាកក្នុងការគណនា ទៅតាមករណីលំបាកជាក់លាក់ ដូចក្នុងខ្លឹមសារ។<br><br>បង្ហាញដោយប្រើក្រដាស់ផ្ទាំងធំ ក្នុងរបៀបមួយៗ (១ ម៉ោង)<br><br>គ្រូសម្របសម្រួល នាំសិក្ខាកាមលេង លំហាត់ជាក់ស្តែង ដោយយកសិក្ខាកាម ធ្វើជាសិស្ស។ (៣០ នាទី) | | ៦០ នាទី<br><br><br><br><br><br><br>៦០ នាទី | |

# គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

**លំហូរ ចង្វាក់ គន្លឹះ និងល្បិច ក្នុងការបង្រៀនបំណិនអំណានភាសាខ្មែរ កម្រិតបឋមសិក្សា** សម្រាប់រយៈពេល ៨ម៉ោង

ខ្លឹមសារមេរៀនមាននៅក្នុងឯកសារឧបសម្ព័ន្ធ ដោយផ្តោតលើតែ បំណិនមូលដ្ឋានគ្រឹះ ចំនួនពីរ គឺ៖

- *ស្គាល់សូរ តួអក្សរ និងសូរ (សម្រាប់អំណានភាសាខ្មែរថ្នាក់ដំបូងៗ)៖ រយៈពេល៥ម៉ោង*
- *ប្រកបព្យាង្គ (សម្រាប់អំណានភាសាខ្មែរថ្នាក់ដំបូងៗ)៖ រយៈពេល៣ម៉ោង*

| ខ្លឹមសារសំខាន់ៗ Key Content of the Topic | វិធីសាស្ត្រ និងសកម្មភាពបង្រៀន Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន Training/Teaching Materials | រយៈពេលបង្រៀន Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| **លំហូរសកម្មភាព និងបំណិនតូចៗ** | ១. សិក្សាលំហូរ៖<br>▪ អ្នកសម្របសម្រួល ណែនាំ បញ្ញត្តិសំខាន់ៗ សម្រាប់ឱ្យកុមារ ស្គាល់ សូរ តួអក្សរ និងសូរ ក្នុងការសិក្សា ព្យញ្ជនៈ ស្រៈ និងព្យាង្គ ឬពាក្យ<br>▪ ការងារក្រុម៖ អ្នកសម្របសម្រួល កាត់ខ្លឹមសារលំហូរ ជាផ្នែកតូចៗ សម្រាប់ឱ្យសិក្សាកាម ផ្គូផ្គង វិធី លំហូរ និងគន្លឹះ ឱ្យត្រូវតាមឯកសារដែលត្រូវចែកជូន<br>▪ បង្ហាញលទ្ធផលតាមក្រុមតូច និងក្រុមធំ<br><br>**២. សិក្សាវិធី គន្លឹះ ល្បិច សកម្មភាព និងសម្ភារៈ** | ▪ រូបភាព<br>▪ វត្ថុពិត<br>▪ សម្តែងកាយវិការ<br>▪ បណ្ណព្យញ្ជនៈ<br>▪ បណ្ណស្រៈ<br>▪ បណ្ណព្យាង្គ<br>▪ បណ្ណពាក្យ<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត ខ្មៅដៃ<br>- ឧបករណ៍បញ្ចាំងស្លាយ | ១ម៉ោង | ១. សិក្ខាកាមប្រាប់បានថា កុមារស្គាល់តួអក្សរ ដោយផ្តើមចេញពីសូររបស់វា ដែលមានជាឈ្មោះ វត្ថុ សត្វ រុក្ខជាតិទីកន្លែង សកម្មភាព ជាដើម។<br><br>២. សិក្ខាកាមចេះប្រើវិធី និង |

| | | | | |
|---|---|---|---|---|
| **ការស្គាល់សូរ**<br>)ដែលជាឈ្មោះ វត្ថុ សត្វ រុក្ខជាតិទីកន្លែង សកម្មភាព<br>(......<br>**ការស្គាល់តួអក្សរ**<br>*តួព្យញ្ជនៈ តួស្រៈ ជើងព្យញ្ជនៈនិងសញ្ញាវណ្ណយុត្ត(*<br><br>**ការស្គាល់តួអក្សរនិងសូរ**<br>*តួព្យញ្ជនៈ តួស្រៈ ជើងព្យញ្ជនៈនិងសញ្ញាវណ្ណយុត្ត(* | ▪ ការងារក្រុម៖ សិក្ខាកាមប្រាប់វិធី គន្លឹះ ល្បិច សកម្មភាព និងសម្ភារៈ ដែលគ្រូធ្លាប់បានប្រើប្រាស់កន្លងមក ក្នុងការបង្រៀនស្គាល់សូរ តួអក្សរ និងសូរ<br>▪ អ្នកសម្របសម្រួលបង្ហាញសង្ខេប អំពីវិធី គន្លឹះ ល្បិច សកម្មភាព និងសម្ភារ<br>▪ ការងារក្រុម៖ ៦ក្រុម៖ ក្រុមមួយសិក្សាវិធីមួយ ទៅលើល្បិច គន្លឹះ សកម្មភាព និងសម្ភារ រួចរៀបចំត្រៀមធ្វើថ្នាក់និទស្សន៍<br><br>**៣. អនុវត្តបង្រៀនបង្ហាញ (ថ្នាក់និទស្សន៍)៖ ៦ក្រុម**<br>▪ ក្រុមនីមួយៗ អនុវត្តន៍ជាមួយសិស្សបង្ហាញ<br>▪ យោបល់ និងពត៌មានត្រឡប់របស់ក្រុមធំ<br>**៤. សង្ខេបឡើងវិញ** | (LCD)<br>- វីដេអូ | ២ម៉ោង<br><br><br><br><br><br>២ម៉ោង | សម្ភារសម្រាប់បង្រៀនកុមារឱ្យចេះ **ពិនិត្យ និងស្គាល់ច្បាស់អំពី រូបរាង ទំហំ ទីតាំង និងទិសបញ្ឈរ របស់តួអក្សរ**) *ករណីបង្រៀនតួព្យញ្ជនៈ តួស្រៈ ជើងព្យញ្ជនៈ និងសញ្ញាវណ្ណយុត្ត(*<br><br>៣. គ្រូចេះវិធីក្នុងការនាំសិស្ស<br>▪ **បន្លឺសូររបស់តួអក្សរច្បាស់ៗ មួយៗ ច្រើនដង ជាគម្រូ ឱ្យសិស្សស្តាប់ រួចបន្លឺទាំងអស់គ្នា ជាមួយសិស្ស**<br>▪ **បន្លឺសូររបស់តួអក្សរ ច្រើនដង** ពីម្នាក់ទៅម្នាក់ ជាដៃគូ ជាក្រុមតូច និងជាជួរ ដោយមិនបាច់គ្រូជួយ។ |
| **ប្រកបព្យាង្គ**<br>**ករណី៖** *ព្យាង្គរាយ ព្យាង្គថ្មី និងសិស្សមិនទាន់ស្គាល់សូរ តួអក្សរ និងសូរ*<br>**ករណី៖** | ១. ការងារក្រុម៖ ពិភាក្សា និងប្រាប់សង្ខេបបទពិសោធន៍តាមក្រុម អំពីរបៀបបង្រៀនប្រកបព្យាង្គ<br>២. បង្ហាញលំហូរ ក្នុងការបង្រៀនប្រកបព្យាង្គ ដោយអ្នកសម្របសម្រួល<br>៣. សិក្សាវិធី គន្លឹះ ល្បិច សកម្មភាព និងសម្ភា | ▪ *រូបភាព*<br>▪ *វត្ថុពិត*<br>▪ *សម្តែងកាយវិការ*<br>▪ បណ្ណព្យញ្ជនៈ | ៣ម៉ោង | គ្រូដែលជាសិក្ខាកាម ចេះប្រើប្រាស់ វិធី និងល្បិច ក្នុងការនាំសិស្ស ប្រកបសូរនៅក្នុងព្យាង្គតាមសូររបស់តួអក្សរ សូរ «អ.អ៊. និងសញ្ញាវណ្ណយុត »។ |

| | | | | |
|---|---|---|---|---|
| 1. គ្រូនិងសិស្សបាន កំណត់ព្យាង្គ ដែល ត្រូវសិក្សារួចហើយ<br>2. សិស្សបានស្គាល់សូរ របស់ព្យាង្គ ដែលអាច) ជាឈ្មោះរបស់ វត្ថុ សត្វ រុក្ខជាតិ ទីកន្លែង ដែលត្រូវ (ឬសកម្មភាព សិក្សារួចហើយ<br>3. សិស្សបានស្គាល់រួច ហើយ នូវតួអក្សរ ទាំងអស់នៅក្នុង ព្យាង្គដែលត្រូវសិក្សា<br>4. សិស្សបានរកសូរ ដើមនៃព្យាង្គ ឬពាក្យ<br>5. សិស្សបានរកសូរ ដើម សូរបន្ទាប់ និង) (សូរចុង នៅក្នុង ព្យាង្គ | រៈ<br>▪ ការងារក្រុម៖ ប្រាប់វិធី គន្លឹះ ល្បិច សកម្មភាព និងសម្ភារៈ ដែលខុសពីអ្វីដែល គ្រូធ្លាប់បានប្រើប្រាស់កន្លងមក<br>▪ ពន្យល់សង្ខេបរបស់អ្នកសម្របសម្រួល អំពីវិធី គន្លឹះ ល្បិច សកម្មភាព និងសម្ភារ ដែលថ្មីសម្រាប់សិក្ខាកាម<br>▪ ការងារក្រុម៖ ក្រុមមួយសិក្សាវិធីមួយ ទៅ លើល្បិច គន្លឹះ សកម្មភាព និងសម្ភារ រួច រៀបចំត្រៀមធ្វើថ្នាក់និទស្សន៍<br>៣. អនុវត្តបង្រៀនបង្ហាញ (ថ្នាក់និទស្សន៍)៖<br>▪ យោបល់ និងពត៌មានត្រឡប់របស់ក្រុមធំ<br>៤. សង្ខេបឡើងវិញ | ▪ បណ្ណស្រៈ<br>▪ បណ្ណព្យាង្គ<br>▪ បណ្ណពាក្យ<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត ខ្មៅដៃ<br>- ឧបករណ៍ បញ្ចាំងស្លាយ (LCD)<br>- វីដេអូ | | |

# គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

## មេរៀនទី៧៖ **វិធីសាស្ត្របង្រៀនកុមារខ្សោយបញ្ញា** សម្រាប់រយៈពេល៖ ៨ម៉ោង

| ខ្លឹមសារសំខាន់ៗ<br>Key Content of the Topic | វិធីសាស្ត្រ និងសកម្មភាពបង្រៀន<br>Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន<br>Training/Teaching Materials | រយៈពេលបង្រៀន<br>Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា<br>Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| ❖ វិធីសាស្ត្របង្រៀនកុមារមានបញ្ហាខ្សោយបញ្ញា<br><br><br><br><br><br>❖ ការប្រើប្រាស់មូលដ្ឋានគ្រឹះនៃការបង្រៀនខ្សោយសតិបញ្ញា | ❖ អ្នកសម្របសម្រួលបែងចែកសិក្ខាកាម៖ ឱ្យសិក្ខាកាមអានវិធីសាស្ត្របង្រៀនចំនួន១៨នៅក្នុងឯកសារជំនួយទំព័រ១០៧, ១០៨<br>❖ ឱ្យជ្រើសរើសមួយចំណុចរបស់វិធីសាស្ត្របង្រៀនមានចំនួន១៨ចំណុចយកមកពិភាក្សា (ក្រុមពិភាក្សារួចឡើងធ្វើការសម្តែងតួ) (ឯកសារក្នុងមេរៀនវិធីសាស្ត្របង្រៀន)<br>❖ អ្នកធ្លាប់ដឹងថាសិស្សនៅក្នុងថ្នាក់របស់អ្នកមានបញ្ហាខ្សោយបញ្ញាដែរឬទេ?<br>❖ បើមាន អ្នកមានយកវិធីសាស្ត្រណាមកបង្រៀនសិស្សខ្សោយបញ្ញាដែរឬទេ?<br>❖ លើកជាឧទាហរណ៍<br>❖ សំយោគចម្លើយ៖<br>• ពីងាយស្រួលទៅលំបាក<br>• ពីអរូបី ទៅពាក់កណ្តាលអរូបី<br>• ពីពាក់កណ្តាលរូបីទៅអរូបី<br>• អនុវត្តជាក់ស្តែង | - សក.<br>- ក្រដាសផ្ទាំងធំ ហ្វឺត ...<br><br><br><br><br><br>- LCD<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត | - ១ម៉ោង<br><br><br><br><br><br><br>- ១ម៉ោង | - សិក្ខាកាមយល់ និងអាចបង្ហាញពីវិធីទាំង១៨ចំណុច<br><br><br>- ប្រាប់បានពីវិធីសាស្ត្រទាំង៤ |
| ❖ វិធីបង្រៀន៖<br>1. សកម្មភាពលំនាំគំរូរបាង<br>- សិស្សចង់ហូបទឹក | ❖ សំណួរផ្ទាល់មាត់ទៅសិក្ខាកាម<br>- តើអ្នកធ្លាប់ឮពាក្យលំនាំគំរូរបាងដែរឬទេ? | - រូបភាពដបទឹក និងកែវទឹក | - ២ម៉ោង | - គ្រូយល់ពីគំរូរបាង<br>- គ្រូចេះប្រើវិធីគំរូរបាង |

| | | | | |
|---|---|---|---|---|
| | - លើកជាឧទាហរណ៍ដល់សិក្ខាកាមៈ<br>• កុមារចង់ហូប**ទឹក**<br>មកពីការនិយាយរបស់គាត់ មិនច្បាស់ឮតែ "**ទ**" ប្រើការលើកទឹកចិត្តថាកូននិយាយបានល្អ ចឹង គ្រូសុំឱ្យកូននិយាយឱ្យខ្លាំងដើម្បីឱ្យមិត្តភក្តិយើងបានឮកាន់តែច្បាស់។<br>- គ្រូនិយាយបញ្ជាក់ "**ទឹក**" ឱ្យស្តាប់ និងសិស្សទាំងអស់គ្នាអានតាមពាក្យ "**ទឹក**" | - ដបទឹក កែវទឹក<br>- ល្បះពាក្យ<br>- រូបភាពមនុស្សហូបទឹក | | |
| 2. សកម្មភាពការនាំមុខ<br>- កុមារត្រូវការជំនួយក្នុងការកាន់ដៃ | ❖ គ្រូបង្ហាញពីពាក្យ "ការនាំមុខ"<br>❖ គ្រូអនុវត្តជាសកម្មភាព សម្តែងតួ<br>❖ ឧទាហរណ៍ ៖ គ្រូកាន់សិស្សមានបញ្ហាខ្សោយបញ្ញាឱ្យសរសេរអក្សរជាពាក្យ "យើង ចាំ និងខាំ" | - បណ្ណពាក្យ<br>- ក្តារឆ្នួន<br>- ហ្វឺត ដីស<br>- រូបភាព | - ២ម៉ោង | - គ្រូយល់ពីវិធីប្រើការនាំមុខដោយការសម្តែងតួ |
| 3. សកម្មភាពការផ្តល់គំរូ<br>- កុមារចង់ឃើញសកម្មភាពគ្រូដុសធ្មេញ | ❖ គ្រូអនុវត្តសកម្មភាពជាក់ស្តែងពីការដុសធ្មេញ<br>- គ្រូធ្មេញឱ្យសិស្សសង្កេតជាក់ស្តែង<br>- សិស្សចូលរួមអនុវត្តជាក់ស្តែងទាំងអស់គ្នា | - ថ្នាំដុសធ្មេញ ទឹក កែវទឹក កន្សែង | - ១ម៉ោង | - គ្រូយល់ពីសកម្មភាពការផ្តល់គំរូតាមរយៈការអនុវត្តជាក់ស្តែង<br>- គ្រូយល់ពីសកម្មភាពជួយសិស្សតាមលំដាប់លំដោយ |
| 4. សកម្មភាពលំដាប់ដោយ<br>- កុមារចង់ឱ្យគ្រូបង្ហាញពីសកម្មភាពងូតទឹក | ❖ គ្រូបង្ហាញសកម្មភាពតាមលំដាប់លំដោយងូតទឹក<br>- គ្រូបង្ហាញរូបភាពពីសកម្មភាពងូតទឹក<br>- គ្រូធ្វើសកម្មភាពពីរបៀបងូតទឹក<br>- ឱ្យសិស្សបង្ហាញពីសកម្មភាពងូតទឹកពី២ ទៅ ៣ | - កន្សែង សាប៊ូ កាទឹក ធុងទឹក<br>- រូបភាពទាក់ទងនឹងសកម្មភាពងូតទឹក | - ១ម៉ោង | |

| | | | | |
|---|---|---|---|---|
| | នាក់ម្តង | - ល្បះពាក្យ ឬពាក្យ | | |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិននិងខ្លឹមសារមេរៀន** : **វិធីបង្រៀនកុមារខ្សោយបញ្ញា**

**វិធី និងសកម្មភាពបង្រៀន** : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្តែងតួ ករណីសិក្សា បង្ហាញវីដេអូ រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖ **ចំណេះដឹង**

សិក្ខាកាមយល់អំពីវិធីសាស្ត្រជួយកុមារការខ្សែយបញ្ញា តាមរយៈសំនួរបំផុស ឧទាហរណ៍ រូបភាព បណ្ណពាក្យ បានត្រឹមត្រូវ។

៖ **បំណិនសម្បទា**

សិក្ខាកាមមានបំណិនងាយៗក្នុងការជួយកុមារខ្សោយបញ្ញា។

៖ **ចរិយាសម្បទា**

សិក្ខាកាមដែលជាគ្រូ បានជួយកុមារខ្សោយបញ្ញា បានចំនួន................នាក់ នៅក្នុងថ្នាក់របស់គាត់ ។

**សម្ភារបង្រៀន** ៖

- បណ្ណពាក្យ
- បណ្ណរូបភាព
- អក្សរចល័ត
- រូបភាពពិត សៀវភៅណែនាំ វីដេអូ
- ការសម្តែងតួ

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|

| | | |
|---|---|---|
| ❖ អ្នកសម្របសម្រួលបែងចែកសិក្ខាកាម ជាក្រុម | ❖ វិធីសាស្ត្របង្រៀនកុមារមានបញ្ហាខ្សោយបញ្ញា<br>▪ ខ្លឹមសារ និងកិច្ចការ ត្រូវស្របនឹងសមត្ថភាពជាក់ស្តែងរបស់សិស្ស<br>▪ រៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងវិធីបង្រៀនបន្ថែម សម្រាប់ជួយសិស្សដែលមាន ការលំបាកទាំងនេះ។<br>▪ ជ្រើសរើសសកម្មភាព ស្របតាមចំណង់ចំណូលចិត្ត និងកម្រិតសមត្ថភាពជាក់ស្តែងរបស់សិស្ស។<br>▪ ប្រើវិធីលើកទឹកចិត្ត និងផ្តល់រង្វាន់<br><br>ទាំងនេះហៅថាវិធីជួយសិស្សរៀនយឺត ដែលមានសកម្មភាព ជាច្រើនដូចជា៖<br>✓ មានអ្នកជួយក្នុងពេលរៀន(ជួយអាន ជួយសរសេរ ជួយពន្យល់ ជួយគិត ...។ល។)<br>✓ បន្ថែមម៉ោងពេលសិក្សា<br>✓ បន្ថែមសម្ភារ រូបភាព ល្បែងជាជំនួយ<br>▪ ប្រើសកម្មភាព និងល្បែងចងចាំឱ្យបានរាល់ថ្ងៃ<br>▪ ប្រើវិធីបង្រៀន ស្គាល់តួអក្សរ សូរ ផ្សំសូរ ញែកសូរ សូរដូច និងវាក្យស័ព្ទ តាមរបៀបបរិយាបន្ន<br>ប្រើវិធីអានត្រឹមត្រូវ ស្ទាត់ និងយល់ន័យ តាមរបៀបបរិយាបន្ន។<br><br>វិធីសាស្ត្របង្រៀនមានចំនួន១៨ចំណុច៖<br>1. បង្ហាញអំពីខ្លឹមសារសំខាន់ៗតាមលំដាប់ | ❖ ឱ្យសិក្ខាកាមអានវិធីសាស្ត្របង្រៀនចំនួន ១៨នៅក្នុងឯកសារជំនួយ**ទំព័រ១០៧, ១០៨** ។<br>❖ ឱ្យជ្រើសរើសមួយចំណុចនូវវិធីសាស្ត្របង្រៀនមានចំនួន១៨ចំណុចយកមកពិភាក្សា (ក្រុមពិភាក្សារួចឡើងធ្វើការសម្តែងតួ) (ឯកសារក្នុងមេរៀនវិធីសាស្ត្របង្រៀន) |

| | | |
|---|---|---|
| | លំដោយនៃមេរៀនដែលត្រូវរៀន និងបង្រៀន ដោយបញ្ជាក់ពីគោលគំនិតសំខាន់ និងផ្តល់ឱកាសសម្រាប់ការអនុវត្តន៍ជាក់ស្តែងនូវជំនាញ និងគោលគំនិតថ្មីៗ។<br>2. ផ្តល់ឯកសារ ឬមេរៀនឱ្យបានច្បាស់លាស់មុនពេលចាប់ផ្តើមបង្រៀនដើម្បីឱ្យពួកគេបានអានជាមុន។<br>3. ផ្តល់ឯកសារ ឬមេរៀនជាផ្នែកៗ និងណែនាំដល់សិស្ស ពីរបៀបអានឯកសារ ឬមេរៀនគន្លឹះឱ្យបានស៊ីជម្រៅ ប្រសើរជាងឱ្យពួកគេសិក្សាឯកសារ ឬមេរៀនទូទៅច្រើន។<br>4. គ្រូត្រូវណែនាំសិស្សឱ្យបានច្បាស់ តាមលំដាប់លំដោយ ទាំងការនិយាយពន្យល់ ការសរសេរ និងការអនុវត្ត ។ ឧទាហរណ៍ ពេលធ្វើលំហាត់ ធ្វើពិសោធន៍ ឬប្រើប្រាស់កុំព្យូទ័រ ។<br>5. សិស្សអាចរៀនបានច្រើន និងទទួលបានលទ្ធផលកាន់តែល្អ ប្រសិនបើមានការប្រើប្រាស់បច្ចេកវិទ្យាជំនួយ។<br>6. ប្រើប្រាស់ការពិពណ៌នាជាពាក្យសម្តីឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីបន្ថែមទៅលើខ្លឹមសារឯកសារ ឬមេរៀននានាដែលបានបង្ហាញនៅលើក្តារខៀន ឬផ្ទាំងរូបភាព។<br>7. ប្រើភាសាដែលមានលក្ខណៈខ្លី ច្បាស់ និងងាយយល់។<br>8. ពង្រឹងការរៀនសូត្រ ដោយប្រើប្រាស់ | |

| | | |
|---|---|---|
| | ឧទាហរណ៍ជាក់ស្តែង និងផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ។<br>9. បង្ហាញព័ត៌មានទៅតាមទម្រង់ផ្សេងៗដូចជា ឯកសារ សន្លឹកកិច្ចការ ផ្ទាំងរូបភាព វីដេអូ ដើម្បីឱ្យឆ្លើយតបទៅនឹងរបៀបនៃការរៀនខុសៗគ្នារបស់កុមារ។<br>10. ប្រើប្រាស់វិធីបង្រៀនផ្សេងៗ ដើម្បីឱ្យសិស្សទទួលបានព័ត៌មានដោយមិនចាំបាច់តែតាមរយៈការអានតែមួយមុខប៉ុណ្ណោះ។ ចូរប្រើប្រាស់ តារាង ដ្យាក្រាម បញ្ជីក្រាប គោលគំនិតជាដើម សម្រាប់បង្ហាញខ្លឹមសារមេរៀនដល់សិស្ស។<br>11. រៀបចំដ្យាក្រាមឱ្យមានរបៀបរៀបរយ និងប្រើប្រាស់ពណ៌ដែលសមស្របដើម្បីបង្ហាញពីភាពខុសគ្នា និងបញ្ជាក់ពីចំណុចសំខាន់ៗ។<br>12. ត្រូវប្រាកដថា មានបញ្ជីពាក្យបច្ចេកទេសដែលសិស្សចាំបាច់ត្រូវរៀនមុនពេលបង្រៀន។<br>13. គ្រូត្រូវមានកំណត់ត្រា និងផែនការជួយសិស្សទាំងឡាយដែលមានបញ្ហាក្នុងការសរសេរ ការស្តាប់ និងការផ្ទង់អារម្មណ៍។<br>14. សិស្សអាចចាប់បានខ្លឹមសារមេរៀនត្រឹមត្រូវតាមលំដាប់លំដោយ ប្រសិនបើពួកគេបានអាននិងសិក្សាមេរៀននោះ លើសពី១ដង។<br>15. បញ្ជាក់សារឡើងវិញចំពោះឃ្លា និងការណែនាំសំខាន់ៗក្នុងពេលបង្រៀន ។ | |

| | | |
|---|---|---|
| | 16. ការបង្រៀនជាលក្ខណៈបុគ្គលមានសារៈសំខាន់ រួមទាំងមិត្តអប់រំមិត្តផងដែរ ។<br>17. សិស្សអាចផ្តល់ចម្លើយតាមរយៈពាក្យសម្តីជាជាងជាលាយលក្ខណ៍អក្សរ សម្រាប់កិច្ចការសំណេររបស់ពួកគេ ។<br>18. ការណែនាំជាលក្ខណៈបុគ្គលមានប្រយោជន៍សម្រាប់សិស្សខ្សោយបញ្ញាអំពីការប្រើឧបករណ៍ក្នុងមន្ទីរពិសោធន៍ ឬកុំព្យូទ័រ ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់កុមារ។ | |
| ❖ អ្នកធ្លាប់ដឹងថាសិស្សនៅក្នុងថ្នាក់របស់អ្នកមានបញ្ហាខ្សោយបញ្ញាដែរឬទេ ?<br>❖ គ្រូបង្ហាញពីពាក្យ "ការនាំមុខ"<br>- គ្រូអនុវត្តជាសកម្មភាព សម្តែងតួ<br>- បើមាន អ្នកយកវិធីសាស្រ្តណាមកបង្រៀនសិស្សខ្សោយបញ្ញាដែរឬទេ ?<br>- លើកជាឧទាហរណ៍ | - ការប្រើប្រាស់មូលដ្ឋានគ្រឹះនៃការបង្រៀនខ្សោយបញ្ញា។<br>❖ សំយោគចម្លើយ៖<br>• ពីងាយស្រួលទៅលំបាក<br>• ពីរូបី ទៅពាក់កណ្តាលអរូបី<br>• ពីពាក់កណ្តាលរូបីទៅអរូបី<br>• អនុវត្តជាក់ស្តែង | ❖ សង្កេតមើលការរបស់អនុវត្តជាសកម្មភាពសម្តែងតួ<br>❖ លើកជាឧទាហរណ៍មកបង្ហាញ<br>❖ ធ្វើសកម្មភាព សម្តែងតួ |
| ❖ គ្រូអនុវត្តសកម្មភាពជាក់ស្តែងដូចជា ហូបទឹកដុសធ្មេញ<br>- គ្រូដុសធ្មេញឱ្យសិស្សសង្កេតជាក់ស្តែង សិស្សចូលរួមអនុវត្តជាក់ស្តែងទាំងអស់គ្នា | ❖ វិធីបង្រៀន៖<br><br>1. សកម្មភាពលំនាំគំរូរូបរាង<br>- សិស្សចង់ហូបទឹក<br>2. សកម្មភាពការនាំមុខ<br>- កុមារត្រូវការជំនួយក្នុងការកាន់ដៃ<br>3. សកម្មភាពការផ្តល់គំរូ | ❖ សង្កេតមើលការអនុវត្តជាសកម្មភាពសម្តែងតួ<br>❖ លើកជាឧទាហរណ៍មកបង្ហាញ ធ្វើសកម្មភាព សម្តែងតួ |

| | | |
|---|---|---|
| | - កុមារចង់ឃើញសកម្មភាពគ្រូដុសធ្មេញ<br>4. សកម្មភាពលំដាប់ដោយ<br>កុមារចង់ឱ្យគ្រូបង្ហាញពីសកម្មភាពងូតទឹក | |

# គម្រោងលំនាំបង្រៀន/បណ្តុះបណ្តាល

មេរៀន៧៖ **វិធីសាស្រ្តបង្រៀនកុមារមានអូទីសឹម** សម្រាប់រយៈពេល **ចំនួន១ថ្ងៃ**

| ខ្លឹមសារសំខាន់ៗ<br>Key Content of the Topic | វិធីសាស្រ្ត និងសកម្មភាពបង្រៀន<br>Method & Activities to be Used in Teaching/Training | សម្ភារបង្រៀន<br>Training/Teaching Materials | រយៈពេលបង្រៀន<br>Duration for training/teaching | លទ្ធផលរំពឹងទុកបន្ទាប់ពីការសិក្សា<br>Expected Learning outcomes from the training/teaching |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ❖ វិធីសាស្ត្របង្រៀនកុមារមានអូទីសឹម | អ្នកសម្របសម្រួលបែងចែកសិក្ខាកាមៈ ឱ្យសិក្ខាកាមអានវិធីសាស្ត្របង្រៀនចំនួន១៥នៅក្នុងឯកសារជំនួយ។<br>❖ ឱ្យសិក្ខាកាមជ្រើសរើសមួយចំណុចរបស់វិធីសាស្ត្របង្រៀនមានចំនួន១៥ចំណុចយកមកពិភាក្សា (ក្រុមពិភាក្សារួចឡើងធ្វើការសម្ដែងតួ) (ឯកសារក្នុងមេរៀនវិធីសាស្ត្របង្រៀន) ដូចជាៈ<br>○ ការរៀបចំថ្នាក់ឱ្យសមស្របតាមខ្លឹមសារមេរៀន<br>○ ការប្រើកាលវិភាគបែបរូបភាព<br>○ ការរៀបចំកាលវិភាគឱ្យមានលក្ខណៈជាទម្លាប់ប្រចាំ<br>○ ការប្រើភាសាសាមញ្ញៗ មួយៗ និងងាយៗ<br>○ ...............................<br><br>❖ អ្នកធ្លាប់ដឹងថាសិស្សនៅក្នុងថ្នាក់របស់អ្នកមានអូទីសឹមដែរឬទេ?<br>❖ បើមាន អ្នកមានយកវិធីសាស្ត្រណាមកបង្រៀនសិស្សមានអូទីសឹមដែរឬទេ?<br>❖ លើកជាឧទាហរណ៍<br>❖ សំយោគចម្លើយៈ ឧទាហរណ៍ទូទៅដូចជា<br>• ពីងាយស្រួលទៅលំបាក<br>• ពីអរូបី ទៅពាក់កណ្ដាលអរូបី<br>• ពីពាក់កណ្ដាលរូបីទៅអរូបី<br>• អនុវត្តជាក់ស្ដែង | - ឯកសារមេរៀន<br>- ក្រដាសផ្ទាំងធំ<br>- LCD<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- សម្ដែងរឿង | - ៤ម៉ោង | - សិក្ខាកាមយល់ និងអាចបង្ហាញពីវិធីទាំង១៥ចំណុច<br><br>- សិក្ខាកាមសម្ដែងបានត្រឹមត្រូវតាមខ្លឹមសារការលំបាករបស់កុមារ និងវិធីជួយរបស់គ្រូ |

| | | | | |
|---|---|---|---|---|
| ❖ សកម្មភាពជាក់លាក់ សម្រាប់ជួយកុមារអូទីសឹម ទៅតាមលក្ខណៈសម្គាល់ផ្សេងៗគ្នារបស់កុមារ ដូចជា៖<br><br>▪ ករណីប្រើពាក្យមួយម៉ាត់ៗ<br>▪ ករណីមិនចូលចិត្តប្រើភាសានិយាយ<br>▪ ករណីមិនមានមិត្តភក្តិ<br>▪ ករណីមិនចូលចិត្តសកម្មភាពជាមួយមនុស្ស<br>▪ ........................ | ❖ ណែនាំសកម្មភាពទាំង៥ ដូចមាននៅក្នុងមេរៀន<br>❖ អ្នកសម្របសម្រួលអនុវត្តសម្តែង សកម្មភាពនីមួយៗ<br>❖ សិក្ខាកាមទាយ និងប្រាប់អំពី លក្ខណៈសម្គាល់ផ្សេងៗគ្នារបស់កុមារ រួចប្រាប់អំពីសកម្មភាពជួយ<br>❖ ការងារក្រុម៖<br>❖ ក្រុមនីមួយៗជ្រើសសកម្មភាពមួយ រួចហ្វឹកហាត់ និងរៀបចំសម្ភារ<br>❖ សិក្ខាកាមអនុវត្តជាថ្នាក់និទស្សន៍តាមក្រុម<br>❖ ពត៌មានត្រឡប់<br>❖ សង្ខេបឡើងវិញ | | - ៤ម៉ោង | សិក្ខាកាមបានជ្រើសរើសសកម្មភាពជួយត្រឹមត្រូវ សម្រប់ជួយកុមារតាមករណីផ្សេងៗគ្នា |

# មេរៀនទី១០ និង១១

# ការគ្រប់គ្រងថ្នាក់រៀន និងការគ្រប់គ្រងកុមារមានឥរិយាបថអាកប្បកិរិយា៖

- ការគ្រប់គ្រងថ្នាក់រៀន
- ការគ្រប់គ្រងកុមារមានវិបត្តិអាកប្បកិរិយា

## គម្រោងលំនាំបង្រៀន/បណ្ដុះបណ្ដាល

មេរៀនទី១០,១១៖ **ការគ្រប់គ្រងថ្នាក់រៀន** សម្រាប់រយៈពេល ១៥០នាទី

| ខ្លឹមសារសំខាន់ៗ<br>Key Content of the | វិធីសាស្ត្រ និងសកម្មភាពបង្រៀន<br>Method & Activities to be Used in | សម្ភារបង្រៀន<br>Training/Teaching | រយៈពេល<br>បង្រៀន | លទ្ធផលរំពឹងទុក<br>បន្ទាប់ពីការសិក្សា |
|---|---|---|---|---|

| Topic | Teaching/Training | Materials | Duration for training/teaching | Expected Learning outcomes from the training/teaching |
|---|---|---|---|---|
| ១.និយមន័យការគ្រប់គ្រងថ្នាក់រៀន | សំណួរ៖<br>- ដូចម្ដេចដែលហៅថាការ គ្រប់គ្រងថ្នាក់រៀន?<br>- ដើម្បីគ្រប់គ្រងថ្នាក់រៀនមួយឱ្យមានប្រសិទ្ធិភាព តើគ្រូត្រូវផ្តោតទៅលើអ្វីខ្លះ?<br>- ចូរបង្ហាញពីអត្ថប្រយោជន៍នៃការគ្រប់គ្រងថ្នាក់រៀនបានល្អ។<br>- គ្រូឧទ្ទេសកត់ចម្លើយនៅលើក្ដារខៀន<br>- គ្រូឧទ្ទេសបង្ហាញចម្លើយដោយឱ្យសិក្ខាកាមអានមេរៀនទី១០ ការគ្រប់គ្រងថ្នាក់រៀន( ទំព័រទី១៩៩ និង ២០០)។ | - ក្ដារខៀន<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ១៥នាទី | សិក្ខាកាមអាចប្រាប់បានពីនិយមន័យនៃការគ្រប់គ្រងថ្នាក់រៀន |
| ២-ភាពខុសគ្នារវាងកុមារា និងកុមារី | សំណួរ៖<br>- តើកុមារា និងកុមារីមានអាកប្បកិរិយាប្លែកខុសគ្នាយ៉ាងដូចម្ដេច?<br>- តើពេលធុញទ្រាន់ ឬអស់កម្លាំង កុមារាតែងតែធ្វើអ្វី?<br>- តើគ្រូត្រូវធ្វើដូចម្ដេចនៅពេលកុមារីម្នាក់មានភាពភ័យខ្លាចពេលឆ្លើយសំណួរ?<br>- គ្រូឧទ្ទេសកត់ចម្លើយនៅលើក្ដារខៀន<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | - ក្ដារខៀន<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ១៥នាទី | សិក្ខាកាមអាចកំណត់បានពីភាពខុសគ្នារវាងអាកប្បកិរិយារបស់កុមារា និងកុមារី |

| | | | | |
|---|---|---|---|---|
| ៣-និយមន័យរបស់ពាក្យ «វិន័យ» | សំណួរ៖<br>- ចូរឱ្យនិយមន័យនៃពាក្យ«វិន័យ» ដោយលើកឧទាហរណ៍មកបញ្ជាក់ចំនួន២។<br>- តើការដាក់ទណ្ឌកម្ម និងវិន័យមានភាពខុសគ្នាយ៉ាងដូចម្តេច?<br>- ហេតុអ្វីបានជាកុមារត្រូវដឹងរាល់សកម្មភាពដែលខ្លួនបានប្រព្រឹត្ត?<br>- គ្រូឧទ្ទេសកត់ចម្លើយនៅលើក្តារខៀន<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | - ក្តារខៀន<br>- ក្រដាសផ្ទាំង ធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ១៥នាទី | សិក្ខាកាមអាចយល់ដឹងពី«វិន័យ» និងអាចលើកឧទាហរណ៍បាន២ពីបទពិសោធក្នុងថ្នាក់រៀនរបស់គាត់ |
| ៤-និយមន័យ "ការផ្តល់ និងដករង្វាន់" | សំណួរ៖<br>- តើលោកគ្រូ អ្នកគ្រូធ្លាប់បានផ្តល់រង្វាន់ និងដករង្វាន់អ្វីដល់សិស្ស?ដោយលើកឧទារហ៍មកបញ្ជាក់។<br>- តើការផ្តល់រង្វាន់ និងការដករង្វាន់មានន័យដូចម្តេច?<br>- តើការផ្តល់រង្វាន់ និងការដករង្វាន់ត្រូវគិតទៅលើចំណុចអ្វីខ្លះ?<br>– ឱ្យសិក្ខាកាមសរសេរ និងបិទចម្លើយ<br>– គ្រូឧទ្ទេសបង្ហាញ | - ក្តារខៀន<br>- ផ្ទាំងក្រដាសធំ<br>- ក្រដាសរ៉ាម/ពណ៌<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ១៥នាទី | សិក្ខាកាមបានយល់ដឹង និង និងអនុវត្តបានការផ្តល់ និងការដករង្វាន់" |
| ៥-ការទទួល | - ឱ្យសិក្ខាកាម៥នាក់សម្តែងតួ ពីកំហុស | - ក្តារខៀន | ២៥នាទី | សិក្ខាកាមអាចយល់ដឹងពីការ |

| | | | | |
|---|---|---|---|---|
| ស្គាល់ សុំអភ័យទោស សំណង និងការផ្សះផ្សា | ឆ្លងជាមួយមិត្តរួមថ្នាក់ ការទទួលស្គាល់កំហុស និងដំណោះស្រាយ។<br>- សិក្ខាកាមក្រុមធំសង្កេត និងឆ្លើយសំណួរ៖<br>- ដូចម្តេចដែលហៅថាការទទួលស្គាល់ពីកំហុស?<br>- តើការទទួលស្គាល់ពីកំហុសមានអត្ថប្រយោជន៍អ្វីខ្លះ?លើកយកឧទាហរណ៍ចំនួន១មកបញ្ជាក់<br>- តើពេលណាដែល កុមារត្រូវប្រើពាក្យ « សុំអភ័យទោស»?<br><br>- ហេតុអ្វីបានជាកុមារត្រូវមានសំណងនៅពេលដែលគាត់មានអាកប្បកិរិយាអវិជ្ជមាន?<br>- តើការផ្សះផ្សាអាចដោះស្រាយអ្វីខ្លះចំពោះកុមារពេលជួបបញ្ហា?<br>- តើការផ្សះផ្សាគួរតែធ្វើឡើងជាលក្ខណៈដាច់ដោយឡែក ឬនៅជាសាធារណៈ?<br>- គ្រូឧទ្ទេសកត់ចម្លើយរបស់សិក្ខាកាមលើក្តារខៀន<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | - ក្រដាសផ្ទាំង ធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | | ទទួលស្គាល់ សុំអភ័យទោស សំណង ការផ្សះផ្សា និងរបៀបដោះស្រាយពេលសិស្សប្រព្រឹត្តកំហុស |

| | | | | |
|---|---|---|---|---|
| ៦-ប្រព័ន្ធគ្រប់គ្រងថ្នាក់រៀន ឬអាកប្បកិរិយា | សំណួរ៖<br>- តើប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាធ្វើឡើងដើម្បីអ្វី?<br>- តើគ្រូត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាអ្វីខ្លះសម្រាប់តាមដានអាកប្បកិរិយាសិស្ស?<br>- ចូរលើកយកឧទាហរណ៍មកបញ្ជាក់។<br>- គ្រូឧទ្ទេសកត់ចម្លើយរបស់សិក្ខាកាមលើក្ដារខៀន។<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | - ក្ដារខៀន<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ១០នាទី | សិក្ខាកាមយល់ដឹងពីរបៀបរៀបចំប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬ អាកប្បកិរិយា |
| ៧-ការសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមានជាមុន | សំណួរ៖<br>- ហេតុអ្វីបានជាត្រូវសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមានជាមុន?<br>- តើគ្រូត្រូវសរសើរកុមារដែលមានអាកប្បកិរិយាវិជ្ជមាននៅក្បែរ ឬ ឆ្ងាយពីកុមារដែលមានអាកប្បកិរិយាមិនសមរម្យ?សិក្ខាកាមអាចលើកឧទាហរណ៍បានចំនួន១។<br>- គ្រូឧទ្ទេសកត់ចម្លើយរបស់សិក្ខាកាមលើក្ដារខៀន។<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | - ក្ដារខៀន<br>- ក្រដាសផ្ទាំង ធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ១៥នាទី | សិក្ខាកាមបានយល់ច្បាស់ពីមូលហេតុនៃការសរសើរកុមារដែលមានអាកប្បកិរិយាវិជ្ជមាន ជាមុន |
| ៨-កៅអីសញ្ជឹង | សំណួរ៖ | - ក្ដារខៀន | | សិក្ខាកាមអាច យល់ពីវិធីប្រើ |

| | | | | |
|---|---|---|---|---|
| គិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម) | - តើកៅអីសញ្ជឹងគិតជាអ្វី?<br>- តើកៅអីសញ្ជឹងគិត(មានសារៈសំខាន់អ្វីខ្លះដល់កុមារ?<br>- តើអ្វីដែលគ្រូត្រូវប្រុងប្រយ័ត្ននៅពេលប្រើវិធីសាស្រ្តកៅអីសញ្ជឹងគិត)?<br>- គ្រូឧទ្ទេសកត់ចម្លើយរបស់សិក្ខាកាមលើក្តារខៀន។<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | - ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ១៨នាទី | ប្រាស់កៅអីសញ្ជឹងគិត |
| ៩-វិធីធ្វើឱ្យចិត្តស្ងប់ | - ឱ្យសិក្ខាកាមទាំងអស់អនុវត្តពីវិធីធ្វើឱ្យចិត្តស្ងប់ ដោយអង្គុយសមាធិរយៈពេល៥នាទី<br>សំណួរៈ<br>- តើអ្នកមានអារម្មណ៍យ៉ាងម៉េច?<br>- តើអ្វីជាវិធីធ្វើឱ្យចិត្តស្ងប់?<br>- គ្រូឧទ្ទេសកត់ចម្លើយរបស់សិក្ខាកាមលើក្តារខៀន<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | - ក្តារខៀន<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត<br>- ស្កុត<br>- កុំព្យូទ័រយួរដៃ<br>- LCD Projector | ២២នាទី | សិក្ខាកាមអាចបង្ហាញពីរបៀបធ្វើឱ្យចិត្តស្ងប់ |

## កិច្ចតែងការបង្រៀន/បណ្ដុះបណ្ដាល (សម្រាប់តែជំហានទី៣)

**ប្រធានបទ និងខ្លឹមសារមេរៀន** ៖ **និយមន័យនៃ ការគ្រប់គ្រងថ្នាក់រៀន**

**វិធី និងសកម្មភាពបង្រៀន** ៖ បំផុសសំណួរពិភាក្សាក្នុងក្រុមធំ និង បង្ហាញចម្លើយ

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖ **ចំណេះដឹងសម្បទា**៖

- សិក្ខាកាមយល់ច្បាស់អំពីការគ្រប់គ្រងថ្នាក់រៀន ដូចជា និយមន័យ និងវិធីផ្សេងៗនៃការគ្រប់គ្រងថ្នាក់រៀនមួយបានល្អ

៖**បំណិនសម្បទា**៖

- សិក្ខាកាមអាច ពិចារណាពីការគ្រប់គ្រងថ្នាក់រៀនរបស់ខ្លួន និងអនុវត្តការគ្រប់គ្រងថ្នាក់រៀនអាស្រ័យទៅតាមថ្នាក់រៀន និងអាកប្បកិរិយារបស់សិស្សម្នាក់ៗ ឱ្យកាន់តែមានប្រសិទ្ធិភាព

៖**ចរិយាសម្បទា**៖

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីរបៀបគ្រប់

គ្រងថ្នាក់រៀនសម្រាប់កូនរបស់គាត់ និងចែករំលែកវិធីសាស្ត្រមួយចំនួនដល់អាណាព្យាលសម្រាប់អនុវត្តនៅឯផ្ទះដើម្បីកាត់បន្ថយបញ្ហាអាកប្បកិរិយារបស់កូនគាត់។

**សម្ភារឧបទ្ទេស** ៖

- ក្តារខៀន
- ផ្ទាំងក្រដាសធំ
- ហ្វឺត
- ស្កុត
- កុំព្យូទ័រយួរដៃ
- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer´s Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees´ activities |
|---|---|---|
| ចែកសិក្ខាកាមជា៣ឬ៤ក្រុម ដាក់កិច្ចការទៅក្រុមនីមួយៗ៖<br>- ចូរលោកគ្រូ អ្នកគ្រូចែករំលែកបទពិសោធន៍នៃការគ្រប់គ្រងថ្នាក់រៀនដែលលោកគ្រូ អ្នកគ្រូបានអនុវត្តប្រចាំថ្ងៃក្នុងថ្នាក់រៀន។<br>- ដូចម្តេចដែលហៅថាការគ្រប់គ្រងថ្នាក់រៀន។<br>កត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្រដាសផ្ទាំង<br>បង្ហាញចម្លើយដល់សិក្ខាកាម | ការគ្រប់គ្រងថ្នាក់រៀនសំដៅលើជំនាញ និងប្រើវិធី ផ្សេងៗជាច្រើនដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីរៀបចំ កុមារឱ្យមានសណ្តាប់ធ្នាប់ យកចិត្តទុកដាក់ ចូលរួមក្នុងសកម្មភាព និងទទួលបានលទ្ធផលល្អក្នុងថ្នាក់រៀន។ | ការងារក្រុម៖<br>- ពិភាក្សាអំពីបទពិសោធន៍ដែលបានអនុវត្តកន្លងមក។<br>- ពិភាក្សាគ្នាអំពី ការគ្រប់គ្រងថ្នាក់រៀន<br>- ជ្រើសរើសតំណាងក្រុម<br>- ចែករំលែកបទពិសោធន៍ |
| - ចែកសិក្ខាកាមជា៣ឬ៤ក្រុមរួច | ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធិភាពគឺផ្តោតទាំងស្រុង | ការងារក្រុម៖ |

| | | |
|---|---|---|
| ដាក់សំណួរៈ<br>តើលោកគ្រូ អ្នកគ្រូត្រូវផ្តោតទៅលើអ្វីខ្លះ ដើម្បីគ្រប់គ្រងថ្នាក់រៀនមួយប្រកបដោយប្រសិទ្ធិភាព?<br>- ឱ្យសិក្ខាកាមកត់ត្រាចម្លើយដាក់លើក្រដាសផ្ទាំងធំ<br>បង្ហាញចម្លើយដល់សិក្ខាកាម | ទៅលើ«ការគោរពតាមបទបញ្ញត្តិនានា» រួមមាន ច្បាប់ វិក្រឹតការ និងយុទ្ធសាស្ត្រនានាដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីឱ្យសិស្សអង្គុយនៅតាមកន្លែង<br>ស្តាប់ការណែនាំ និងស្តាប់ដោយយកចិត្តទុកដាក់។ | - ពិភាក្សាគ្នា<br>- កត់ត្រាលើក្រដាសផ្ទាំងធំ<br>- ធ្វើបទបង្ហាញលទ្ធផល |
| បំផុសសំណួរក្នុងក្រុមធំ និងបង្ហាញ ៖<br><br>-ចូរបង្ហាញពីអត្ថប្រយោជន៍នៃការគ្រប់គ្រងថ្នាក់រៀនបានល្អ<br>កត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្រដាសផ្ទាំងធំ<br>បង្ហាញចម្លើយដល់សិក្ខាកាម | ការគ្រប់គ្រងថ្នាក់រៀនត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនអាចកាត់បន្ថយរាល់សកម្មភាពដែលប៉ះពាល់ដល់ការសិក្សារបស់កុមារម្នាក់ៗ ឬកុមារទាំងអស់ ប៉ុន្តែបង្កើនជាអតិបរមាចំពោះអាកប្បកិរិយាដែលជួយសម្របសម្រួល ឬពង្រឹងការសិក្សា។<br>- បរិយាកាសក្នុងថ្នាក់រៀនមានភាពរៀបរយ និងមានសោភណ្ឌភាពគួរចង់រៀន<br>- សិស្សមានវិន័យល្អ<br>- សិស្សយកចិត្តទុកដាក់ក្នុងការរៀនសូត្រ<br>- គ្រូងាយស្រួលក្នុងការគ្រប់គ្រងសិស្ស<br>- គ្រូចំណេញពេលវេលាក្នុងការបង្រៀន<br>- សិស្សកាត់បន្ថយបញ្ហាអាកប្បកិរិយារបស់សិស្សបាន<br>- សិស្សមានការផ្ចង់អារម្មណ៍បានប្រសើរ ជាហេតុធ្វើឱ្យលទ្ធផលនៃការសិក្សារបស់សិស្សបានល្អប្រសើរ | - ពិភាក្សា<br>- រាយការណ៍<br>- ស្តាប់ និងកត់ត្រា |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិន និងខ្លឹមសារមេរៀន** ៖ **ភាពខុសគ្នារវាងកុមារា និងកុមារី**

**វិធី និងសកម្មភាពបង្រៀន** ៖ ឧទ្ទេសបង្ហាញ បំផុសសំណួរក្នុងក្រុមធំ និងពិភាក្សាក្រុម

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖

**ចំណេះសម្បទា៖**

- សិក្ខាកាមយល់ច្បាស់អំពីភាពខុសគ្នាពីអាកប្បកិរិយារវាងកុមារា និងកុមារី

**បំណិនសម្បទា៖**

- សិក្ខាកាមអាចយល់ពីរបៀបដោះស្រាយ ឬការលើទឹកចិត្តដល់កុមារា និងកុមារីបានល្អប្រសើរក្នុងការអនុវត្តក្នុងថ្នាក់រៀនជាប្រចាំ

**ចរិយាសម្បទា៖**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីរបៀបដោះស្រាយ /លើកទឹកចិត្តកូនគាត់

**សម្ភារឧបទ្ទេស** ៖

- ក្ដារខៀន
- ក្រដាសផ្ទាំងធំ
- ហ្វឺត
- ស្កុត
- កុំព្យូទ័រយួរដៃ
- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| ឧទ្ទេសបង្ហាញ និងបំផុសសំណួរក្នុងក្រុមធំ ៖<br><br>តើកុមារា និងកុមារីមានអាកប្បកិរិយាខុសគ្នាយ៉ាងដូចម្ដេច?<br>- កត់ចម្លើយរបស់សិក្ខាកាម<br>- បង្ហាញចម្លើយដល់សិក្ខាកាម | កុមារាមានសកម្មភាពច្រើន ហើយចូលចិត្តដើរចុះឡើងចំណុចនេះហាក់ដូចជាធ្វើឱ្យពួកគេ « រពឹស »។សកម្មភាពរបស់កុមារាអាចធ្វើឱ្យពួកគេសកម្មជាង ដែលជំរុញឱ្យពួកគេកាន់តែសប្បាយរីករាយ ប៉ុន្តែវាមិនមែនជាបំណងរបស់ពួកគេទេ។<br><br>កុមារីមានទំនោរក្នុងការនិយាយស្ដីច្រើនជាងកុមារា ហើយចង់ជជែកជាមួយមិត្តភក្ដិរបស់ពួកគេនៅពេលដែលពួកគេជួបបញ្ហាអ្វីមួយ ។ វាមានន័យថាពួកគេត្រូវការចំណាយពេលយូរដើម្បី បញ្ចប់ការជជែកគ្នា ឬដើម្បីរក្សាភាពស្ងៀមស្ងាត់នៅពេលមួយសមរម្យ។<br>- កុមារា និងកុមារីចូលចិត្តលេងល្បែងខុសគ្នា។ឧទាហរណ៍៖កុមារាចូលចិត្តលេងឡាន លេងកាំភ្លើងជ័រ... ។ | - ពិភាក្សាគ្នា<br>- រាយការណ៍<br>- កត់ត្រាចម្លើយ<br>- អានឯកសារ |

| | | |
|---|---|---|
| | ចំណែកកុមារីចូលចិត្តលេង<br>- តុក្កតា បាយឡុកបាយឡ...<br>- កុមារារពឹសជាងកុមារី<br>- កុមារាភាគច្រើនសកម្មជាងកុមារី<br>- កុមារីភាគច្រើននិយាយច្រើនជាងកុមារា | |
| ចែកសិក្ខាកាមជា២ក្រុម ហើយសួរសំណួរៈ<br><br>តើនៅពេលធុញទ្រាន់ ឬអស់កម្លាំង កុមារាតែងតែធ្វើអ្វី? | នៅពេលកុមារាធុញទ្រាន់ អស់កម្លាំង និងត្រូវការការផ្លាស់ប្តូរសកម្មភាព ឬត្រូវការសម្រាក។ ការសម្រាកគឺមិនចាំបាច់ចំណាយពេលយូរនោះទេ ប៉ុន្តែគ្រាន់តែជាសកម្មភាព ឬ ការលេងកំសាន្តរយៈពេលខ្លីដែលអាចឱ្យពួកគេមានពេលវេលា ក្នុងការផ្លាស់ប្តូរ និងប្រមូលអារម្មណ៍ឡើងវិញបានប៉ុណ្ណោះ។<br>- កុមារាពេលធុញទ្រាន់ គាត់ មិនសូវនិយាយស្តី<br>- កុមារាពេលធុញទ្រាន់គាត់ មិនសូវនិយាយស្តី ហើយគេងគិត<br>- កុមារាពេលធុញទ្រាន់ គាត់មិនសូវនិយាយស្តី ហើយទ្រគោះ បោះបោក | ការងារក្រុម<br>- អានអត្ថបទ<br>- សង្ខេបខ្លឹមសារ<br>- រាយការណ៍ចម្លើយ |
| ចែកសិក្ខាកាមជា២ក្រុម ហើយសួរសំណួរៈ<br>- តើគ្រូត្រូវធ្វើដូចម្តេចនៅពេលកុមារីម្នាក់មានភាពភ័យខ្លាចពេលឆ្លើយសំណួរ?<br>- កត់ត្រាចម្លើយរបស់សិក្ខាកាមលើ | កុមារីមានភាពទន់ជ្រាយ និងភ័យខ្លាចក្នុងការផ្លាស់ប្តូរយោបល់ និងការឆ្លើយសំណួររបស់គ្រូក្នុងថ្នាក់ ដូច្នេះពួកគេអាចមានឥរិយាបទស្ងប់ស្ងាត់ ហើយគេត្រូវការការលើកទឹកចិត្ត ក្នុងការចូលរួម សកម្មភាពឱ្យមានប្រសិទ្ធិភាព ។<br>- ពេលកុមារីមានភាពភ័យខ្លាច លោកគ្រូ អ្នកគ្រូត្រូវនៅក្បែរជួយលើកទឹកចិតគាត់។ | ការងារក្រុម<br>- អានអត្ថបទ<br>- សង្ខេបខ្លឹមសារ<br>- រាយការណ៍ចម្លើយ |

| | | |
|---|---|---|
| ក្ដារខៀនឬ លើក្រដាសផ្ទាំងធំ<br>- បង្ហាញចម្លើយដល់សិក្ខាកាម | - នៅក្បែរគាត់ លួងលោម លើកទឹកចិត្ត និងផ្ដល់ភាពកក់ក្ដៅ។<br>- នៅក្បែរគាត់ លើកទឹកចិត្ត និងសួររកមូលហេតុ | |

## កិច្ចតែងការបង្រៀន/បណ្ដុះបណ្ដាល (សម្រាប់តែជំហានទី៣)

**ចំណេះដឹង និងខ្លឹមសារមេរៀន** ៖ **និយមន័យនៃពាក្យ«វិន័យ»**

**វិធី និងសកម្មភាពបង្រៀន** ៖ បទបង្ហាញ ពិភាក្សា ការងារក្រុម ឧទាហរណ៍បង្ហាញ ...

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖

**ចំណេះដឹង៖**

- សិក្ខាកាមយល់ច្បាស់អំពីវិន័យ

**បំណិនសម្បទា៖**

- សិក្ខាកាមអាចចែកដាច់ពីការដាក់ទណ្ឌកម្ម និងវិន័យ
- សិក្ខាកាមអាចអនុវត្តវិធីសាស្ត្រវិន័យនេះនៅក្នុងថ្នាក់រៀនជាមួយសិស្ស

**ចរិយាសម្បទា៖**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីអ្វីដែលលោកគ្រូ អ្នកគ្រូបានធ្វើជាមួយកូនគាត់ និងអាចចែករំលែកវិធីសាស្ត្រមួយចំនួននៃបច្ចេកទេសនេះយកទៅអនុវត្តជាមួយកូននៅផ្ទះដើម្បីជួយកុមារឱ្យកាត់បន្ថយនូវអាកប្បកិរិយា /ការប្រព្រឹត្តដែលមិនសមរម្យ។

**សម្ភារឧបទេស** ៖

- ក្ដារខៀន
- ផ្ទាំងក្រដាសធំ
- ហ្វឺត
- ស្កុត
- កុំព្យូទ័រយួរដៃ
- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer´s Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees´ activities |
|---|---|---|
| បំផុសសំណួរទៅក្រុមធំ<br><br>ចូរឱ្យនិយមន័យនៃពាក្យ«វិន័យ»<br><br>ឱ្យសិក្ខាកាមលើកឧទាហរណ៍មួយចំនួនទាក់ទងនឹងវិន័យ៖<br>- កត់ចម្លើយរបស់សិក្ខាកាមលើក្រដាសផ្ទាំងធំ<br>- បង្ហាញចម្លើយដល់សិក្ខាកាម | វិន័យគឺជា«ការបណ្ដុះបណ្ដាលដែលអាចកែប្រែ បំពាក់បំប៉ន ឬធ្វើឱ្យប្រសើរឡើងនូវបញ្ញាស្មារតី និងចរិតលក្ខណៈផ្នែកក្រមសីធម៌» ។ ពាក្យថា «Pupil» កើតចេញមកពីពាក្យឡាតាំងដែលមានន័យថាសិស្សសាលា ។ ពាក្យវិន័យនេះកើតចេញមកពីពាក្យឡាតាំង «Discipline»ដែល មានន័យថា «ការណែនាំ ការបង្រៀន ការរៀន និងចំណេះដឹង»។<br><br>វិន័យគឺផ្ដោតច្រើនទៅលើការអប់រំបណ្ដុះបណ្ដាលផ្នែកអាកប្បកិរិយាឱ្យបានសមរម្យ និងទៅតាមការរំពឹងទុក ។ វិន័យសំដៅទៅលើ "ការបង្រៀន" និង "ការទូន្មាន" ឬ "ការណែនាំ» ។ ដូច្នេះ វាគឺជាលំនាំមួយ ដែលមានទំនាក់ទំនងទៅនឹងការយល់ដឹង និងការរីកលូតលាស់ប្រកបដោយលទ្ធផលជាវិជ្ជមាន និងអវិជ្ជមាន។ វាអាចជួយកែប្រែសិស្សតាមរយៈការណែនាំជាគំរូ និងការទូន្មាន។<br>- វិន័យ គឺច្បាប់មួយត្រូវឱ្យអនុវត្តតាម<br>- វិន័យ គឺឱ្យទទួលស្គាល់នូវអ្វីដែលយើងបានកំណត់រួចហើយ | - ផ្ដល់ចម្លើយ<br>- លើកឧទាហរណ៍បង្ហាញ |

| | | |
|---|---|---|
| | - វិន័យ គឺជាក្រឹត្យក្រមដែលបានតាក់តែងឱ្យមនុស្សអនុវត្តតាម<br>ឧទាហរណ៍៖<br>១-ត្រូវចូលរៀននៅម៉ោង៧ព្រឹក<br>២-ត្រូវស្លៀកពាក់ឯកសណ្ឋានសិស្ស<br>៣-ត្រូវស្តាប់តាមការណែនាំរបស់លោកគ្រូ អ្នកគ្រូ | |
| ចែកសិក្ខាកាមជា៣ទៅ៤ក្រុម ហើយសួរ ៖<br>តើការដាក់ទណ្ឌកម្ម និងវិន័យមានភាពខុសគ្នាយ៉ាងដូចម្តេច?<br>- ចែកក្រដាសផ្ទាំងដល់ក្រុម<br>- ឱ្យក្រុមលើកបង្ហាញ<br>- បង្ហាញចម្លើយដល់សិក្ខាកាម | ការដាក់ទណ្ឌកម្មគឺជា «ការធ្វើឱ្យឈឺចាប់ ឬជាការដាក់ទោសចំពោះការប្រព្រឹត្តកំហុស» ហើយជាទូទៅទាក់ទងនឹងការដាក់ទោសធ្ងន់ធ្ងរ ឬផលវិបាកធ្ងន់ធ្ងរដែលបង្កឱ្យមានការភ័យខ្លាច និងជាការបំពាន ។ ផ្ទុយទៅវិញ វិន័យគឺជា«ការបណ្តុះបណ្តាលដែលអាចកែប្រែ បំពាក់បំប៉ន ឬធ្វើឱ្យប្រសើរឡើងនូវបញ្ញាស្មារតី និងចរិតលក្ខណៈផ្នែកក្រមសីធម៌» ។<br>- ការដាក់ទណ្ឌកម្មគឺធ្ងន់ធ្ងរ ដល់ផ្លូវកាយ ផ្លូវចិត្ត<br>- វិន័យ គឺមានលក្ខណៈស្រាល ជាងដាក់ទណ្ឌកម្ម។ វិន័យគ្រាន់តែជា ការណែនាំ ឬអប់រំ។ | ការងារក្រុម<br>- សរសេរចម្លើយលើក្រដាសផ្ទាំងធំ<br>- ជ្រើសរើសតំណាងម្នាក់ដើម្បីរាយការណ៍<br>- តំណាងក្រុមឡើងរាយការណ៍ |
| បំផុសសំណួរក្នុងក្រុមធំ ៖<br>ហេតុអ្វីបានជាកុមារត្រូវដឹងរាល់សកម្មភាពប្រព្រឹត្តរបស់ខ្លួន?<br>ឱ្យសិក្ខាកាមពិភាក្សាជាមួយដៃគូ<br>ផ្តល់ចម្លើយដល់សិក្ខាកាម | ដើម្បីដឹងថា៖ បើកុមារ ប្រព្រឹត្តខ្លួនឱ្យបានសមស្រប មានភាពអត់ធ្មត់ និងសុភាពរាបសារ នោះនឹងទទួលបានលទ្ធផលវិជ្ជមាន ប៉ុន្តែប្រសិនបើកុមារប្រព្រឹត្ត នូវអ្វីដែលមិនល្អ គ្មានភាពអត់ធ្មត់ និងរពឹស  នោះពួកគេនឹងទទួលបានលទ្ធផលអវិជ្ជមានជាក់ជាមិនខាន។<br>- ដើម្បីឱ្យកុមារមានភាពទទួលខុសត្រូវនូវទង្វើរបស់ខ្លួន<br>- ដើម្បីប្រៀបធៀបនឹងលទ្ធផលដែលបានធ្វើហើយ<br>- ដើម្បីឱ្យអាចកែតម្រូវកំហុសឆ្គងក្នុងការប្រព្រឹត្តរបស់ខ្លួន | - ពិភាក្សាជាមួយដៃគូ<br>- ផ្តល់ចម្លើយដល់ក្រុមធំ |

| | | |
|---|---|---|
| | | |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិន និងខ្លឹមសារមេរៀន** ៖ **ការផ្តល់ និងដករង្វាន់**

**វិធី និងសកម្មភាពបង្រៀន** ៖ ឧទ្ទេសបង្ហាញ បំផុសសំណួរក្នុងក្រុមធំ និងលើកឧទាហរណ៍មកបញ្ជាក់

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖

**ចំណេះដឹង៖**

- សិក្ខាកាមយល់ច្បាស់អំពីការផ្តល់ និងដករង្វាន់

**បំណិនសម្បទា៖**

- សិក្ខាកាមអាចបែងចែកបានថាតើកុមារបែបណាដែលត្រូវផ្តល់រង្វាន់ និងកុមារបែបណាដែលត្រូវដករង្វាន់។
- សិក្ខាកាមអាចអនុវត្តបច្ចេកទេសការផ្តល់ និងដករង្វាន់ជាមួយសិស្សជាប្រចាំក្នុងថ្នាក់រៀន

**ចរិយាសម្បទា៖**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីបច្ចេកទេសការផ្តល់ និងដករង្វាន់ជាមួយកូននៅផ្ទះដើម្បីជួយកុមារឱ្យកាត់បន្ថយនូវអាកប្បកិរិយា /ការប្រព្រឹត្តដែលមិនសមរម្យ។

**សម្ភារឧបទេស** ៖

- ក្តារខៀន ក្រដាស ផ្ទាំងធំ ហ្វឺត ស្កុត
- កុំព្យូទ័រយួរដៃ
- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| សំណួរ៖<br>ចែកសិក្ខាកាមជា៣ ឬ៤ក្រុម៖<br><br>តើការផ្តល់ និងការដករង្វាន់មានន័យដូចម្តេច ?ចូរលើកលើកឧទាហរណ៍<br><br>កត់ត្រាចម្លើយរបស់សិក្ខាកាម<br>បង្ហាញចម្លើយដល់សិក្ខាកាម | ការផ្តល់រង្វាន់គឺជាផលប៉ះពាល់វិជ្ជមាន ដែលបានមកពីការប្រព្រឹត្តល្អ ចំណែកឯការដករង្វាន់គឺជាផលប៉ះពាល់អវិជ្ជមាន ឬការដាក់ពិន័យសម្រាប់ការប្រព្រឹត្តមិនល្អ ។<br>- ការផ្តល់រង្វាន់ គឺជាការលើកទឹកចិត្ត នៅពេលសិស្សស្តាប់បង្គាប់គ្រូ<br>- ការផ្តល់រង្វាន់ គឺជាការបង្ហាញប្រាប់ថាកុមារធ្វើបានល្អ<br>- ការផ្តល់រង្វាន់ គឺជាការផ្តល់កិត្តិយសដល់គាត់ ឬជាសារមួយប្រាប់កុមារឱ្យខិតខំ ឬធ្វើល្អបន្តទៀត<br>ឧទាហរណ៍៖ សមធ្វើកិច្ចការសាលាដែលគ្រូដាក់ឱ្យបានល្អ និងទាន់ពេលវេលា ។ គ្រូសរសើរ និងឱ្យសៀវភៅសរសេរមួយក្បាល។<br>- ការដករង្វាន់ គឺការបង្ហាញនូវការមិនពេញចិត្តនូវទង្វើដែលកុមារធ្វើ<br>- ការដករង្វាន់ គឺការបង្ហាញប្រាប់កុមារថាទង្វើដែលគាត់ធ្វើមិនបានល្អ ឬមិនជោគជ័យ<br>- ការដករង្វាន់ គឺជាវិន័យ<br>- ការដករង្វាន់ គឺជាការពញ្ញាក់ស្មារតីកុមារឱ្យប្រុងប្រយ័ត្ន | ចែកក្រុមពិភាក្សា៖<br>- ពិភាក្សាគ្នា<br>- រកឧទាហរណ៍តាមបទពិសោធន៍តាមក្រុម<br>- បង្ហាញចម្លើយដល់ក្រុមធំ |

| | | |
|---|---|---|
| | នូវទង្វើមិនល្អរបស់ខ្លួន<br>ឧទាហរណ៍៖ សមមិនបានធ្វើកិច្ចការសាលាដែលគ្រូដាក់ឱ្យទាន់ពេលវេលា ។ គ្រូណែនាំ និងដករង្វាន់ដែលបានឱ្យពីម្សិលមិញ។ | |
| សំណួរ៖<br><br>តើការផ្តល់ និងការដករង្វាន់ត្រូវគិតទៅលើចំណុចអ្វីខ្លះ?ចូរលើកឧទាហរណ៍មកបញ្ជាក់។<br>ឱ្យសិក្ខាកាមពិភាក្សាជាក្រុម បង្ហាញចម្លើយដល់សិក្ខាកាម | ការផ្តល់រង្វាន់ និងការដករង្វាន់ ត្រូវមាន៖<br>• ភាពសមស្របតាមអាយុ និងភេទរបស់សិស្ស<br>• សុវត្ថិភាព<br>• សង្គតិភាព (ស៊ីសង្វាក់គ្នា)<br>• ផ្តោតទៅលើអាកប្បកិរិយា មិនមែនផ្តោតទៅលើកុមារនោះទេ<br>- ការផ្តល់ និងការដករង្វាន់ត្រូវគិតទៅលើចំណុច៖<br>  ○ ការប្រព្រឹត្តរបស់កុមារ និងលទ្ធផលដែលគាត់ធ្វើបាន<br>  ○ គិតដល់អាយុកុមារ<br>  ○ ភេទ<br>  ○ សុវត្ថិភាព<br>ការផ្តល់រង្វាន់ និងដករង្វាន់ត្រូវកម្រិតនៃការប្រព្រឹត្ត ដើម្បីធានាថា៖<br>ក) អាកប្បកិរិយាខុសឆ្គងតិចតួច ឬមានលក្ខណៈរំភើបមិនគួរដោះស្រាយក្នុងលក្ខណៈធ្ងន់ធ្ងរពេកទេ<br>ខ) កុមារអាចមានឱកាសកែខ្លួន និងមិនប្រព្រឹត្តិអ្វីដែលខុសឆ្គងធ្ងន់ធ្ងរនោះឡើយ | - ពិភាក្សាក្រុម<br>- រកឧទាហរណ៍<br>- លើកបង្ហាញលទ្ធផលពិភាក្សាដល់ក្រុមធំ |

| | | |
|---|---|---|
| | គ) គ្រូផ្ដល់យោបល់ និងគាំទ្រ<br>ឃ) កុមារអាចទទួលស្គាល់ពីកម្រិតនៃការផ្ដល់ និងការដករង្វាន់ អាស្រ័យទៅលើការប្រព្រឹត្តិរបស់ពួកគេ | |

## កិច្ចតែងការបង្រៀន/បណ្ដុះបណ្ដាល (សម្រាប់តែជំហានទី៣)

**បំណិន និងខ្លឹមសារមេរៀន** : **ការទទួលស្គាល់ សុំអភ័យទោស សំណង និងការផ្សះផ្សា**

**វិធីសាស្ត្រ និងសកម្មភាព** : ឧទ្ទេសបង្ហាញ ពិភាក្សាក្រុម បំផុសសំណួរក្នុងក្រុមធំ និងលើកឧទាហរណ៍មកបញ្ជាក់

**លទ្ធផលរំពឹងទុកពីការសិក្សា** :

**ចំណេះដឹង:**

- សិក្ខាកាមយល់ច្បាស់អំពីការទទួលស្គាល់ សុំអភ័យទោស សំណង និងការផ្សះផ្សា

**បំណិនសម្បទា:**

- សិក្ខាកាមអាចយកចំណេះដឹងនេះទៅអនុវត្តជាមួយសិស្សផ្ទាល់ជាប្រចាំក្នុងថ្នាក់រៀន
- សិក្ខាកាមអាចវិភាគ និងអាចអនុវត្តវិធីនេះទៅតាមបញ្ហារបស់កុមារ

**ចរិយាសម្បទា:**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីដើម្បីអនុវត្តជាមួយកូនឱ្យគាត់ចេះទទួលស្គាល់ សុំអភ័យទោស សំណង និងផ្សះផ្សា។

**សម្ភារឧបទេស** :

- ក្ដារខៀន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត
- កុំព្យូទ័រយួរដៃ

- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| - ចែកសិក្ខាកាមជា៣ក្រុម៖<br>បំផុសសំណួរដល់ក្រុម៖<br>- ដូចម្តេចដែលហៅថាការទទួលស្គាល់ពីកំហុស ?ចូររកឧទាហរណ៍មកបង្ហាញ។<br>- ឱ្យសិក្ខាកាមកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ<br>- បង្ហាញចម្លើយដល់សិក្ខាកាម | ការទទួលស្គាល់ពីកំហុស៖<br>ជាវិធីដែលត្រូវអនុវត្តដើម្បីជួយកុមារឱ្យទទួលស្គាល់ពីកំហុសឆ្គងរបស់ពួកគេ និងកែលម្អកំហុសឆ្គងទាំងនោះ ។ កុមារចាំបាច់ត្រូវយល់ថា សកម្មភាពរបស់ពួកគេតែងនាំមកនូវផលប៉ះពាល់ ហើយពួកគេជាអ្នកទទួលខុសត្រូវក្នុងការជានាថាពួកគេត្រូវរកឱ្យឃើញពីកំហុសឆ្គងទាំងនោះ និងត្រូវធ្វើយ៉ាងណាកែប្រែវាឱ្យបានសមស្រប<br>- ការទទួលស្គាល់ពីកំហុស គឺជាការទទួលស្គាល់នូវអ្វីដែលខ្លួនឯងធ្វើខុស។<br>- ការទទួលស្គាល់ពីកំហុសគឺជាការទទួលស្គាល់នូវសកម្មភាពដែលប្រព្រឹត្តខុស។ | ការងារក្រុម៖<br>- ពិភាក្សាក្រុម<br>- កត់ត្រាលទ្ធផលលើក្រដាសផ្ទាំងធំ<br>- បង្ហាញលទ្ធផល ដោយភ្ជាប់ជាមួយឧទាហរណ៍ |
| ចែកសិក្ខាកាមជាបី ឬបួនក្រុម និងឧទាហរណ៍ចំនួន១មកបញ្ជាក់៖<br><br>តើការទទួលស្គាល់កំហុសមានអត្ថប្រយោជន៍ | ជាការជួយកុមារឱ្យទទួលស្គាល់កំហុសឆ្គងនៃអាកប្បកិរិយា ឬសកម្មភាពរបស់ពួកគេ ព្រមទាំងផលប៉ះពាល់ចំពោះអ្នកដទៃ ដឹងថាអ្វីដែលពួកគេបានធ្វើគឺមិនសមស្រប ដឹងពីមូលហេតុ និង គុណតម្លៃរបស់កុមារដទៃ | ការងារក្រុម៖<br>- ពិភាក្សាក្រុម<br>- កត់ត្រាលើក្រដាសផ្ទាំងធំ<br>- បង្ហាញលទ្ធផលដល់ក្រុមធំ |

| | | |
|---|---|---|
| អ្វីខ្លះ ?<br><br>- បង្ហាញចម្លើយដល់សិក្ខាកាម<br>- បកស្រាយចម្ងល់របស់សិក្ខាកាម | ទៀត ។<br>- ការទទួលស្គាល់ពីកំហុសមានអត្ថប្រយោជន៍ដូចជា ៖<br>○ ទទួលបានការកែលម្អ និងការលើកទឹកចិត្ត។ ឧទាហរណ៍៖សម្មស្សបានលួចសៀវភៅមិត្តរួមថ្នាក់ ដែលបង្កឱ្យមានបញ្ហានៅក្នុងថ្នាក់រៀន។ គ្រូបានសួររកអ្នកដែលបានលួចសៀវភៅមិត្តរួមថ្នាក់ តែត្រូវបានគាត់បដិសេធរហូត។ ក្រោយមកទើបគាត់បានទទួលកំហុស។ គ្រូបានណែនាំ និងលើកទឹកចិត្តគាត់បញ្ឈប់ការលួចព្រោះនេះជាអំពើខុសឆ្គង។ | - សួរសំណួរទៅអ្នកសម្របសម្រួល |
| ឱ្យសិក្ខាកាមពិភាក្សាជាមួយដៃគូឆ្លើយសំណួរខាងក្រោម៖<br><br>តើពេលណាដែល កុមារត្រូវប្រើពាក្យ« សុំអភ័យទោស» ?<br>- បង្ហាញចម្លើយដល់សិក្ខាកាម<br>- បកស្រាយចម្ងល់របស់សិក្ខាកាម | កុមារគប្បីចេះនិយាយពាក្យ«សុំទោស»ទៅកាន់កុមារដែលទទួលរងផលប៉ះពាល់ដោយសារសកម្មភាពរបស់ខ្លួន។ ពួកគេត្រូវការធ្វើការសុំទោសដោយផ្ទាល់។<br>- នៅពេលដែលខ្លួនប្រព្រឹត្តិនូវអំពើខុសឆ្គង នៅពេលដែលខ្លួនធ្វើឱ្យអ្នកដទៃមានបញ្ហាដោយសារខ្លួន ឬធ្វើឱ្យខូចខាតអ្វីមួយរបស់អ្នកដទៃ។ | - ពិភាក្សាជាមួយដៃគូ<br>- កត់ត្រាចម្លើយ<br>- បង្ហាញដល់ក្រុមធំ<br>- សួរសំណួរ |
| ឧទ្ទេសបង្ហាញ និងបំផុសសំណួរក្នុងក្រុមធំ ៖<br><br>ហេតុអ្វីបានជាកុមារត្រូវផ្តល់សំណងនៅពេលដែលប្រព្រឹត្តមិនសមរម្យចំពោះកុមារដទៃ ? | ជាការសងនូវអ្វីដែលបានបាត់បង់ ។ នៅពេលដែលកុមារម្នាក់បានសម្តែងចេញនូវអាកប្បកិរិយាអវិជ្ជមានដល់អ្នកដទៃ វាមានសារៈសំខាន់ណាស់ដែលពួកគេត្រូវចេះកែប្រែស្ថានភាព នេះឱ្យល្អឡើងវិញ ។ ពួកគេត្រូវដោះស្រាយបញ្ហា និងត្រូវសងការខូចខាតសម្រាប់ផល | - សិក្ខាកាមម្នាក់ៗគិតរកចម្លើយ<br>- ប្រាប់ដល់ក្រុមធំ<br>- សួរសំណួរ |

| | | |
|---|---|---|
| - កត់ត្រាចម្លើយរបស់សិក្ខាកាម<br>- បង្ហាញចម្លើយរបស់សិក្ខាកាម<br>- បកស្រាយចម្លល់របស់សិក្ខាកាម | ប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីអាកប្បកិរិយារបស់ពួកគេ ។ បើមិនធ្វើដូច្នេះទេ ការនិយាយពាក្យសុំទោស នឹងលែងមានន័យ ។<br>- កុមារត្រូវផ្តល់សំណងនៅពេលដែលប្រព្រឹត្តមិនសមរម្យចំពោះកុមារដទៃព្រោះកុមារត្រូវតែបស្នងនូវអ្វីដែលខ្លួនធ្វើខុស។<br>- ដើម្បីឱ្យកុមាររងគ្រោះស្ងប់ចិត្ត<br>- ដើម្បីរក្សាទំនាក់ទំនងឡើងវិញ | |
| ចែកសិក្ខាកាមជា៣ ទៅ៤ក្រុម<br>សួរសំណួរ៖<br><br>តើការផ្សះផ្សាអាចដោះស្រាយអ្វីខ្លះចំពោះកុមារពេលជួបបញ្ហា ?<br>- សម្របសម្រួលតាមក្រុម<br>- បង្ហាញចម្លើយដល់សិក្ខាកាម | ប្រការនេះនឹងមាន ប្រសិទ្ធភាពសម្រាប់ការស្តារឡើងវិញនូវទំនុកចិត្ត ប៉ុន្តែត្រូវយកចិត្តទុកដាក់ដើម្បីធានាថាការណ៍នេះមិនមែនជា«ការសងសឹក»ឬគំនុំគុំគួនទេ។<br>- ការផ្សះផ្សាអាចដោះស្រាយអាចរក្សាចំណងមិត្តភាពឡើងវិញ<br>ការផ្សះផ្សាអាចដោះស្រាយអាចធ្វើឱ្យកុមារទាំងពីររៀនសូត្រពីគ្នាទៅវិញទៅមក។ | ការងារក្រុម៖<br>- ពិភាក្សាក្រុម<br>- កត់ត្រា<br>- បង្ហាញដល់ក្រុមធំ |
| - ចែកសិក្ខាកាមជា៣ ឬ៤ក្រុម<br>- សម្របសម្រួលឱ្យក្រុមពិភាក្សាក្រុម<br><br>- តើការផ្សះផ្សាគួរតែធ្វើឡើងជាលក្ខណៈដាច់ដោយឡែក ឬនៅចំពោះមុខមនុស្សច្រើន ? | វិធីនេះត្រូវអនុវត្តលើកុមារជាលក្ខណៈបុគ្គល និងត្រូវធ្វើឡើងដាច់ដោយឡែក មិនមែននៅចំពោះមុខកុមារជាច្រើនទេ។ វិធីនេះ ពិតជាជួយដោះស្រាយនូវស្ថានភាពនៃការប្រឈមមុខដាក់គ្នាដោយចេតនា។ ប្រសិនបើកុមារនៅតែបន្ត បដិសេធមិនធ្វើតាមការផ្សះផ្សារទៀតនោះ វិធីនេះនឹងត្រូវពង្រឹងបន្ថែមទៀត។<br>- ការផ្សះផ្សាគួរតែធ្វើឡើងជាលក្ខណៈដាច់ដោយ | ការងារក្រុម៖<br>- ពិភាក្សាក្រុម<br>- បង្ហាញលទ្ធផលដល់ក្រុមធំ<br>- សំណួរដល់អ្នកសម្របសម្រួល |

| | | |
|---|---|---|
| - បង្ហាញចម្លើយដល់សិក្ខាកាម | ទ្បែក | |

## កិច្ចតែងការបង្រៀន/បណ្ដុះបណ្ដាល (សម្រាប់តែជំហានទី៣)

**បំណិន និងខ្លឹមសារមេរៀន** ៖ **ប្រព័ន្ធគ្រប់គ្រងថ្នាក់រៀន ឬអាកប្បកិរិយា**

**វិធីសាស្ត្រ និងសកម្មភាព** ៖ បទបង្ហាញ ពិភាក្សា ការងារក្រុម ពន្យល់បង្ហាញនិងលើកឧទាហរណ៍មកបញ្ជាក់

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖

**វិជ្ជាសម្បទា៖**

- សិក្ខាកាមយល់ច្បាស់អំពីប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយា

**បំណិនសម្បទា៖**

- សិក្ខាកាមអាចចេះពីរបៀបរៀបចំប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយា
- សិក្ខាកាមអាចអនុវត្តប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាបានជាប្រចាំជាមួយសិស្ស

**ចរិយាសម្បទា៖**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីអ្វីដែលលោកគ្រូ អ្នកគ្រូបានធ្វើជាមួយកូនគាត់ និងអាចចែករំលែកវិធីសាស្រ្តមួយចំនួននៃបច្ចេកទេសនេះយកទៅអនុវត្តជាមួយកូននៅផ្ទះដើម្បីជួយកុមារឱ្យកាត់បន្ថយនូវអាកប្បកិរិយា /ការប្រព្រឹត្តដែលមិនសមរម្យ។

**សម្ភារឧបទេស** ៖

- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត
- កុំព្យូទ័រយួរដៃ

- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| - ចែកសិក្ខាកាមជា៣ ឬ៤ ក្រុម<br>- សួរសំណួរដល់ក្រុមនីមួយៗ<br>- តើប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាធ្វើឡើងដើម្បីអ្វី?<br>- កត់ត្រាចម្លើយរបស់សិក្ខាកាមលើក្រដាសផ្ទាំងធំ<br>- បង្ហាញចម្លើយដល់សិក្ខាកាម | យើងត្រូវការ «ប្រព័ន្ធ» ដើម្បីគាំទ្រដល់ការផ្តល់រង្វាន់ និងការដករង្វាន់ដើម្បីឱ្យមានភាពសមស្របទៅតាមអាកប្បកិរិយារបស់កុមារ និងធានាថាយើងអាចផ្តល់រង្វាន់លើកទឹកចិត្ត មិនមែនត្រឹមតែជា«ការសរសើរ»នោះទេ។ ការលើកទឹកចិត្តសិស្ស ជួយពួកគេឱ្យរៀនធ្វើការងារផ្សេងៗដើម្បីសម្រេចគោលបំណង ។ ពួកគេអាចស្វែងយល់ពីអ្វីដែលត្រូវធ្វើ និង ដឹងអំពីសារសំខាន់នៃការប្រព្រឹត្តិសមស្របដើម្បីទទួលបានរង្វាន់ ក៏ដូចជាការទទួលខុសត្រូវរបស់ពួកគេក្នុងការបំពេញការងារជាក្រុមតូច ក្រុមធំ ឬថ្នាក់រៀន ព្រមទាំងជួយឱ្យកុមារយល់ដឹងអំពីសមធម៌ ភាតរភាព និងយុត្តិធម៌ក្នុងការទទួលបានរង្វាន់ទាំងនោះ ។<br>- ប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាធ្វើឡើងដើម្បីគ្រប់គ្រងអាកប្បកិរិយាខុសឆ្គងរបស់កុមារ | ការងារក្រុម៖<br>- ពិភាក្សាគ្នា<br>- កត់ត្រាលទ្ធផលនៃការពិភាក្សា<br>- បង្ហាញលទ្ធផលក្រុមធំ |

| | | |
|---|---|---|
| | - ប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាធ្វើឡើងដើម្បីងាយស្រួលក្នុងការគ្រប់គ្រងអាកប្បកិរិយាល្អៗរបស់កុមារដើម្បីត្រៀមក្នុងការផ្តល់រង្វាន់។<br>- ជាវិធីសាស្ត្រមួយជួយកាត់បន្ថយអាកប្បកិរិយាខុសឆ្គងរបស់កុមារឱ្យបានប្រសើរឡើង។ | |
| - ចែកសិក្ខាកាមជាក្រុមតូចៗ<br>- សំណួរបំផុសដល់ក្រុម<br>តើប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាសម្រាប់ការតាមដានអាកប្បកិរិយាសិស្សមានអ្វីខ្លះ ?<br>- គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្តារខៀន។<br>- គ្រូសម្របសម្រួលបង្ហាញចម្លើយដោយអោយសិស្សអានមេរៀន | ប្រព័ន្ធក្នុងថ្នាក់រៀនទាំងមូលសម្រាប់ការតាមដានអាកប្បកិរិយាសិស្ស៖<br>• ពិន្ទុ ឬផ្កាយរង្វាន់ (រង្វាន់ផ្សេងៗគ្នា ទៅតាមកម្រិតអាយុ)<br>• រូបភាពដូចជាមុខញញឹម មុខសប្បាយចិត្ត និងពិន្ទុ (អាចយកមកប្រើប្រាស់ដូចខាងលើ ឬប្រើជាសញ្ញាក្រើនរំឭក)<br>• ការផ្តល់រង្វាន់ជាក្រុមធំ ក្រុមតូច និងពិន្ទុជួយដល់ការប្រកួតប្រជែងការងារក្រុមតូចក្រុមធំ ។<br>- ប្រព័ន្ធគ្រប់គ្រងថ្នាក់រៀនឬអាកប្បកិរិយាសម្រាប់ការតាមដានអាកប្បកិរិយាសិស្សរួមមាន៖<br>○ បង្កើតតារាងសកម្មភាព និងមានដាក់រូបភាពតំណាងឱ្យភាពពេញចិត្តនឹង | ការងារក្រុម៖<br>- ពិភាក្សាគ្នា<br>- កត់ត្រាលទ្ធផលនៃការពិភាក្សា<br>- បង្ហាញលទ្ធផលក្រុមធំ |

| | | |
|---|---|---|
| | ទង្វើរបស់គាត់<br>ឧទាហរណ៍៖<br>សំអាចផ្ទង់អារម្មណ៍អង្គុយរៀនបានត្រឹមតែ ២នាទីប៉ុណ្ណោះ។ ក្រោយមកសំដើរចេញពីកៅអី រួចចេញទៅក្រៅថ្នាក់។លោកគ្រូ អ្នកគ្រូបានបង្កើតជាតារាងដើម្បីធ្វើជាប្រព័ន្ធគ្រប់គ្រងអាកប្បកិរិយាគាត់។ គ្រូបានប្រាប់ និងបង្ហាញតារាងនោះដល់សំថា បើកូនអង្គុយបាន៣នាទី លោកគ្រូ/អ្នកគ្រូនឹងឱ្យរូបបិទមុខញញឹមមួយដែលកូនចូលចិត្ត បិទនៅលើម៉ោងដែលកូនធ្វើបានល្អ។សំសប្បាយចិត្តនឹងខំអង្គុយឱ្យបាន៣នាទី ៤នាទី...តាមការណែនាំរបស់លោកគ្រូ អ្នកគ្រូដើម្បីទទួលបានរូបញញឹមទៅបិទនឹងតារាងរបស់គាត់។ថ្ងៃក្រោយៗមកសំអង្គុយបានរយៈពេលវែងជាងមុន បន្តិចម្តងៗគាត់អាចផ្ទង់អារម្មណ៍អង្គុយរៀនដូចកុមារធម្មតា។ | |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិន និងខ្លឹមសារមេរៀន** ៖ **ការសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមានជាមុន**

**វិធីសាស្ត្រ និងសកម្មភាព** ៖ បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ សម្តែងតួ បង្ហាញវីដេអូ ករណីសិក្សា រូបភាព បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងទុកពីការសិក្សា**

**ចំណេះដឹងសម្បទា៖**

- សិក្ខាកាមយល់ច្បាស់អំពីការសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមានជាមុន

**បំណិនសម្បទា៖**

- សិក្ខាកាមអាចយល់ដឹងពីវិធីសាស្ត្រក្នុងការសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមានជាមុន
- សិក្ខាកាមអាចអនុវត្តបច្ចេកទេសការសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមានជាមុនជាមួយសិស្សជាប្រចាំក្នុងថ្នាក់រៀន

**ចរិយាសម្បទា៖**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីអ្វីដែលលោកគ្រូ អ្នកគ្រូបានធ្វើជាមួយកូនគាត់ និងអាចចែករំលែកវិធីសាស្ត្រមួយចំនួននៃបច្ចេកទេសនេះយកទៅអនុវត្តជាមួយកូននៅផ្ទះដើម្បីជួយកុមារឱ្យកាត់បន្ថយនូវអាកប្បកិរិយា /ការប្រព្រឹត្តដែលមិនសមរម្យ។

**សម្ភារឧបទ្ទេស** ៖

- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត
- កុំព្យូទ័រយួរដៃ

- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| - ចែកសិក្ខាកាមជាក្រុមតូចៗ<br>- សួរសំណួរបំផុសដល់ក្រុម<br>ហេតុអ្វីបានជាត្រូវសរសើរដល់កុមារដែលមានអាកប្បកិរិយាវិជ្ជមាន ?<br>- គ្រូសម្របសម្រួលកត់ចម្លើយនៅលើក្តារខៀន<br>- គ្រូសម្របសម្រួលបង្ហាញចម្លើយដោយអោយសិស្សអានមេរៀន | នេះគឺជាការឆ្លុះបញ្ចាំងពីលក្ខណៈវិជ្ជមាន ហើយក្រើនរំឭកតាមបែបវិជ្ជមានទៅដល់កុមារម្នាក់នោះ ក៏ដូចជាសិស្សក្នុងថ្នាក់ទាំងមូលផងដែរដើម្បីឱ្យពួកគេមានអាកប្បកិរិយាវិជ្ជមាន ។<br>- ដើម្បីលើកទឹកចិត្តកុមារ ដែលមានអាកប្បកិរិយាល្អ និងបន្តធ្វើល្អទៀត<br>- ចង់ឱ្យកុមារដែលមានអាកប្បកិរិយាមិនល្អយកគំរូតាម<br>ឧទាហរណ៍៖<br>សូរិយាកូនធ្វើលំហាត់នេះបានល្អណាស់។ កូនគួរជួយពន្យល់ដល់មិត្តភ័ក្តិណាដែលមិនទាន់យល់ពីលំហាត់នេះ។ | ការងារក្រុម<br>- ពិភាក្សាគ្នា<br>- មើល ស្តាប់ និងកត់ត្រា ទៅលើការប្រើប្រាស់ភាសា អាកប្បកិរិយា និងការងាររបស់កុមារ<br>- រាយការណ៍កំណត់ត្រារបស់ខ្លួនដល់ក្រុមរបស់ខ្លួន |
| ចែកសិក្ខាកាមជាក្រុម៤ឬ៥នាក់<br>▪ បែងចែកសិក្ខាកាមជា៣ | គ្រូត្រូវព្យាយាមសរសើរកុមារដែលមានអាកប្បកិរិយាល្អដែលនៅក្បែរ។ ភាគច្រើន កុមារដែលមានអាកប្បកិរិយាមិនសមរម្យក៏ចង់ទទួលបាននូវការចាប់អារម្មណ៍ និងការសរសើរពីគ្រូផងដែរ ប្រសិនបើគេស្តាប់ឮកុមារដទៃ | - ពិភាក្សាក្រុម<br>- កត់ត្រាលទ្ធផលក្រុម<br>- បង្ហាញលទ្ធផលដល់ក្រុម |

| | | |
|---|---|---|
| ក្រុមតូចៗ<br>▪ នាំសិក្ខាកាមធ្វើការងារក្រុម<br>▪ នាំសិក្ខាកាមរាយការណ៍<br>▪ បកស្រាយសំណួររបស់សិក្ខាកាម<br>▪ បង្ហាញដល់សិក្ខាកាម<br><br>តើគ្រូត្រូវសរសើរកុមារដែលមានអាកប្បកិរិយាវិជ្ជមាននៅជិតឬកុមារនៅឆ្ងាយពីកុមារដែលមានអាកប្បកិរិយាអវិជ្ជមាន ? | ទៀតទទួលបានការសរសើរ ដូចនេះពួកគេនឹងកែប្រែអកប្បកិរិយា ឬសកម្មភាពរបស់ពួកគេ ។ចំណុចនេះអាចមានប្រសិទ្ធភាព ជាពិសេសសម្រាប់កុមារាដែលពួកគេមានចរិតចូលចិត្តប្រកួតប្រជែង។<br>- គ្រូត្រូវសរសើរកុមារដែលមានអាកប្បកិរិយាវិជ្ជមាននៅជិត កុមារដែលមានអាកប្បកិរិយាអវិជ្ជមាន<br>- គ្រូត្រូវសរសើរកុមារដែលមានអាកប្បកិរិយាវិជ្ជមាន កុមារនៅឆ្ងាយពីកុមារដែលមានអាកប្បកិរិយាអវិជ្ជមាន<br>ដោយសារកុមារដែលនៅឆ្ងាយ ពេលខ្លះគាត់ក៏ត្រូវការការលើកទឹកចិត្តដែរ | |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិន និងខ្លឹមសារមេរៀន** ៖ **កៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)**

**វិធីសាស្ត្រ និងសកម្មភាព** ៖ : បទបង្ហាញ ពិភាក្សា ការងារក្រុម ការងារដៃគូ ការងារបុគ្គល ពន្យល់បង្ហាញ បង្ហាញលទ្ធផលការងារក្រុម ។ល។

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖

**ចំណេះសម្បទា៖**

- សិក្ខាកាមយល់ច្បាស់អំពីការកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)

**បំណិនសម្បទា៖**

- សិក្ខាកាមអាចវិភាគទៅលើការប្រព្រឹត្តរបស់កុមារដែលត្រូវប្រើវិធីសាស្ត្រកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)
- សិក្ខាកាមអាចអនុវត្តកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)ជាមួយសិស្សជាប្រចាំក្នុងថ្នាក់រៀន

**ចរិយាសម្បទា៖**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីអ្វីដែលលោកគ្រូ អ្នកគ្រូបានធ្វើជាមួយកូនគាត់ និងអាចចែករំលែកវិធីសាស្ត្រមួយចំនួននៃបច្ចេកទេសនេះយកទៅអនុវត្តជាមួយកូននៅផ្ទះដើម្បីជួយកុមារឱ្យកាត់បន្ថយនូវអាកប្បកិរិយា /ការប្រព្រឹត្តដែលមិនសមរម្យ។

**សម្ភារឧបទេស** ៖

- ក្តារខៀន ផ្ទាំងក្រដាសធំ ហ្វឺត ស្កុត
- កុំព្យូទ័រយួរដៃ

- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| - ចែកសិក្ខាកាមជាក្រុម៣ទៅ៤ក្រុម<br>- សួរសំណួរ<br>តើកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)ជាអ្វី?<br>- សម្របសម្រួលក្រុមឱ្យពិភាក្សាគ្នា<br>- ឱ្យសិក្ខាកាមកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។<br>- បង្ហញចម្លើយដល់ក្រុមធំ | នេះគឺជាការឆ្លុះបញ្ចាំងពីលក្ខណៈវិជ្ជមាន ហើយក្រើនរំឭកតាមបែបវិជ្ជមានទៅដល់កុមារម្នាក់នោះ ក៏ដូចជាសិស្សក្នុងថ្នាក់ទាំងមូលផងដែរដើម្បីឱ្យពួកគេមានអាកប្បកិរិយាវិជ្ជមាន ។<br>- កៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម) គឺជាវិធីសាស្ត្រក្នុងការដាក់ពិន័យកុមារពេលប្រព្រឹត្តអាកប្បកិរិយាខុសឆ្គង<br>- គឺជាវិធីសាស្ត្រក្នុងការទុកពេលឱ្យកុមារពិចារណាកំហុសឆ្គងខ្លួនឯង | - ពិភាក្សាក្រុម<br>- កត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ<br>- រាយការណ៍ដល់ក្រុមធំ |
| - ឱ្យសិក្ខាកាមអានមេរៀនទំព័រទី ២០៩<br>- ហើយឆ្លើយសំណួរ<br>តើកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម) មានសារៈសំខាន់អ្វីខ្លះដល់កុមារ?<br>- បង្ហាញចម្លើយដល់សិក្ខាកាម | គ្រូត្រូវព្យាយាមសរសើរកុមារដែលមានអាកប្បកិរិយាល្អដែលនៅក្បែរ។ ភាគច្រើន កុមារដែលមានអាកប្បកិរិយាមិនសមរម្យក៏ចង់ទទួលបាននូវការចាប់អារម្មណ៍ និងការសរសើរពីគ្រូផងដែរ ប្រសិនបើគេស្តាប់ឮកុមារដទៃទៀតទទួលបានការសរសើរ ដូចនេះពួកគេនឹងកែប្រែអកប្បកិរិយា ឬសកម្មភាពរបស់ពួកគេ ។ចំណុចនេះអាចមានប្រសិទ្ធភាព ជាពិសេសសម្រាប់កុមារដែលពួកគេមានចរិតចូលចិត្តប្រកួតប្រជែង។<br>- មានសារៈសំខាន់ឱ្យកុមារពិចារណា និងកែប្រែកំហុស | - អានមេរៀន<br>- រាយការណ៍ចម្លើយ |

| | | |
|---|---|---|
| | ឆ្លងរបស់ខ្លួន<br>- មិនឱ្យគាត់រំខានកុមារដទៃ | |
| - ចែកសំណួរឱ្យសិក្ខាកាមតាមតុនីមួយៗពិភាក្សា ហើយរាយការណ៍<br><br>តើអ្វីដែលលោកគ្រូ អ្នកគ្រូត្រូវប្រុងប្រយ័ត្ននៅពេលប្រើវិធីសាស្ត្រកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)?<br>- ផ្តល់ចម្លើយដល់សិក្ខាកាម | លោកគ្រូ អ្នកគ្រូត្រូវប្រុងប្រយ័ត្ននៅពេលប្រើវិធីសាស្ត្រកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)៖<br>• មិនត្រូវដាក់ងារដល់កុមារ<br>• ត្រូវចែកឱ្យដាច់រវាងអាកប្បកិរិយា និងកុមារ<br>• ត្រូវផ្តល់ជម្រើសឱ្យកុមារ<br>• ប្រើប្រាស់ការគិត ការឆ្លុះបញ្ចាំង និងទុកពេលវេលាកែលម្អអាកប្បកិរិយា<br>• បង្រៀនពួកគេឱ្យចេះជ្រើសរើសដោយខ្លួនឯង<br>- លោកគ្រូ អ្នកគ្រូត្រូវប្រុងប្រយ័ត្ននៅពេលប្រើវិធីសាស្ត្រកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)៖<br>○ សុវត្ថិភាព<br>○ កុំបន្ទុះបង្អាប់ដល់កុមារ | - សិក្ខាកាមតាមតុពិភាក្សាគ្នា<br>- កត់ត្រាលទ្ធផលក្រុម<br>- រាយការណ៍ដល់ក្រុមធំ |

## កិច្ចតែងការបង្រៀន/បណ្តុះបណ្តាល (សម្រាប់តែជំហានទី៣)

**បំណិន និងខ្លឹមសារមេរៀន** ៖ **វិធីធ្វើឱ្យចិត្តស្ងប់**

**វិធីសាស្ត្រ និងសកម្មភាព** ៖ បទសបង្ហាញ ពិភាក្សា ការងារជាដៃគូ បំផុសសំណួរក្នុងក្រុមធំ និងឧទាហរណ៍បញ្ជាក់

**លទ្ធផលរំពឹងទុកពីការសិក្សា** ៖

**ចំណេះសម្បទា៖**

- សិក្ខាកាមយល់ច្បាស់អំពីវិធីធ្វើឱ្យចិត្តស្ងប់

**បំណិនសម្បទា៖**

- សិក្ខាកាមអាចចេះពីវិធីធ្វើឱ្យចិត្តស្ងប់
- សិក្ខាកាមអាចអនុវត្តកៅអីសញ្ជឹងគិត(អង្គុយម្នាក់ឯង ដាច់ដោយឡែកពីក្រុម)ជាមួយសិស្សជាប្រចាំក្នុងថ្នាក់រៀន

**ចរិយាសម្បទា៖**

- សិក្ខាកាមយកចំណេះដឹងនេះចែករំលែកដល់អាណាព្យាបាលសិស្សពីអ្វីដែលលោកគ្រូ អ្នកគ្រូបានធ្វើជាមួយកូនគាត់ និងអាចចែករំលែកវិធីសាស្ត្រមួយចំនួននៃបច្ចេកទេសនេះយកទៅអនុវត្តជាមួយកូននៅផ្ទះដើម្បីជួយកុមារឱ្យកាត់បន្ថយនូវអាកប្បកិរិយា /ការប្រព្រឹត្តដែលមិនសមរម្យ។

**សម្ភារឧបទ្ទេស** ៖

- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត
- កុំព្យូទ័រយួរដៃ
- LCD Projector

| សកម្មភាពគ្រូសម្របសម្រួល<br>Trainer's Activities: | ខ្លឹមសារមេរៀន<br>Key contents | សកម្មភាពសិស្ស/សិក្ខាកាម<br>Trainees' activities |
|---|---|---|
| បែកសិក្ខាកាមតាមតុ រួចឱ្យពិភាក្សាលើសំណួរខាងក្រោម៖<br><br>តើវិធីធ្វើឱ្យចិត្តស្ងប់ជាអ្វី?<br>- បង្ហាញចម្លើយដល់សិក្ខាកាម | វិធីធ្វើឱ្យចិត្តស្ងប់គឺដូចគ្នានឹងល្បែងថាមពលដែរ ប៉ុន្តែការធ្វើឱ្យស្ងប់ចិត្តមានគោលដៅធ្វើឱ្យកុមារផ្តោតអារម្មណ៍ជាជាង ធ្វើឱ្យពួកគេមានភាពសកម្ម ។<br>- វិធីធ្វើឱ្យចិត្តស្ងប់ គឺការបន្ធូរអារម្មណ៍ កាត់បន្ថយភាពតានតឹង។ | - ពិភាក្សាតាមតុ<br>- កត់ត្រាលទ្ធផលក្រុម<br>- រាយការណ៍ដល់ក្រុមធំ |
| - ធ្វើបង្ហាញពីវិធីធ្វើឱ្យចិត្តស្ងប់ឱ្យសិក្ខាកាមមើល។<br>- នាំសិក្ខាកាមធ្វើវិធីចិត្តស្ងប់ទាំងអស់គ្នា<br>- ឱ្យសិក្ខាកាមទាំងអស់រាប់ពី១ ដល់១០ យឺតៗ<br>សួរសំណួរដល់ក្រុមធំ<br>- តើអ្នកមានអារម្មណ៍យ៉ាងម៉េច?<br>- តើអ្វីជាវិធីធ្វើឱ្យចិត្តស្ងប់?<br>គ្រូឧទ្ទេសកត់ចម្លើយរបស់សិក្ខាកាមលើក្តារខៀន<br>- គ្រូឧទ្ទេសបង្ហាញចម្លើយ | វិធីនេះមានដូចជា៖<br>• ការធ្វើសមាធិ<br>• ការរាប់យឺតៗដល់លេខ១០<br>• អោបដៃ<br>• ដកដង្ហើមចេញចូលឱ្យវែង<br>• ល្បែងសត្វតោដេក ឱ្យសិស្សដាក់ក្បាលលើតុ ហើយព្យាយាមនៅស្ងៀមមួយកន្លែងតាមដែលអាចធ្វើបាន (សត្វតោដេក) ហើយគ្រូដើរចុះឡើង អ្នកដែលនៅស្ងាត់ស្ងៀមបានយូរជាងគេគឺជាអ្នកឈ្នះ។<br>• និទានរឿងឱ្យសិស្សស្តាប់<br>• សម្រួល<br>• ដកដង្ហើមវែងៗ<br>• សមាធិ<br>• រកកន្លែងស្ងប់ស្ងាត់ | - ធ្វើតាមការណែនាំរបស់អ្នកសម្របសម្រួល<br>- រាប់ពី១ ដល់១០ យឺតៗ<br>- ប្រាប់ពីអារម្មណ៍ដល់ក្រុមធំ |